NDI

NATIONAL
DEMOCRATIC
INSTITUTE






# របាយការណ៍ស្តីពី

# កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនៅកម្ពុជា

ពី ខែវិច្ឆិកា ឆ្នាំ២០១០ ដល់ ខែកញ្ញា ឆ្នាំ២០១១

រៀបរៀងដោយ ឡូរ៉ា ថនថុន
នាយកប្រចាំប្រទេស
វិទ្យាស្ថានជាតិប្រជាធិបតេយ្យ
ផ្ទះលេខ ២១អា ផ្លូវលេខ ៣៥២
សង្កាត់បឹងកេងកងទី១
ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

National Democratic Institute
455 Massachusetts Avenue, NW, 8th Floor
Washington, DC 20001-2621
USA
Tel: (202) 728 5500
Fax: (888) 875 2887
www.ndi.org

រក្សាសិទ្ធិ © វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) ឆ្នាំ២០១១។ រក្សាសិទ្ធិគ្រប់បែបយ៉ាង។ ផ្នែកនៃស្នាដៃនេះ អាចផលិតឡើងវិញ និង/ឬបកប្រែសម្រាប់គោលបំណងមិនធ្វើពាណិជ្ជកម្ម ល្គឹកណាតែវិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ ត្រូវបានទទួលស្គាល់ថា ជាប្រភពដើម ហើយឯកសារបកប្រែនោះត្រូវផ្ញើជូនវិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ។ របាយការណ៍ជាភាសាខ្មែរនេះ គឺជាការបកប្រែក្រៅផ្លូវការ។

របាយការណ៍នេះ ត្រូវបានធ្វើឡើងក្រោមការឧបត្ថម្ភដ៏ថ្លៃថ្លារបស់ពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ក្រោមកិច្ចព្រមព្រៀងសហប្រតិបត្តិការលេខ 442-A-09-00001។ មតិយោបល់ ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ គឺជាមតិយោបល់របស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

# វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ

វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) គឺជាអង្គការមិនរកកម្រៃ មិនប្រកាន់គណបក្ស និងមិនមែនរដ្ឋាភិបាល ដែលឆ្លើយតបទៅនឹងសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋនៅជុំវិញពិភពលោក ដែលចង់រស់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីទទួលស្គាល់ និងលើកកម្ពស់សិទ្ធិមនុស្សជាមូលដ្ឋាន។

ចាប់តាំងពីការបង្កើតឡើងនៅក្នុងឆ្នាំ១៩៨៣ វិទ្យាស្ថានជាតិ NDI និងដៃគូក្នុងស្រុក (តាមប្រទេស) របស់ខ្លួនបានធ្វើការ ដើម្បីគាំទ្រ និងពង្រឹងស្ថាប័នប្រជាធិបតេយ្យ និងការអនុវត្តន៍ដោយការពង្រឹងគណបក្សនយោបាយ អង្គការសង្គមស៊ីវិល និងសភា ការការពារដំណើរការបោះឆ្នោត និងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ការបើកចំហ និងការទទួលខុសត្រូវ (គណនេយ្យភាព) នៅក្នុងរដ្ឋាភិបាល។

ដោយមានបុគ្គលិក និងអ្នកអនុវត្តន៍នយោបាយស្ម័គ្រចិត្តជាច្រើនមកពីបណ្តាប្រទេសជាង១០០ វិទ្យាស្ថានជាតិ NDI បានអញ្ជើញបុគ្គល និងក្រុមនីមួយៗឲ្យចូលរួម ដើម្បីចែករំលែកគំនិត ចំណេះដឹង បទពិសោធន៍ និងជំនាញនានា។ ដៃគូជាច្រើន បានទទួលបទពិសោធន៍យ៉ាងទូលំទូលាយ អំពីការអនុវត្តន៍ល្អបំផុតនៅក្នុងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យអន្តរជាតិ ដែលអាចផ្លាស់ប្តូរ ស្របទៅតាមតម្រូវការរបស់បណ្តាប្រទេសផ្ទាល់ខ្លួនរបស់ពួកគេ។ វិធីសាស្ត្រពហុជាតិរបស់វិទ្យាស្ថានជាតិ NDI ពង្រឹងសារថា នៅខណៈពេលដែលមិនមានគំរូលទ្ធិប្រជាធិបតេយ្យតែមួយ ដូច្នេះ គោលការណ៍ស្នូលពិតប្រាកដទាំងឡាយ ត្រូវបានចែករំលែកដោយប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យទាំងអស់។

កិច្ចការរបស់វិទ្យាស្ថាននេះ គឺលើកតម្កើងគោលការណ៍ដែលបានចែងនៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស។ ជាមួយគ្នានេះដែរ កិច្ចការរបស់វិទ្យាស្ថាន ក៏ជម្រុញឲ្យមានការបង្កើតបណ្តាញទំនាក់ទំនងគ្នាជាលក្ខណៈស្ថាប័នក្នុងចំណោមប្រជាពលរដ្ឋ ស្ថាប័ននយោបាយ និងមន្ត្រីជាប់ឆ្នោត ហើយនឹងពង្រឹងសមត្ថភាពរបស់ពួកគេ ដើម្បីធ្វើឲ្យប្រសើរឡើងនូវគុណភាពជីវិតសម្រាប់ប្រជាពលរដ្ឋទាំងអស់។ សម្រាប់ព័ត៌មានបន្ថែមអំពីវិទ្យាស្ថានជាតិ NDI សូមមើលគេហទំព័រ៖ www.ndi.org ។

## វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិនៅកម្ពុជា

ចាប់តាំងពីឆ្នាំ១៩៩២ វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិនៅកម្ពុជា (NDI) បានជួយឧបត្ថម្ភសកម្មជនប្រជាធិបតេយ្យនៅកម្ពុជា តាមរយៈកិច្ចសហការជាមួយក្រុមអង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ និងផ្តួចផ្តើមគំនិតឲ្យគាំទ្រការបោះឆ្នោត។ កម្មវិធីបច្ចុប្បន្នរបស់វិទ្យាស្ថានជាតិ NDI នៅក្នុងប្រទេសកម្ពុជា គឺខិតខំដើម្បីពង្រឹងសមត្ថភាពរបស់ប្រជាពលរដ្ឋ និងគណបក្សនយោបាយ ដើម្បីចូលរួមឲ្យកាន់តែមានប្រសិទ្ធភាពនៅក្នុងដំណើរការនយោបាយ។ វិទ្យាស្ថានជាតិ NDI សហការជាមួយក្រុមសង្គមស៊ីវិលក្នុងស្រុក ដើម្បី

រៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដែលអញ្ជើញប្រជាពលរដ្ឋ និងអ្នកតំណាងរាស្ត្រជួបគ្នា ដើម្បីពិភាក្សាពីបញ្ហាដែលជាកង្វល់នៅក្នុងមូលដ្ឋាន។ វិទ្យាស្ថានជាតិ NDI គឺមានផែនការរៀបចំកិច្ចពិភាក្សាបេក្ខជន បណ្ដុះបណ្ដាលបេក្ខជន និងការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតថ្នាក់ជ្រើសរើសក្រុមប្រឹក្សាឃុំ - សង្កាត់ឆ្នាំ២០១២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ នាពេលខាងមុខនេះ។

# បញ្ជីមាតិកា


I. **ប្រវត្តិ** ........................................ 2

II. **សេចក្តីសង្ខេបនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត** .......... 8

ក. ជម្លោះដីធ្លី ........................................ 8

ខ. ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍ ........................ 13

គ. អំពើពុករលួយ ........................................ 18

ឃ. បញ្ហាផ្សេងៗ ........................................ 19

III. **លទ្ធផលនៃការពិភាក្សាក្រុមគោលដៅ** ........................ 21

IV. **សកម្មភាព និងលទ្ធផលក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត**...... 35

V. **សេចក្តីសន្និដ្ឋាន** ........................................ 43

## I. **ប្រវត្តិ**

នៅកម្ពុជា ទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតមានភាពទន់ខ្សោយ។ ប្រជាពលរដ្ឋកម្រមានឱកាសដើម្បីសម្តែងមតិ ឬតស៊ូមតិដើម្បីឲ្យមានកំណែទម្រង់ទៅកាន់អ្នកតំណាងដែលជាប់ឆ្នោតរបស់ខ្លួន ហើយអ្នកតាក់តែងច្បាប់ជាច្រើន មិនបានចុះតាមមណ្ឌលបោះឆ្នោតរបស់ពួកគេឲ្យបានទៀងទាត់ ដើម្បីរាយការណ៍អំពីសកម្មភាព និងកម្មវិធីរបស់ពួកគេឡើយ។ ទោះបីជា អ្នកតំណាងរាស្ត្រម្នាក់ៗ បានខិតខំប្រឹងប្រែងដើម្បីចុះសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន និងរៀបចំកិច្ចប្រជុំដោយខ្លួនឯង ឬតាមរយៈគណបក្សនយោបាយរបស់ពួកគេក៏ដោយ ក៏ពួកគេនៅតែប្រឈមនឹងបញ្ហាពេលវេលាតិចតួច មធ្យោបាយមានកម្រិតនៅថ្នាក់មូលដ្ឋាន និងកង្វះខាតយន្តការដែលមានប្រសិទ្ធភាពសម្រាប់ម្ចាស់ឆ្នោត ធ្វើការទំនាក់ទំនងជាមួយពួកគេ។ ដោយសារទំនាក់ទំនងមានកម្រិតបែបនេះ ប្រជាពលរដ្ឋមានការយល់ដឹងតិចតួចអំពីតួនាទីរបស់សភា ឬការទទួលខុសត្រូវរបស់សភាក្នុងការតាក់តែងច្បាប់ តំណាង និងត្រួតពិនិត្យ ហើយអ្នកតំណាងរាស្ត្រ ក៏មានចំណេះដឹងមានកម្រិតអំពីមណ្ឌលបោះឆ្នោតរបស់ខ្លួន ហើយរដ្ឋសភានៅមានការខ្វះខាត ក្នុងការធ្វើជាតំណាងនូវតម្រូវការ និងផលប្រយោជន៍នៃម្ចាស់ឆ្នោតរបស់ខ្លួនដែរ។

ដើម្បីផ្តល់មធ្យោបាយសម្រាប់ទំនាក់ទំនងបែបនេះ វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI ឬវិទ្យាស្ថាន) បានរៀបចំកិច្ចពិភាក្សាពហុបក្សរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត (CDs) ចាប់តាំងពីឆ្នាំ២០០៤ ដែលមានការចូលរួមពីអ្នកតំណាងរាស្ត្រមកពីគ្រប់គណបក្សនយោបាយដែលមានអាសនៈនៅក្នុងសភា[1]។ កិច្ចពិភាក្សានេះ បង្កើនចំណេះដឹង និងទំនាក់ទំនងរបស់អ្នកតំណាងរាស្ត្រ (MNA) ជាមួយម្ចាស់ឆ្នោតរបស់ពួកគេ និងអប់រំប្រជាពលរដ្ឋអំពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកតំណាងរាស្ត្រនៅក្នុងសង្គមប្រជាធិបតេយ្យ។ គោលបំណងដ៏សំខាន់មួយទៀតនៃកម្មវិធីនេះ គឺដើម្បីបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីជម្រើសនយោបាយរបស់ខ្លួន ពីព្រោះ ពួកគេមានឱកាសតិចតួចក្នុងការស្តាប់នូវទស្សនៈ និងគោលនយោបាយផ្សេងៗពីគណបក្សដែលមិនកាន់អំណាច។ កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មានបំណងធ្វើឲ្យមានប្រក្រតីភាព និងបង្ហាញអំពីសារៈសំខាន់នៃកិច្ចពិភាក្សានៅកម្ពុជា ដោយមានការចែករំលែកគោលនយោបាយរវាងគូប្រជែងខាងនយោបាយកម្រកើតមាន និងត្រូវបានត្រួតពិនិត្យដោយប្រុងប្រយ័ត្ន។

ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១០ ដល់ខែកញ្ញា ឆ្នាំ២០១១ វិទ្យាស្ថានជាតិ NDI បានរៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ចំនួន២៤ នៅក្នុងខេត្តចំនួន១២ នៅកម្ពុជា

[1] ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) បានផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់កិច្ចពិភាក្សានេះចាប់តាំងពីកម្មវិធីនេះចាប់ផ្តើម។ នៅខែតុលា ឆ្នាំ២០០៩ កម្មវិធីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ត្រូវបានបញ្ចូលក្នុង *កម្មវិធីគណនេយ្យភាពក្នុងអភិបាលកិច្ច និងនយោបាយ (AGAP) កម្ពុជា* ដែលបានផ្តល់មូលនិធិដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) សម្រាប់រយៈពេល៥ឆ្នាំ ។

ជាមួយអ្នកតំណាងរាស្ត្រមកពីគណបក្ស[2] ដែលមានអាសនៈនៅក្នុងរដ្ឋសភា៖ បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្ដាល ក្រចេះ ព្រៃវែង សៀមរាប និងតាកែវ។ កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ត្រូវបានរៀបចំ២ដង ក្នុងមួយឆ្នាំ ក្នុងខេត្តនីមួយៗនៅក្នុងឃុំផ្សេងៗគ្នា។

ទម្រង់នៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មានលក្ខណៈស្រដៀងគ្នាទៅនឹងកិច្ចប្រជុំសាធារណៈរបស់សាលាក្រុង (town hall meeting) ហើយគ្រប់គ្នា ត្រូវបានស្វាគមន៍ឲ្យចូលរួម។ អ្នកភូមិ ចន្លោះពី៥០០នាក់ទៅ១,០០០នាក់ ចូលរួមនៅក្នុងកិច្ចពិភាក្សានីមួយៗ ដែលកិច្ចពិភាក្សានេះ ត្រូវបានសម្របសម្រួលដោយបុគ្គលិកពោរពេញដោយបទពិសោធន៍របស់វិទ្យាស្ថានជាតិ NDI ។ អ្នកតំណាងរាស្ត្រ អង្គុយជាអធិបតីចំពោះមុខអ្នកចូលរួម និងថ្លែងសុន្ទរកថាខ្លីដល់អ្នកចូលរួមស្ដាប់ទាំងអស់។ បន្ទាប់មក អ្នកចូលរួម ត្រូវបានផ្ដល់ឱកាសឲ្យលើកឡើងអំពីកង្វល់របស់ពួកគេ សួរសំណួរដោយផ្ទាល់ទៅអ្នកតំណាងរាស្ត្រម្នាក់ៗ និងសំណូមពរឲ្យពួកគេចាត់វិធានការដោះស្រាយបញ្ហាផ្សេងៗ។ នៅក្នុងពេលវេលាដែលបានបែងចែកសម្រាប់ពួកគេដើម្បីឆ្លើយតប អ្នកតំណាងរាស្ត្រម្នាក់ៗប្រើប្រាស់ឱកាសនោះដើម្បីចែករំលែកព័ត៌មានថ្មីៗដល់ប្រជាពលរដ្ឋអំពីសកម្មភាពរបស់អង្គនីតិប្បញ្ញត្តិ និងរដ្ឋាភិបាល ហើយផ្ដល់ព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងម្ចាស់ឆ្នោតរបស់ពួកគេ។ កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត លើកទឹកចិត្តឲ្យមានទំនាក់ទំនងពីរផ្លូវ និងពុំបានត្រៀមពាក្យសម្រាប់និយាយជាមុន ដោយអនុញ្ញាតឲ្យមានសំណួរពិបាកៗ និងការទាមទារជាច្រើនពីប្រជាពលរដ្ឋ។ ស្ថានីយ៍វិទ្យុចំនួន២ - វិទ្យុ FM៩៥.៥ និងវិទ្យុ FM៩៣.៥[3] – ចាក់ផ្សាយអំពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនៅទូទាំងប្រទេស ដោយពង្រីកនូវការគ្របដណ្ដប់របស់កម្មវិធី ដើម្បីធានាឲ្យមានអ្នកស្ដាប់កាន់តែច្រើនស្ដាប់នូវកិច្ចពិភាក្សានេះ។

---

[2] ប្រទេសកម្ពុជា មានប្រព័ន្ធបញ្ជីគណបក្សសមាមាត្រដែលមណ្ឌលអ្នកតំណាងរាស្ត្រនៅតាមខេត្ត មានសមាជិកពី១ ដល់ ១៨នាក់ ផ្អែកតាមចំនួនប្រជាពលរដ្ឋ។ វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ មិនរៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនៅតាមខេត្តណា ដែលមានអ្នកតំណាងរាស្ត្រមកពីគណបក្សតែមួយទេ។

[3] ការចាក់ផ្សាយគ្របដណ្ដប់លើរាជធានី-ខេត្តចំនួន២០ ក្នុងចំណោមរាជធានី-ខេត្តទាំង២៤ របស់ប្រទេសកម្ពុជា៖ កណ្ដាល កំពង់ឆ្នាំង កំពង់ចាម កំពង់ស្ពឺ កំពង់ធំ ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ក្រចេះ ព្រៃវែង ស្វាយរៀង កែប តាកែវ កំពត កោះកុង ប៉ៃលិន ឧត្តរមានជ័យ ព្រះវិហារ និងរាជធានីភ្នំពេញ។




អ្នកតំណាងរាស្ត្រ តំណាងគណបក្សនយោបាយចំនួន៤ ចូលរួមកម្មវិធីកិច្ចពិភាក្សារវាង
អ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត នៅភូមិអ្នកតាជ័យ ឃុំគោកគង់លិច ស្រុកកញ្ជៀច ខេត្តព្រៃវែង
កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ។

កម្មវិធីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត គឺជាព្រឹត្តិការណ៍ពហុបក្សមួយ ដែលតំណាងមកពីគណបក្សនយោបាយទាំង៥ ដែលមានអាសនៈនៅក្នុងរដ្ឋសភាចូលក្នុងកម្មវិធី គឺគណបក្សប្រជាជនកម្ពុជា (CPP) គណបក្ស សម រង្ស៊ី (SRP) គណបក្សហ៊្វុនស៊ិនប៉ិច (FUNCINPEC)[4] គណបក្សសិទ្ធិមនុស្ស (HRP) និងគណបក្ស នរោត្តម រណឫទ្ធិ(NRP)[5]។ ដូច្នេះ វេទិកានេះ ផ្តល់នូវឱកាសដ៏កម្រមួយសម្រាប់ការពិភាក្សាលើគោលនយោបាយ និងបង្ហាញអំពីភាពខុសគ្នារវាងអ្នកតំណាងរាស្ត្រមកពីគណបក្សផ្សេងៗ និងយុទ្ធសាស្ត្ររបស់ពួកគេចំពោះកង្វល់នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។ អាជ្ញាធរមូលដ្ឋាន ដូចជាក្រុមប្រឹក្សាឃុំ មេភូមិ និងមន្ត្រីថ្នាក់ស្រុក និងថ្នាក់ខេត្ត ជាញឹកញាប់ មានវត្តមាននៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ហើយនៅក្នុងឆ្នាំ២០១០ ដោយមានការសំណូមពររបស់គណបក្សនយោបាយ វិទ្យាស្ថាន ក៏ចាប់ផ្តើមផ្តល់ពេលវេលាដល់ពួកគេ ដើម្បីនិយាយនៅចុងបញ្ចប់នៃកិច្ចពិភាក្សាផងដែរ។ ដើម្បីធានាបាននូវសមធម៌ និងភាពអព្យាក្រឹត និងជម្រុញឲ្យមានកិច្ចពិភាក្សា

[4] គណបក្សហ៊្វុនស៊ិនប៉ិច (FUNCINPEC) គឺជាអក្សរកាត់សម្រាប់រណសិរ្សបង្រួមបង្រួមជាតិ ដើម្បីកម្ពុជាឯករាជ្យ អព្យាក្រឹត សន្តិភាព និងសហប្រតិបត្តិការ។ FUNCINPEC តំណាងឲ្យឈ្មោះគណបក្ស ជាភាសាបារាំង "Front Uni National pour un Cambodge Indépendant, Neutre, Pacifique, et Coopératif."

[5] ពីឆ្នាំ២០០៤ រហូតដល់ខែមីនា ឆ្នាំ២០០៨ គណបក្សនយោបាយតែបីប៉ុណ្ណោះ គឺគណបក្សប្រជាជនកម្ពុជា (CPP) គណបក្ស សម រង្ស៊ី (SRP) និងគណបក្សហ៊្វុនស៊ិនប៉ិច (FUNCINPEC) មានអាសនៈនៅក្នុងរដ្ឋសភា។ ដោយមានគណបក្សថ្មីពីរទៀត គឺគណបក្សសិទ្ធិមនុស្ស (HRP) និងគណបក្ស នរោត្តម រណឫទ្ធិ (NRP) ដែលទទួលបានអាសនៈនៅក្នុងការបោះឆ្នោតឆ្នាំ២០០៨ បច្ចុប្បន្ន មានគណបក្សចំនួន៥ ចូលរួម។

បែបស្ថាបនា វិទ្យាស្ថានជាតិ NDI បានបង្កើតក្រុមសីលធម៌[6]សម្រាប់អ្នកតំណាងរាស្ត្រ អ្នកចូលរួម និងអ្នកសម្របសម្រួលរបស់វិទ្យាស្ថានជាតិ NDI ។ ក្រុមសីលធម៌នេះ បញ្ជាក់អំពីចំណុចមួយចំនួនដូចជាការបែងចែកពេលវេលាសម្រាប់និយាយ ប្រធានបទសមស្រប និងមិនសមស្របសម្រាប់ការពិភាក្សា និងវិន័យទាក់ទងនឹងការចូលរួមរបស់អ្នកចូលរួម។

វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) សហការជាមួយអង្គការសង្គមស៊ីវិលនៅតាមមូលដ្ឋាន (CSOs) ឬអ្នកស្ម័គ្រចិត្តសហគមន៍នៅក្នុងខេត្តនីមួយៗ ដែលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ត្រូវបានរៀបចំឡើង[7] ។ អង្គការសង្គមស៊ីវិលទាំងនេះ ដើរតួនាទីផ្នែករៀបចំ និងភស្តុភារដ៏សំខាន់ក្នុងការធ្វើផែនការអនុវត្តកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ព្រមទាំងពិនិត្យតាមដានផលប៉ះពាល់របស់កិច្ចពិភាក្សាទាំងនេះនៅថ្នាក់មូលដ្ឋាន។ អង្គការដៃគូនៅមូលដ្ឋាន កំណត់ភូមិសម្រាប់រៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន និងគ្រប់គ្រងភស្តុភារសម្រាប់កិច្ចពិភាក្សានីមួយៗ។ លើសពីនេះទៀត វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ មានអ្នកស្ម័គ្រចិត្តសហគមន៍(CVs) នៅតាមខេត្តនីមួយៗ ដែលជួយកៀងគរប្រជាពលរដ្ឋ មុនការរៀបចំព្រឹត្តិការណ៍។ ពីរសប្តាហ៍មុនកិច្ចពិភាក្សានីមួយៗ អ្នកស្ម័គ្រចិត្តសហគមន៍ (CVs) និងដៃគូថ្នាក់ខេត្ត បានរៀបចំកិច្ចពិភាក្សាក្រុមតូច ដោយមានប្រជាពលរដ្ឋចំនួនប្រហែល៣៥នាក់ ចូលរួមក្នុងកិច្ចពិភាក្សានោះ ដើម្បីប្រមូលព័ត៌មានលើបញ្ហាផ្សេងៗដែលសហគមន៍កំពុងជួបប្រទះ។ បន្ទាប់មក វិទ្យាស្ថានជាតិ NDI សង្ខេបជូនអ្នកតំណាងរាស្ត្រដែលត្រូវចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អំពីបញ្ហាទាំងនេះដើម្បីជួយដល់ពួកគេក្នុងការត្រៀមរៀបចំសម្រាប់កិច្ចពិភាក្សា។ លើសពីនេះទៀត ក្រុមការងាររបស់វិទ្យាស្ថានជាតិ NDI ធ្វើដំណើរទៅកាន់ទីកន្លែងដែលរៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត(CD)ពីរបីថ្ងៃមុនព្រឹត្តិការណ៍នៃកិច្ចពិភាក្សា ដើម្បីពន្យល់អំពីគោលគំនិតនៃកម្មវិធី

[6] វិទ្យាស្ថានជាតិ NDI បានបង្កើតក្រុមសីលធម៌នៅក្នុងឆ្នាំ២០០៨ ដើម្បីបំភ្លឺការយល់ច្រឡំ និងជៀសវាងការភាន់ច្រឡំលើដំណើរការកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត និងការចោទប្រកាន់អគតិ។ វិទ្យាស្ថានជាតិ NDI ក៏ទប់ស្កាត់ការវាយប្រហារដោយពាក្យសម្ដី និងការជេរប្រមាថជាលក្ខណៈបុគ្គលនៅក្នុងកិច្ចពិភាក្សាទាំងនេះផងដែរ។ វិធីទប់ស្កាត់ និងដោះស្រាយជម្លោះ ត្រូវបានព្រមព្រៀងដោយគណបក្សនយោបាយទាំង៥ ដែលចូលរួមធ្វើការបង្ហាញនៅក្នុងកម្មវិធីនេះ។ វិទ្យាស្ថានជាតិ NDI ពិនិត្យឡើងវិញជាទៀតទាត់លើក្រុមសីលធម៌ជាមួយបណ្ដាគណបក្ស ដើម្បីធានានូវភាពពាក់ព័ន្ធរបស់វា និងការកែតម្រូវក្នុងករណីចាំបាច់។

[7] ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១១ អង្គការសង្គមស៊ីវិលជាដៃគូរបស់វិទ្យាស្ថានជាតិ NDI រួមមាន៖ សមាគមឥន្ទ្រទេវី (IDA) នៅខេត្តកណ្ដាល អង្គការនគរភ្នំពេញច្រើងសុខុមាលភាពសហគមន៍ (NPCEO) នៅខេត្តកំពង់ចាម អង្គការកាត់បន្ថយទុពលភាព និងអនក្ខរភាព (VIR) នៅខេត្តសៀមរាប អង្គការអភិវឌ្ឍន៍កសិករខ្មែរ (KFD) នៅខេត្តបន្ទាយមានជ័យ អង្គការក្រុមទ្រទ្រង់ភូមិ (VSG) នៅខេត្តបាត់ដំបង អង្គការសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា (CoDec) នៅខេត្តកំពង់ធំ អង្គការបង្កើនសមត្ថភាពសហគមន៍ដើម្បីអភិវឌ្ឍន៍ (CCD) នៅខេត្តកំពង់ឆ្នាំង និងអង្គការសកម្មភាពដើម្បីសុខុមាលភាពស្ត្រីកម្ពុជា (KWWA) នៅខេត្តក្រចេះ។ វិទ្យាស្ថានជាតិ NDI សហការជាមួយអ្នកស្ម័គ្រចិត្តសហគមន៍តែ ៤ ខេត្តប៉ុណ្ណោះ គឺនៅខេត្តកំពត ព្រៃវែង តាកែវ និងកំពង់ស្ពឺ។

ទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតដល់អាជ្ញាធរមូលដ្ឋាន និងក្រុមសហគមន៍ ដើម្បីធានាបាននូវការគាំទ្រពីពួកគេ។ ក្នុងអំឡុងការជួបប្រជុំទាំងនេះ បុគ្គលិកវិទ្យាស្ថានជាតិ NDI ពន្យល់អំពីគោលបំណងនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត សារៈសំខាន់នៃការរៀបចំកិច្ចពិភាក្សាពហុបក្សទាំងនេះ គោលគំនិតនៃការទទួលខុសត្រូវ និងមុខងារជាតំណាងរបស់អ្នកតំណាងរាស្ត្រ។ មន្ត្រីមូលដ្ឋាន មានឱកាសសួរសំណួរ និងចែករំលែកសេចក្តីព្រួយបារម្ភនានា ដែលពួកគេអាចមានទាក់ទងនឹងកិច្ចពិភាក្សា។

បន្ទាប់ពីកិច្ចពិភាក្សានីមួយៗ វិទ្យាស្ថានជាតិ NDI បង្កើតតារាងពិនិត្យតាមដាន ដោយមានបញ្ហាដែលត្រូវបានលើកឡើង និងសកម្មភាពដែលបានស្នើឡើងដោយអ្នកតំណាងរាស្ត្រម្នាក់ៗ។ ក្រោយមក វិទ្យាស្ថានជាតិ NDI ទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្រយ៉ាងទៀងទាត់ ដើម្បីតាមដានដំណើរការរបស់ពួកគេ ក្នុងការបំពេញការសន្យាដែលពួកគេបានធ្វើក្នុងអំឡុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ ស្របពេលជាមួយគ្នានេះ អង្គការដៃគូមូលដ្ឋានរបស់វិទ្យាស្ថានជាតិ NDI ចុះទៅតាមភូមិ ដែលកិច្ចពិភាក្សាត្រូវបានរៀបចំនៅទីនោះ ដើម្បីពិនិត្យតាមដាននូវការផ្លាស់ប្តូរដែលបានកើតឡើង ដោយសារកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ លទ្ធផល និងគំនិតផ្តួចផ្តើមទាំងអស់នេះ ត្រូវបានកត់ត្រា និងរាយការណ៍ត្រឡប់ទៅសហគមន៍វិញ។ ការតាមដាននេះ មានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់ការទទួលខុសត្រូវ ដោយផ្តល់ឲ្យប្រជាពលរដ្ឋនូវព័ត៌មានដែលចាំបាច់ដើម្បីវិនិច្ឆ័យលើការបំពេញភារកិច្ចរបស់អ្នកតំណាងរាស្ត្ររបស់ខ្លួន។ វិទ្យាស្ថានជាតិ NDI ក៏រៀបចំការពិភាក្សាក្រុមគោលដៅមុន និងក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនីមួយៗផងដែរ ដើម្បីប្រមូលព័ត៌មានបែបគុណភាព និងវាយតម្លៃលើឥទ្ធិពលនៃកម្មវិធីទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតទៅលើចំណេះដឹង អាកប្បកិរិយា និងការអនុវត្តន៍របស់ប្រជាពលរដ្ឋ។ វិទ្យាស្ថានជាតិ NDI ក៏រៀបចំការសម្ភាសន៍ជាក្រុមជាមួយមន្ត្រីមូលដ្ឋានផងដែរ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដើម្បីប្រមូលមតិយោបល់ និងទស្សនៈរបស់ពួកគេអំពីកិច្ចពិភាក្សា និងបទពិសោធន៍ដែលទទួលបាន។

កម្មវិធីទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានលើកកម្ពស់ការយល់ដឹងក្នុងចំណោមសាធារណជនកម្ពុជាអំពីទំនាក់ទំនងរវាងបញ្ហានៅមូលដ្ឋាន និងការទទួលខុសត្រូវរបស់មន្ត្រីដែលបានជាប់ឆ្នោត។ កិច្ចពិភាក្សាទាំងនេះ ផ្តល់ឱកាសសម្រាប់អ្នកតំណាងរាស្ត្រក្នុងការពង្រឹងបន្ថែមនូវទំនាក់ទំនងជាមួយម្ចាស់ឆ្នោតរបស់ខ្លួន និងឆ្លើយតបទៅនឹងសំណូមពរ និងតម្រូវការរបស់សាធារណជន។ លើសពីនេះទៀត ដោយការបង្ហាញនូវភាពខុសគ្នារវាងគណបក្សនយោបាយនីមួយៗ ប្រជាពលរដ្ឋមានឱកាសរៀនសូត្រច្រើនអំពីមតិយោបល់ និន្នាការ និងកម្មវិធីនយោបាយផ្សេងៗគ្នានៃអ្នកតំណាងរាស្ត្ររបស់ពួកគេ និងយល់ដឹងច្រើនអំពីជម្រើសនយោបាយរបស់ខ្លួន។ នៅក្នុងករណីជាច្រើន កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ

និងម្ចាស់ឆ្នោត បាននាំឲ្យមានសកម្មភាពជាក់ស្តែងពីសំណាក់អ្នកតំណាងរាស្ត្រដែលបាន ចូលរួមដោយបានផ្តល់ផលប្រយោជន៍ដោយផ្ទាល់ទៅលើសហគមន៍ ដែលកិច្ចពិភាក្សាទាំងនេះ ត្រូវបានរៀបចំឡើង រួមមានដំណោះស្រាយលើជម្លោះដីធ្លី និងការបំពេញតម្រូវការផ្នែក ហេដ្ឋារចនាសម្ព័ន្ធ និងកសិកម្ម។




អ្នកតំណាងរាស្ត្រ ឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងដោយអ្នកចូលរួម នៅក្នុងកម្មវិធីកិច្ចពិភាក្សា រវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត នៅភូមិបុស្សតាអឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១១។ បុគ្គលិករបស់វិទ្យាស្ថានជាតិ NDI (ខាងស្តាំ) គឺជាអ្នកសម្របសម្រួលសម្រាប់ព្រឹត្តិការណ៍នេះ។

## II. ការសង្ខេបអំពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត[8]

ប្រជាពលរដ្ឋច្រើនជាង១១,០០០នាក់ (ជិត៥០% ជាស្ត្រី) និងអ្នកតំណាងរាស្ត្រ៣៥នាក់ (រួមមានស្ត្រី៧នាក់) បានចូលរួមវេទិកាកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ចំនួន២៤លើក នៅចន្លោះខែវិច្ឆិកា ឆ្នាំ២០១០ ដល់ខែកញ្ញា ឆ្នាំ២០១១។ នៅក្នុងខេត្តចំនួន១២ អ្នកចូលរួមកិច្ចពិភាក្សា បានលើកឡើងដូចៗគ្នាអំពីបញ្ហាចំនួន៣ ដែលបានប៉ះពាល់ដល់ជីវភាព របស់ពួកគេ៖ ជម្លោះដីធ្លី តម្រូវការហេដ្ឋារចនាសម្ព័ន្ធ និងធារាសាស្ត្រ ហើយនឹងអំពើពុករលួយ និងវិសមភាពក្នុងការអនុវត្តន៍ច្បាប់ដោយអាជ្ញាធរមូលដ្ឋាន។ វិសមភាព គឺជាប្រធានបទដ៏ សំខាន់នៃបញ្ហាទាំងនេះ ហើយអ្នកចូលរួមបានសម្តែងកង្វល់ថា អ្នកមានលុយ និងអ្នកមាន អំណាចទទួលបានអត្ថប្រយោជន៍ទាំងអស់ - ដីធ្លី ការអភិវឌ្ឍន៍ និងយុត្តិធម៌។ នៅក្នុងខេត្ត ទាំងអស់ ប្រជាពលរដ្ឋបានរាយការណ៍ថា ឥទ្ធិពលទឹកប្រាក់ប៉ះពាល់ខ្លាំងទៅលើគ្រប់ទិដ្ឋភាព នៃជីវភាពរបស់ពួកគេ និងយល់ថា ពួកគេកំពុងបាត់បង់ប្រទេសដោយសារក្រុមហ៊ុនបរទេស និងផលប្រយោជន៍ឯកជន។ អ្នកចូលរួមម្នាក់ បានរៀបរាប់អំពីគោលនយោបាយរបស់ រដ្ឋាភិបាលថា "តែងតែគាំទ្រអ្នកមានលុយ" ហើយបានសួរសំណួរថា "តើឈ្មួញដែលមានលុយ ត្រួតត្រារដ្ឋាភិបាល ឬរដ្ឋាភិបាលត្រួតត្រាឈ្មួញ?" ។

### ក. ជម្លោះដីធ្លី

ជាក់ស្តែងដីធ្លី គឺជាកង្វល់លេខមួយរបស់ប្រជាពលរដ្ឋហើយជម្លោះដីធ្លីដែលបានរាយការណ៍ មានចំនួនកាន់តែច្រើនជាងឆ្នាំមុនៗនៃកម្មវិធីទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនីមួយៗ អ្នកចូលរួមបានរៀបរាប់អំពីដី របស់ពួកគេ ឬដីរបស់អ្នកដទៃទៀតនៅក្នុងសហគមន៍របស់ពួកគេ ត្រូវបានដណ្តើមយកដោយ ក្រុមហ៊ុន ឬការសម្បទាន។ នៅក្នុងកិច្ចពិភាក្សាខ្លះ បញ្ហាពីរបីផ្សេងទៀត ត្រូវបានលើកយកមក ពិភាក្សា។ នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតលើកទីពីរ ដែលបានរៀបចំ ឡើងនៅក្នុងខេត្តកណ្តាល អ្នកចូលរួម១១នាក់ក្នុងចំណោមអ្នកចូលរួម១៤នាក់ ដែលបានសួរ សំណួរ បានលើកឡើងអំពីបញ្ហាដែលទាក់ទងទៅនឹងដីធ្លី។ នៅក្នុងកិច្ចពិភាក្សាលើកទីមួយនៅ ក្នុងខេត្តកំពង់ស្ពឺ អ្នកចូលរួម១៣នាក់ក្នុងចំណោមអ្នកចូលរួម១៦នាក់ ក៏ដូចជាអ្នកចូលរួមនៅ ក្នុងកិច្ចពិភាក្សាលើកទីមួយនៅខេត្តក្រចេះ អ្នកចូលរួម១៣នាក់ក្នុងចំណោមអ្នកចូលរួម១៦នាក់ ហើយនឹងនៅក្នុងកិច្ចពិភាក្សាលើកទីពីរនៅខេត្តក្រចេះ អ្នកចូលរួម៧នាក់ក្នុងចំណោមអ្នកចូលរួម ១០នាក់ សុទ្ធតែបានលើកឡើងអំពីបញ្ហាដីធ្លី។ អ្នកដែលបានឡើងនិយាយអំពីបញ្ហាដីធ្លី

---

[8] មតិយោបល់ដែលបានលើកឡើងដោយអ្នកចូលរួម និងអ្នកតំណាងរាស្ត្រដែលជាប់ឆ្នោត នៅក្នុងកំណត់ហេតុនៃកិច្ចពិភាក្សា រវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មិនឆ្លុះបញ្ចាំងអំពីកំណត់ហេតុនៃការប្រជុំរបស់វិទ្យាស្ថានជាតិ NDI ឡើយ។ របាយការណ៍នេះ សង្ខេបនូវមតិ កង្វល់ និងចំណាប់អារម្មណ៍របស់ពួកគេ។ របាយការណ៍ពេញលេញជាភាសាអង់គ្លេសនៃកិច្ចពិភាក្សានីមួយៗ អាចត្រូវបានផ្តល់ជូនតាមសំណើ។

បានរៀបរាប់អំពីការលំបាកផ្សេងៗដែលពួកគេបានជួបប្រទះក្នុងការកាន់កាប់ចលនទ្រព្យរបស់ខ្លួន ហើយបានរាយការណ៍ជាញឹកញាប់អំពីការពាក់ព័ន្ធអវិជ្ជមានរបស់អាជ្ញាធរមូលដ្ឋានក្នុងស្ថានភាពបែបនេះរបស់ពួកគេ។ នៅក្នុងករណីមួយចំនួន ប្រជាពលរដ្ឋ ត្រូវធ្វើដំណើរផ្លូវឆ្ងាយដើម្បីរាយការណ៍ជូនអ្នកតំណាងរាស្ត្ររបស់ខ្លួន ពីព្រោះទាំងអាជ្ញាធរនៅក្នុងសហគមន៍ទាំងតុលាការមិនបានជួយដោះស្រាយបញ្ហារបស់ពួកគេ។

អ្នកចូលរួមកិច្ចពិភាក្សា បានរិះគន់ចំពោះគោលនយោបាយសម្បទានរបស់រដ្ឋាភិបាល ហើយបានត្អូញត្អែរអំពីអំពើពុករលួយរបស់អាជ្ញាធរមូលដ្ឋាន និងតុលាការ ក្នុងករណីដីធ្លី និងនីតិវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដោយសារអំពើពុករលួយ និងឃឺតយ៉ាវ។ ជម្លោះដីធ្លីដែលអ្នកចូលរួមបានរៀបរាប់ ជាធម្មតាពាក់ព័ន្ធជាមួយក្រុមគ្រួសារប្រជាពលរដ្ឋដែលផ្លាស់ប្តូរទីលំនៅដោយសារការផ្តល់សម្បទានឲ្យក្រុមហ៊ុនឯកជន។ អ្នកចូលរួម បានចោទសួរនូវសំណួរដដែលៗអំពីគោលនយោបាយសម្បទានរបស់រដ្ឋាភិបាល ដោយទាមទារឲ្យមានការពន្យល់អំពីមូលហេតុដែលក្រុមហ៊ុនភាគច្រើនជាក្រុមហ៊ុនបរទេស ហាក់ដូចជាត្រូវបានគាំទ្រខ្លាំងជាងប្រជាពលរដ្ឋ។ ពួកគេក៏បានរិះគន់ផងដែរចំពោះចំនួនទឹកប្រាក់ដ៏តិចតួច ដែលក្រុមហ៊ុនបង់ឲ្យរដ្ឋាភិបាលសម្រាប់ការផ្តល់សម្បទានទាំងនោះ ដោយសម្តែងនូវឆន្ទៈផ្ទាល់របស់ពួកគេ ចង់បង់នូវចំនួនលុយដូចដែលក្រុមហ៊ុនបានបង់ឲ្យរដ្ឋាភិបាលដើម្បីទទួលបានដីសម្រាប់ធ្វើកសិកម្ម។ ពួកគេ បានបដិសេធចំពោះការអះអាងថា សម្បទានទាំងនេះបាននាំយកការងារមកឲ្យពលរដ្ឋខ្មែរធ្វើ ដោយគូសបញ្ជាក់ថាបុគ្គលិកថ្មីទាំងអស់របស់ក្រុមហ៊ុនទាំងនេះសុទ្ធតែជាជនបរទេស។ នៅក្នុងករណីជាច្រើន គ្រួសារជាច្រើន បានបញ្ជាក់ថាមានប័ណ្ណកម្មសិទ្ធិកាន់កាប់អចលនទ្រព្យផ្លូវការ ប៉ុន្តែ ពួកគេ ត្រូវបានបង្ខំឲ្យចាកចេញពីដីរបស់ខ្លួនដោយអ្នកមានអំណាចខ្លាំង ដោយមានការជួយជ្រោមជ្រែងពីមន្ត្រីមូលដ្ឋានដែលជាញឹកញាប់ គឺជានគរបាល ឬយោធា។ នៅក្នុងខេត្តមួយចំនួន ប្រជាពលរដ្ឋបានរៀបរាប់អំពីអំពើហិង្សារាប់បញ្ចូលទាំងការរុះរើផ្ទះសម្បែងរបស់ពួកគេ។ នៅក្នុងករណីផ្សេងទៀត ប្រជាពលរដ្ឋត្រូវបានបណ្តេញចេញពីដីរបស់ខ្លួនដោយមិនបានទទួលសំណងសមស្របពីរដ្ឋាភិបាល ឬក្រុមហ៊ុនពាក់ព័ន្ធឡើយ។ មិនតែប៉ុណ្ណោះ អ្នកចូលរួមកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតបានរៀបរាប់ដដែលៗអំពីការលំបាកក្នុងការទទួលបានប័ណ្ណសម្គាល់កម្មសិទ្ធិសម្រាប់អចលនទ្រព្យរបស់ពួកគេ ដោយសារការទារសំណូកពីសំណាក់មន្ត្រីមូលដ្ឋាន។




ស្ត្រីម្នាក់ លើកឡើងអំពីជម្លោះដីធ្លី រវាងក្រុមហ៊ុន ម៉េង តេក (Meng Tek) និងប្រជាពលរដ្ឋចំនួន៨៨ គ្រួសារ ក្នុងអំឡុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត នៅភូមិពោធិ៍ ឃុំដំណាក់រាំង ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១១។

នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ប្រជាពលរដ្ឋជាញឹកញាប់ ខឹងសម្បារ ថែមទាំងស្រែក និងទាមទារការឆ្លើយតបពីរដ្ឋាភិបាលអំពីការបែងចែកដីមិនយុត្តិធម៌ មិនមានតម្លាភាពក្នុងការផ្តល់ដីសម្បទាន និងមិនមានការឆ្លើយតបទៅនឹងភាពគ្មានដីរបស់ប្រជាពលរដ្ឋ។ អ្នកចូលរួមអះអាងថា ច្បាប់ភូមិបាលគ្មានប្រសិទ្ធភាព មិនត្រូវបានអនុវត្ត និងមានចំណុចខ្វះខាតច្រើន។ ប្រជាពលរដ្ឋម្នាក់នៅខេត្តកំពង់ស្ពឺ បានសួរសំណួរទាំងខឹងសម្បារថា "តើហេតុអ្វីបានជាប្រទេសចាំបាច់មានច្បាប់ភូមិបាល បើច្បាប់នោះ មិនត្រូវបានអនុវត្ត ហើយប្រជាពលរដ្ឋនៅតែបន្តទទួលរងការរំលោភបំពានពីសំណាក់អ្នកមានអំណាច?" គាត់ បានលើកឡើងថា វាគ្មានន័យអ្វីទេ បើសិនជាច្បាប់មាននៅតែលើក្រដាស ហើយមិនអនុវត្តនោះ ហើយបានផ្តល់អនុសាសន៍ថា ច្បាប់ភូមិបាលគួរតែត្រូវបានលុបចោល។ អ្នកចូលរួម ក៏បានសម្តែងការក្រេវក្រោធ នៅពេលបានឮមេដឹកនាំរដ្ឋាភិបាលគ្រប់កម្រិតច្រានចោលបញ្ហាដីធ្លី ដោយនិយាយថា រដ្ឋាភិបាល "អនុវត្តតាមច្បាប់" ដោយបដិសេធមិនដោះស្រាយចំណុចខ្វះខាតរបស់ច្បាប់ ឬកង្វះការអនុវត្តច្បាប់។ ប្រជាពលរដ្ឋបានរាយការណ៍ដដែលៗថា រដ្ឋាភិបាល និងតុលាការមិនបានជួយដោះស្រាយពួកគេទេ។ ប្រជាពលរដ្ឋម្នាក់នៅខេត្តកំពង់ស្ពឺបានលើកឡើងអំពីរដ្ឋធម្មនុញ្ញដើម្បីបង្ហាញថា រដ្ឋាភិបាលត្រូវតែទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ។ អ្នកចូលរួមបានរៀបរាប់ជាញឹកញាប់ថា ពួកគេ មិនបានដឹងអ្វីសោះ (ស្ថិតក្នុងភាពអន្ធការ) អំពីការផ្តល់ដីសម្បទាន ពីព្រោះ មន្ត្រីរដ្ឋាភិបាលមិនបានជូនដំណឹងដល់ពួកគេ

ហើយពួកគេមិនបានដឹងថា ដីរបស់ពួកគេត្រូវបានដកហូតរហូតទាល់តែគ្រឿងចក្រ (អាប៊ុល) ចូលមកឈូសឆាយ។

ជាទូទៅ អ្នកតំណាងរាស្ត្រដែលជាប់ឆ្នោតមកពីគណបក្សតែមួយ បានផ្តល់ចម្លើយឆ្លើយតបស្រដៀងគ្នាលើបញ្ហាដីធ្លី និងបានបង្ហាញអំពីវិន័យរបស់គណបក្ស ដោយប្រកាន់ខ្ជាប់នូវសារ និងគោលជំហរដែលបានឯកភាពរបស់គណបក្ស។ អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា បាននិយាយការពារគោលនយោបាយដីសម្បទានរបស់រដ្ឋាភិបាលដោយអះអាងថា សម្បទាន គឺជាការចាំបាច់សម្រាប់ការអភិវឌ្ឍន៍ប្រទេស។ ពួកគេ បានបញ្ជាក់ថាប្រទេសត្រូវតែសហការជាមួយវិស័យឯកជន និងជម្រុញការវិនិយោគតាមរយៈដីសម្បទានសេដ្ឋកិច្ច។ អ្នកតំណាងរាស្ត្រមួយចំនួន បានចំណាយពេលវេលាជាច្រើនអានច្បាប់ភូមិបាលដោយអះអាងថាបញ្ហាជាច្រើនបានកើតឡើងដោយសារប្រជាពលរដ្ឋមិនយល់ច្បាស់អំពីច្បាប់។ អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជាជាច្រើន បានបញ្ជាក់ដដែលៗថា កម្ពុជា គឺជាប្រទេស "នីតិរដ្ឋ" ហើយដីដែលបានដកហូត គឺត្រូវបានធ្វើឡើងស្របតាមច្បាប់។ ប៉ុន្តែ ពួកគេមិនបានដោះស្រាយបញ្ហាកង្វល់របស់ប្រជាពលរដ្ឋ ដែលទាក់ទងនឹងខ្លឹមសារច្បាប់ជាមុនឡើយ។ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានសង្កត់ធ្ងន់លើ "ដំណើរការជាប្រព័ន្ធ" ដែលត្រូវបានអនុវត្តសម្រាប់ការបណ្តេញចេញ និងគោលនយោបាយសម្រាប់ការទូទាត់សំណង។ ដូចអ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជានៅខេត្តកំពង់ឆ្នាំង បានថ្លែងថា រដ្ឋាភិបាលតែងតែស្វែងរកទីកន្លែងឲ្យប្រជាពលរដ្ឋរស់នៅ ដោយបន្ថែមថា ប្រសិនបើរដ្ឋាភិបាលធ្វើមិនបានសម្រេចជូនប្រជាពលរដ្ឋ ពួកគេ នឹងមិនបោះឆ្នោតឲ្យគណបក្សប្រជាជនកម្ពុជាទេ។




អ្នកចូលរួមម្នាក់ ថ្លែងថា ក្រុមហ៊ុនបរទេសមួយ បានរឹបអូសយកដីពីប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់គាត់។ កម្មវិធីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានរៀបចំធ្វើឡើងនៅក្នុងភូមិគោក ឃុំសង្កែសាទប ស្រុកឱរាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១១។

ខុសពីឆ្នាំមុនៗនៃកម្មវិធីទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ម្តងម្កាល ការឆ្លើយតបរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានលក្ខណៈការពារខ្លួន ហើយ អ្នកតំណាងរាស្ត្រមួយចំនួន បានសម្តែងការមិនពេញចិត្តចំពោះមតិរិះគន់របស់ប្រជាជនលើ គោលនយោបាយដីធ្លីរបស់រដ្ឋាភិបាល។ អ្នកតំណាងរាស្ត្រម្នាក់មកពីគណបក្សប្រជាជនកម្ពុជា ប្រចាំខេត្តកណ្តាលបានបដិសេធថា គ្មាននរណាម្នាក់បាត់បង់ដីធ្លីឡើយ។ នៅខេត្តកំពង់ស្ពឺ អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា បានឆ្លើយតបចំពោះបញ្ហាកង្វល់ដីធ្លីរបស់ អ្នកចូលរួម ដោយស្រែកខ្លាំងៗថា "ឥឡូវ ទើបរិះគន់ ហេតុអ្វីបានជាមិនរិះគន់នៅក្នុងរបប ប៉ុលពត? បើសិនជាហ៊ានរិះគន់នៅពេលនោះ យើងប្រហែលជាគ្មានរបបប៉ុលពតទេ!" ក្រោយ មក អ្នកតំណាងរាស្ត្ររូបនោះ បានបន្ថែមដោយគំរាមគំហែងថា ប្រជាពលរដ្ឋមាន "សិទ្ធិនិយាយ ប៉ុន្តែ ត្រូវប្រយ័ត្នចំពោះអ្វីដែលខ្លួនបាននិយាយផង"។ គាត់បានព្រមានប្រជាពលរដ្ឋថា ប្រសិន បើ ពួកគេរិះគន់នោះ នឹងមានសង្គ្រាមស៊ីវិលកើតឡើងម្តងទៀត។

អ្នកតំណាងរាស្ត្ររបស់គណបក្សប្រឆាំង បានរិះគន់ដីសម្បទាន ជាពិសេសដីសម្បទាន ដែលមានរយៈពេល៩៩ឆ្នាំ និងដីសម្បទានដែលផ្តល់ឲ្យក្រុមហ៊ុនបរទេស។ ពួកគេបានអះអាង ថា ដីគួរតែត្រូវបានរក្សាទុកសម្រាប់កសិករខ្មែរ។ អ្នកតំណាងរាស្ត្រ (គណបក្សប្រឆាំង) មួយ ចំនួនបាននិយាយថា ជាគោលការណ៍ ពួកគេយល់ស្របជាមួយផែនការគោលរបស់រាជរដ្ឋាភិបាល ស្តីពីការផ្តល់ដីសម្បទាន ប៉ុន្តែអះអាងថា ការផ្តល់ដីសម្បទានមិនបានគោរពតាមផែនការ ហើយ ប្រជាពលរដ្ឋខ្មែរ មិនបានទទួលផលប្រយោជន៍ពីដីសម្បទាន។ ពួកគេរិះគន់ថា ជាក់ស្តែង ក្រុមហ៊ុនមិនបានបង់ប្រាក់សម្រាប់ដីសម្បទាន ឬបង់ពន្ធ ដូចអ្នកតំណាងរាស្ត្រម្នាក់នៅ ខេត្តក្រចេះបានលើកឡើងថា "ប្រជាពលរដ្ឋនៅតែក្រីក្រ រដ្ឋាភិបាលនៅតែក្រីក្រដដែល ប៉ុន្តែ ក្រុមហ៊ុនក្លាយជាអ្នកមានស្តុកស្តម្ភ" ។ គាត់បានសួរថា តើហេតុអ្វីបានជាប្រជាពលរដ្ឋខ្មែរ មិន ត្រូវបានផ្តល់ឱកាសឲ្យបង់តម្លៃសម្រាប់ដីសម្បទាន ដូចក្រុមហ៊ុនទាំងនោះ។ អ្នកតំណាងរាស្ត្រ របស់គណបក្សប្រឆាំងជាច្រើន ក៏បានចង្អុលបង្ហាញផងដែរថា ក្រុមហ៊ុនថៃមទាំងមិនបានជួល កម្មករខ្មែរឲ្យធ្វើការផង។ អ្នកតំណាងរាស្ត្ររបស់គណបក្ស សម រង្ស៊ី មួយរូបនៅខេត្តកណ្តាល បានមានប្រសាសន៍ថា ការរឹបអូសយកដីធ្លីដោយក្រុមហ៊ុន ក្នុងនាមអភិវឌ្ឍន៍កំពុងធ្វើឲ្យ ប្រជាពលរដ្ឋភ័យខ្លាចចំពោះការអភិវឌ្ឍន៍ ។



អ្នកចូលរួមម្នាក់លើកឡើងអំពីកង្វល់ដែលទាក់ទងនឹងរយៈពេលនៃការផ្តល់ដីសម្បទាន ដែលបានផ្តល់ឲ្យក្រុមហ៊ុនឯកជន ដោយរដ្ឋាភិបាលកម្ពុជា។ វេទិកាកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានធ្វើឡើងនៅក្នុងភូមិវត្ត ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១១។

អ្នកតំណាងរាស្ត្ររបស់គណបក្សប្រឆាំងជាច្រើន បានអធិប្បាយអំពីអំពើពុករលួយដែលចាក់ឫសកើតមាននៅគ្រប់ទិដ្ឋភាពនៃកម្មសិទ្ធិដីធ្លី ការផ្តល់ប័ណ្ណសម្គាល់កម្មសិទ្ធិ និងដំណើរការបែងចែកដីសម្បទាន។ ពួកគេបានរាយការណ៍ថា កិច្ចសន្យាដីធ្លីជាច្រើននៅក្នុងប្រទេស ត្រូវបានធ្វើឡើងដោយខុសច្បាប់ ហើយអាជ្ញាធរមូលដ្ឋាន ជាញឹកញាប់បាននិយាយកុហកមេដឹកនាំនៅថ្នាក់ជាតិ ដើម្បីផលប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ខ្លួន។ គណបក្សប្រឆាំង ក៏បានចោទប្រកាន់ផងដែរថា កសិករក្រីក្រមិនអាចទទួលបានយុត្តិធម៌នៅក្នុងតុលាការ ឬដំណោះស្រាយតាមរយៈរដ្ឋបាលមូលដ្ឋាន ប្រសិនបើ ពួកគេមានជម្លោះជាមួយអ្នកមានលុយ និងអ្នកមានអំណាចលើបញ្ហាដីធ្លី។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងបានបញ្ជាក់ថា ប្រជាពលរដ្ឋជាច្រើន ពុំមានប័ណ្ណសម្គាល់កម្មសិទ្ធិកាន់កាប់ដីធ្លី ហើយត្រូវបានទាមទារសំណូកដោយអាជ្ញាធរមូលដ្ឋាន ប្រសិនបើ ពួកគេសុំប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនទ្រព្យ។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង បានផ្តល់អនុសាសន៍ថា ការចេញប័ណ្ណសម្គាល់កម្មសិទ្ធិកាន់កាប់ដីធ្លី គួរតែត្រូវបានពន្លឿន និងអនុវត្តដោយគ្មានអំពើពុករលួយ។ ពួកគេ បានជំរុញឲ្យអ្នកដែលមិនពេញចិត្តនឹងគោលនយោបាយដីធ្លីរបស់ប្រទេស បោះឆ្នោតជ្រើសរើសអ្នកដឹកនាំផ្សេង។

## ខ. ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍

ក្រៅពីជម្លោះដីធ្លីដែលប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋ អ្នកចូលរួមបានរៀបរាប់អំពីហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រមិនល្អធ្វើឲ្យពួកគេកាន់តែក្រីក្រថែមទៀត។ សំណូមពរផ្លូវថ្នល់ ទំនប់ទឹក និងអគ្គិសនីមានច្រើនលើសលប់។ នៅក្នុងកិច្ចពិភាក្សាលើកទីពីរ

នៅខេត្តសៀមរាប អ្នកមានមតិ១១នាក់ក្នុងចំណោមអ្នកមានមតិសរុប១៥នាក់ បានស្នើសុំឲ្យមានហេដ្ឋារចនាសម្ព័ន្ធដែលល្អប្រសើរ និងគម្រោងធារាសាស្ត្រថែមទៀត។ អ្នកចូលរួមនៅក្នុងខេត្តចំនួន១២ ក៏បានត្អូញត្អែរអំពីការធ្លាក់ចុះនៃតម្លៃផលិតផលកសិកម្មរបស់កម្ពុជា និងកង្វះទីផ្សារសម្រាប់ផលិតផលរបស់ពួកគេផងដែរ។ អ្នកចូលរួមជាច្រើន បានស្នើសុំឲ្យអ្នកតំណាងរាស្ត្រពន្យល់អំពីគោលនយោបាយកសិកម្ម និងការអភិវឌ្ឍន៍ជាក់លាក់របស់គណបក្សពួកគេ។ អ្នកចូលរួមពីរបីនាក់ចង់យល់ដឹងឲ្យបានច្បាស់ថា តើថវិកាសម្រាប់អភិវឌ្ឍន៍បានមកពីណា។ អ្នកចូលរួមម្នាក់នៅខេត្តតាកែវ បានកត់សំគាល់អំពីឈ្មោះរបស់បុគ្គលនៅលើគម្រោងអភិវឌ្ឍន៍ ហើយសួរថា តើថវិកានោះពិតជាបានមកពីបុគ្គលទាំងនោះមែនឬទេ ។

នៅក្នុងបរិបទនេះ នៅក្នុងវេទិកាកិច្ចពិភាក្សាមួយចំនួន អ្នកចូលរួមបានរិះគន់គណបក្សសម រង្ស៊ី និងការខកខានរបស់គណបក្សនេះ ក្នុងការ "ផ្តល់ការអភិវឌ្ឍន៍" ហើយលើកសរសើរអំពីគណបក្សប្រជាជនកម្ពុជាចំពោះការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដល់ប្រជាជន។ ឧទាហរណ៍នៅក្នុងកិច្ចពិភាក្សាលើកទីពីរនៅខេត្តកំពង់ធំ អ្នកចូលរួមជាច្រើនបានអានសុន្ទរកថាដែលបានត្រៀមទុកអំពីការរួមវិភាគទានរបស់គណបក្សប្រជាជនកម្ពុជា ហើយទំនងជាត្រូវបានគេណែនាំឲ្យឡើងនិយាយ។ នៅក្នុងវេទិកាកិច្ចពិភាក្សាលើកទីមួយនៅខេត្តកំពត អ្នកចូលរួម១០នាក់ក្នុងចំណោមអ្នកចូលរួមសរុប១៨នាក់ បានប្រើប្រាស់ពេលវេលានិយាយរបស់ពួកគេ ដើម្បីរិះគន់គណបក្សប្រឆាំង និងនៅក្នុងកិច្ចពិភាក្សាលើកទីពីរនៅក្នុងខេត្តកំពតដដែល អ្នកចូលរួម៧នាក់ក្នុងចំណោមអ្នកចូលរួមសរុប១០នាក់ ក៏បានលើកឡើងដូចគ្នាដែរ។ អ្នកចូលរួមភាគច្រើនបានសួរថា តើហេតុអ្វីបានជាគណបក្ស សម រង្ស៊ី មិនបានផ្តល់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ឬអនុវត្តសកម្មភាពអភិវឌ្ឍន៍ណាមួយសម្រាប់ប្រជាពលរដ្ឋ។

ជាទូទៅ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានឆ្លើយតបប្រកបដោយស៊ីសង្វាក់គ្នាចំពោះកង្វល់អំពីកសិកម្ម និងការអភិវឌ្ឍន៍។ អ្នកតំណាងរាស្ត្រជាច្រើននៃគណបក្សប្រជាជនកម្ពុជា ជាដំបូង បានចង្អុលបង្ហាញអំពីរបៀបដែលប្រទេសត្រូវបានអភិវឌ្ឍន៍កាន់តែរីកចម្រើន និងល្អប្រសើរជាងរបបប៉ុលពត ហើយដូច្នេះ ប្រជាពលរដ្ឋ គួរតែសរសើរគណបក្សប្រជាជនកម្ពុជា ដែលបាន "កសាងប្រទេសតាំងពីដៃទទេ"។ ជាញឹកញាប់ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានរៀបរាប់ពីចំនួនសាលារៀន មណ្ឌលសុខភាព ឬក៏ម៉ូតូនៅក្នុងតំបន់នោះ ដើម្បីបង្ហាញអំពីសមិទ្ធផលទាំងនោះដោយប្រើប្រាស់ពាក្យ "គណបក្សប្រជាជនកម្ពុជា និងរដ្ឋាភិបាល" ជាញឹកញាប់។ ជាមួយគ្នានេះដែរ ពួកគេក៏បានលើកឡើងដដែលៗថា ប្រជាពលរដ្ឋត្រូវអត់ធ្មត់ ដោយដកស្រង់នូវអនុសាសន៍របស់នាយករដ្ឋមន្ត្រីថា "ការអភិវឌ្ឍន៍បែបជំហានតីង្គក់" (យឺតៗ) ហើយបានប្រកាសថា វាមិនត្រឹមត្រូវទេក្នុងការដែលប្រៀបធៀបកម្ពុជាជាមួយបច្ចឹមប្រទេសនោះ។ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាជាច្រើន បានប្រាប់ប្រជាពលរដ្ឋឲ្យ "ខិតខំប្រឹងប្រែងធ្វើការ" ដើម្បីបង្កើនជីវភាពរបស់ខ្លួន។




អ្នកចូលរួម សួរសំណួរអំពីទំនិញឡើងថ្លៃលើទីផ្សារ និងការថែទាំសុខភាពមិនល្អនៅក្នុងសហគមន៍របស់គាត់ នៅកម្មវិធីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត នៅភូមិតាំងត្រពាំង ឃុំពេជ្រចង្វារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១១។

អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាចជាច្រើន បានរៀបរាប់អំពីគោលនយោបាយជាក់លាក់របស់ប្រទេសដោយរាយការណ៍ថា ប្រទេសកម្ពុជា នឹង "បូមយកប្រេង" នៅឆ្នាំ២០១២ ហើយតម្លៃអគ្គិសនី នឹងចុះថោកនៅក្នុងឆ្នាំ២០១៣ដោយសារគម្រោងទំនប់វារីអគ្គិសនី។ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាជាច្រើន បានពន្យល់អំពីផែនការរបស់រាជរដ្ឋាភិបាលក្នុងការនាំចេញអង្កររាប់លានតោនក្នុងមួយឆ្នាំៗ និងកិច្ចប្រឹងប្រែងក្នុងការលើកទឹកចិត្តពាណិជ្ជករថៃ ឲ្យទិញ និងដឹកជញ្ជូនអង្ករ។ ក្នុងការឆ្លើយតបទៅនឹងការត្អូញត្អែរអំពីតម្លៃទំនិញ អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា បានពន្យល់ថា កម្ពុជាប្រកាន់នូវគោលការណ៍ទីផ្សារសេរី និងប្រាប់ប្រជាពលរដ្ឋមិនឲ្យលក់ទំនិញរបស់ពួកគេ ប្រសិនបើតម្លៃធ្លាក់ចុះទាបពេក។ អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាច បានជម្រុញប្រជាពលរដ្ឋឲ្យចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ ដើម្បីជួយកំណត់អាទិភាពនៃការអភិវឌ្ឍន៍។



អ្នកចូលរួមម្នាក់ សួរអ្នកតំណាងរាស្ត្រថា តើសមិទ្ធផលទាំងអស់របស់ប្រទេស រាប់បញ្ចូលស្ពាន សាលារៀន ផ្លូវថ្នល់ និងមន្ទីរពេទ្យថ្មី ត្រូវបានកសាងដោយរដ្ឋាភិបាល ឬគណបក្សប្រជាជនកម្ពុជា។ កម្មវិធីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត នៅភូមិតារាជ ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្តកំពត កាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១១។

ក្នុងការឆ្លើយតបទៅនឹងសំណួរអំពីការដាក់ឈ្មោះរបស់បុគ្គល ឬគណបក្សនយោបាយលើគម្រោងនានា អ្នកតំណាងរាស្ត្រម្នាក់នៅខេត្តតាកែវ បានពន្យល់ថា ម្ចាស់ជំនួយបានស្នើសុំឲ្យដាក់ឈ្មោះរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លើជំនួយរបស់ពួកគេ ពីព្រោះ "បើសិនជាគ្មាន ហ៊ុន សែន នោះនឹងមិនមានសន្តិភាព ឬស្ថិរភាពឡើយ"។ អ្នកតំណាងរាស្ត្រម្នាក់ទៀតរបស់គណបក្សប្រជាជននៅក្នុងខេត្តកំពត បានអះអាងថា ការអភិវឌ្ឍន៍ទាំងអស់បានមកពីគណបក្សប្រជាជនកម្ពុជាផ្ទាល់ មិនមែនបានមកពីថវិការបស់រដ្ឋាភិបាលទេ រួមមានសាលារៀន និងហេដ្ឋារចនាសម្ព័ន្ធ។ ដូចគ្នានេះដែរ អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជន ជាញឹកញាប់បានប្រើប្រាស់ឃ្លានេះថា "គណបក្សមួយ គឺជាអ្នកធ្វើ ចំណែកឯគណបក្សមួយទៀត គឺជាអ្នកថា"។

អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី និងអ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានពន្យល់ថា គណបក្សនយោបាយដែលឈ្នះនៅក្នុងការបោះឆ្នោត បង្កើតរដ្ឋាភិបាល និងមានលទ្ធភាពក្នុងការកំណត់ និងត្រួតត្រាការចំណាយលើការអភិវឌ្ឍន៍សម្រាប់ប្រទេស។ ពួកគេបានសង្កត់ធ្ងន់ថា ពួកគេ មិនមានអំណាចគ្រប់គ្រងលើថវិកា ឬផែនការទេ ដូច្នេះហើយ ពួកគេមិនអាចផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍ផ្សេងទៀតបានឡើយ។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងបានពន្យល់ថា បើសិនជាប្រជាពលរដ្ឋបោះឆ្នោតគាំទ្រគណបក្សប្រឆាំង ពួកគេនឹងបង្កើតរដ្ឋាភិបាល ហើយអាចអនុវត្តគម្រោងអភិវឌ្ឍន៍ និងហេដ្ឋារចនាសម្ព័ន្ធ។

អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី មួយចំនួន បានបញ្ជាក់ថា ទោះបីជាគណបក្សមានសំលេងភាគតិចនៅក្នុងរដ្ឋសភាក៏ដោយ ក៏គណបក្ស សម រង្ស៊ី នៅតែអាចតំណាងឲ្យប្រជាពលរដ្ឋ និងទទួលយកកង្វល់ និងសំណូមពររបស់ប្រជាពលរដ្ឋទៅជូនរដ្ឋាភិបាលដែរ។

អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង បានរៀបរាប់អំពីចំនួនប្រាក់ជំនួយ និងប្រាក់កម្ចីពីម្ចាស់ជំនួយជាច្រើនសម្រាប់ការអភិវឌ្ឍន៍ ដោយពន្យល់ថា ថវិកានេះត្រូវបានផ្តល់ឲ្យរដ្ឋាភិបាល មិនមែនផ្តល់ឲ្យគណបក្សនយោបាយទេ។ ពួកគេ បានសង្កត់ធ្ងន់អំពីបន្ទុករបស់បំណុលទៅលើសេដ្ឋកិច្ចរបស់ប្រទេស។ ទាក់ទងនឹងឈ្មោះរបស់បុគ្គល និងគណបក្សនយោបាយលើគម្រោងអភិវឌ្ឍន៍ គណបក្សប្រឆាំងបានពន្យល់ថា ការអភិវឌ្ឍន៍ត្រូវបានផ្តល់មូលនិធិដោយរាជរដ្ឋាភិបាលតាមរយៈជំនួយ និងពន្ធ មិនមែនដោយគណបក្សប្រជាជនកម្ពុជា ឬនាយករដ្ឋមន្ត្រីទេ។ ដូចអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ដែលចូលរួមក្នុងកិច្ចពិភាក្សាលើកទីពីរនៅខេត្តកំពង់ធំ បានមានប្រសាសន៍ថា "ខ្ញុំមិនដឹងថា តើហេតុអ្វីបានជាគណបក្សប្រជាជនកម្ពុជាដាក់ឈ្មោះរបស់ខ្លួន ឬឈ្មោះរបស់នាយករដ្ឋមន្ត្រីនៅលើគម្រោងទាំងនោះទេ នៅពេលដែលគម្រោងទាំងនោះជាថវិការបស់រដ្ឋាភិបាលនោះ" ដោយរំលឹកប្រជាពលរដ្ឋថា នាយករដ្ឋមន្ត្រីមានចំណូលតែ ១,៨០០ដុល្លារ ក្នុងមួយខែប៉ុណ្ណោះ។

អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងមួយចំនួន បានឆ្លើយតបទៅនឹងការប្រៀបធៀបដដែលៗរបស់គណបក្សប្រជាជនកម្ពុជាលើស្ថានភាពបច្ចុប្បន្នរបស់ប្រជាពលរដ្ឋខ្មែរ ទៅនឹងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ដោយលើកឡើងថា វាមិនមែនជាម៉ែត្រសម្រាប់វាស់ដ៏ជាក់លាក់សម្រាប់ប្រើដើម្បីវាស់វែងការអភិវឌ្ឍន៍បច្ចុប្បន្នទេ។ នៅក្នុងវេទិកាកិច្ចពិភាក្សាលើកទីពីរនៅខេត្តកំពង់ធំ អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី បានទទួលស្គាល់ថា កម្ពុជាពិតជាបានប្រសើរជាងឆ្នាំ១៩៧៩ ហើយក៏បានឯកភាពផងដែរថា វាមិនត្រឹមត្រូវទេដែលត្រូវប្រៀបធៀបកម្ពុជាជាមួយសហរដ្ឋអាមេរិកនោះ។ តែផ្ទុយទៅវិញ គាត់ចោទសួរថា ហេតុអ្វីបានជាយើងមិនប្រៀបធៀបប្រទេសយើងជាមួយប្រទេសជិតខាង ដូចជា ថៃ និងវៀតណាម។ គាត់បានអះអាងថា ដោយសារភាពក្រីក្រនៅក្នុងប្រទេស វាជារឿងធម្មតាទេ ដែលប្រជាពលរដ្ឋរំពឹងចង់បានច្រើននោះ។

គណបក្ស សម រង្ស៊ី រៀបរាប់អំពី "ផលប៉ះពាល់អវិជ្ជមាននៃការអភិវឌ្ឍន៍មិនសមស្រប" និងស្នើសុំឲ្យពង្រីកទីផ្សារ តាមរយៈការកែលំអនៃគោលនយោបាយកសិកម្មរបស់ប្រទេស។ អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី បានពន្យល់ដដែលៗថា គណបក្សរបស់ពួកគេ បានស្នើសុំឲ្យបង្កើនខ្ទង់ថវិកាសម្រាប់វិស័យកសិកម្ម អប់រំ និងសុខាភិបាល។ ពួកគេ ក៏បានស្នើសុំឲ្យរដ្ឋាភិបាលធ្វើអន្តរាគមន៍ចំពោះការកំណត់តម្លៃទីផ្សារសេរី ដោយផ្តល់ឧបត្ថម្ភលើតម្លៃប្រេង និងសម្ភារៈកសិកម្មផ្សេងទៀត ព្រមទាំងកំណត់តម្លៃខ្ពស់ជាងតម្លៃបច្ចុប្បន្នសម្រាប់ស្រូវ/អង្ករ។

លើសពីនេះទៀត ពួកគេ បានសង្កត់ធ្ងន់លើសំណើរបស់ពួកគេ ឲ្យបង្កើនការបណ្តុះបណ្តាល និងបច្ចេកវិជ្ជាសម្រាប់កសិករដើម្បីបង្កើនទិន្នផល។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង ជម្រុញលើកទឹកចិត្តប្រជាពលរដ្ឋឲ្យចូលរួមក្នុងការអភិវឌ្ឍន៍ប្រទេស និងជួយពិនិត្យតាមដានការចំណាយរបស់រដ្ឋាភិបាល។

## គ. អំពើពុករលួយ

បញ្ហាសំខាន់ទីបីដែលបានលើកឡើងនៅក្នុងវេទិកាកិច្ចពិភាក្សានេះ ពាក់ព័ន្ធនឹងអំពើពុករលួយ និងការអនុវត្តន៍ច្បាប់មិនស្មើគ្នានៅថ្នាក់មូលដ្ឋាន។ អ្នកចូលរួមក្នុងវេទិកាកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានរៀបរាប់អំពីករណីនានាដែលអាជ្ញាធរបានទាមទារសំណូកសម្រាប់ការផ្តល់សេវាផ្សេងៗដូចជាសៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណជាតិខ្មែរ បង្កើតប៉ុស្តិ៍ត្រួតពិនិត្យខុសច្បាប់ សម្លុតទារលុយ ឬអនុវត្តច្បាប់មិនស្មើគ្នា អាស្រ័យទៅតាមទ្រព្យសម្បត្តិ និងអំណាចរបស់បុគ្គលដែលពាក់ព័ន្ធ។ អ្នកចូលរួម ជាញឹកញាប់ បានរៀបរាប់អំពីការរើសអើងលើអ្នកក្រីក្រទាក់ទងនឹងកិច្ចការយុត្តិធម៌ និងភាពអស់សង្ឃឹមក្នុងការដាក់ពាក្យបណ្តឹងទៅតុលាការ។ នៅក្នុងវេទិកាកិច្ចពិភាក្សាលើកទីមួយនៅខេត្តក្រចេះ អ្នកចូលរួមម្នាក់បានអានមាត្រា៣១នៃរដ្ឋធម្មនុញ្ញ ដែលផ្តល់ភាពស្មើគ្នាចំពោះមុខច្បាប់ ហើយបានសួរអ្នកតំណាងរាស្ត្រថា តើពួកគេគិតថា វាមានពិតដែរឬទេ។ ប្រជាពលរដ្ឋ ក៏បានលើកឡើងនូវកង្វល់ទាក់ទងនឹងការចាត់ចែងការងារបោះឆ្នោតរបស់អាជ្ញាធរមូលដ្ឋាន រាប់បញ្ចូលទាំងការសូកប៉ាន់សម្រាប់ការធ្វើអត្តសញ្ញាណប័ណ្ណដែលចាំបាច់សម្រាប់ការបោះឆ្នោត ការប្រើប្រាស់ទម្រង់១០១៨ (ជំនួសអត្តសញ្ញាណប័ណ្ណ) និងការទិញសន្លឹកឆ្នោត។

ជារួម អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា មិនបានឆ្លើយតបលំអិតទៅនឹងការត្អូញត្អែរទាំងអស់នេះទេ ក្រៅពីនិយាយថា សកម្មភាពបែបនេះខុសច្បាប់ និងកម្រកើតមានគោលការណ៍នីតិរដ្ឋត្រូវបានអនុវត្តដោយត្រឹមត្រូវទូទាំងប្រទេស ហើយតុលាការ គឺឯករាជ្យ និងមិនពុករលួយ។ អ្នកតំណាងរាស្ត្រម្នាក់របស់គណបក្សប្រជាជនកម្ពុជាមកពីមណ្ឌលកណ្តាល បានបញ្ជាក់ដោយសង្កត់ធ្ងន់ថា "គ្មានអំពើពុករលួយនៅក្នុងប្រទេសកម្ពុជាទេ"។ អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាចមួយចំនួន បានឆ្លើយតបទៅនឹងការរិះគន់អំពីអំពើពុករលួយ ដោយពន្យល់ថា ដូចអ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជានៅក្នុងកិច្ចពិភាក្សាលើកទីពីរនៅខេត្តបន្ទាយ-មានជ័យបានមានប្រសាសន៍ថា "អ្នកធ្វើតែងតែខុស តែអ្នកមិនធ្វើមិនដែលខុសទេ"។ ពួកគេបានជំរុញឲ្យប្រជាពលរដ្ឋដាក់ពាក្យបណ្តឹងទៅអង្គភាពប្រឆាំងអំពើពុករលួយ។ ចំពោះកង្វល់ទាក់ទងនឹងការបោះឆ្នោត អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានរាយការណ៍ថា ប្រជាពលរដ្ឋត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់អត្តសញ្ញាណប័ណ្ណដែលផុតកំណត់ការប្រើប្រាស់ការបោះឆ្នោតពេលខាងមុខ។ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា នៅក្នុងកិច្ចពិភាក្សាលើកទីមួយនៅខេត្តកំពង់ឆ្នាំង បានឆ្លើយតបថា ការទិញសន្លឹកឆ្នោត "គឺជាអំពើស្របច្បាប់"។

អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង បានឯកភាពជាមួយកង្វល់របស់អ្នកចូលរួម និង លើកឡើងអំពីតម្រូវការឲ្យមានចំណាត់ការតឹងរឹងប្រឆាំងនឹងអំពើពុករលួយ និងធ្វើឲ្យមាន ស្ថាប័នតុលាការឯករាជ្យ។ អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សនៅក្នុងកិច្ចពិភាក្សាលើកទីពីរ នៅខេត្តកណ្តាល បានរាយការណ៍ថា ប្រទេសកម្ពុជាស្ថិតនៅចំណាត់ថ្នាក់លេខ១៥៤ នៅក្នុង ពិភពលោកអំពីអំពើពុករលួយ ហើយថវិការាប់រយលានដុល្លារត្រូវបានបាត់បង់ជារៀងរាល់ឆ្នាំ។ ឆ្លើយតបទៅនឹងសំណួរនៅក្នុងកិច្ចពិភាក្សាលើកទីមួយនៅខេត្តក្រចេះអំពីថា តើប្រជាពលរដ្ឋ មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ដែរឬទេ អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី បានអះអាងថា ច្បាប់នៅកម្ពុជាមានលក្ខណៈល្អ ប៉ុន្តែ មិនបានអនុវត្ត។ គាត់បានពន្យល់ថា ច្បាប់ដែលមាន ពិតប្រាកដនៅកម្ពុជា គឺថា "អ្នកធំមិនដែលខុសទេ ហើយបើអ្នកធំធ្វើខុស សូមមើលមាត្រា១"។ ជាឧទាហរណ៍ គាត់បានបកស្រាយថា អ្នកមានឥទ្ធិពលអាចកាប់ឈើដោយមិនមានទោស ប៉ុន្តែ បើអ្នកក្រីក្រកាប់ គាត់នឹងត្រូវបានចាប់ខ្លួន។ គណបក្សប្រឆាំងបានដាក់ចេញនូវអនុសាសន៍ មួយចំនួនដើម្បីដោះស្រាយបញ្ហានៃស្ថាប័នតុលាការ ដូចជា ត្រូវហាមប្រាមមិនឲ្យចៅក្រមចូល ជាសមាជិកគណបក្សនយោបាយ។

## ឃ. បញ្ហាផ្សេងៗ

បញ្ហាប្រកាន់បក្សពួក បានលេចឡើងនៅក្នុងអំឡុងពេលកិច្ចពិភាក្សាមួយចំនួន ជា ធម្មតា បញ្ហាទាំងនោះទាក់ទងនឹងការពិភាក្សាដេញដោលគ្នាអំពីកាលបរិច្ឆេទសមស្រប ដើម្បី ប្រារព្ធថ្ងៃឯករាជ្យរបស់ប្រទេស ឬបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម។ ដូចបានលើកឡើង ខាងលើក្នុងអំឡុងពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតមួយចំនួន អ្នកចូលរួម បានសម្តែងនូវការរិះគន់ខ្លាំងៗទៅលើគណបក្ស សម រង្ស៊ី ដែលមិនបានផ្តល់"ការអភិវឌ្ឍន៍" ឧទាហរណ៍ ផ្តល់សេវាដែលជាធម្មតាផ្តល់ឲ្យដោយរដ្ឋាភិបាល។ អ្នកតំណាងរាស្ត្រ បានឈ្លោះ ប្រកែកគ្នាដោយពាក្យសម្តីម្តងម្កាល ដោយអ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា អះអាងដដែលៗថា គណបក្សប្រឆាំងមានសមត្ថភាពត្រឹមតែរិះគន់រដ្ឋាភិបាលប៉ុណ្ណោះ ប៉ុន្តែ ក្រៅពីនេះ គណបក្សនេះមិនបានធ្វើអ្វីឡើយ។ ដូចអ្នកតំណាងរាស្ត្រម្នាក់នៅខេត្តកណ្តាល បានមានប្រសាសន៍ថា "ឆ្កែចេះតែព្រុស មនុស្សចេះតែដើរ" ។ អ្នកតំណាងរាស្ត្រម្នាក់របស់ គណបក្សប្រជាជនកម្ពុជានៅក្នុងកិច្ចពិភាក្សាលើកទីពីរនៅខេត្តសៀមរាប បានលើកឡើងថា គណបក្សប្រឆាំងគ្មានហេតុផលទេ ហើយប្រជាពលរដ្ឋមិនគួរស្តាប់តាម "ការញ៉ុះញ៉ង់"ឡើយ។ អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជានៅខេត្តកំពង់ស្ពឺ បានសួរថា តើ "អ្នករិះគន់ ទាំងនោះរស់នៅនៅឯណានៅក្នុងរបបប៉ុលពត?"។ អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាច នៅតែបន្តរំលឹកប្រជាពលរដ្ឋថា គណបក្សប្រឆាំងរិះគន់កាន់តែខ្លាំង គណបក្សប្រជាជនកម្ពុជា នឹងទទួលបានសំលេងឆ្នោតកាន់តែច្រើន។ អ្នកតំណាងរាស្ត្ររបស់គណបក្សប្រឆាំងបានទទួល ស្គាល់ថា ដោយសារគណបក្ស សម រង្ស៊ី មានសម្លេងភាគតិចក្នុងសភា គណបក្សអាចត្រឹមតែ

"និយាយ" មិនអាចចាត់ការលើគោលនយោបាយរបស់រដ្ឋាភិបាលឡើយ។ អ្នកតំណាងរាស្ត្រម្នាក់របស់គណបក្សសិទ្ធិមនុស្ស បានសម្របតាមការប្រៀបធៀបថាជាឆ្កែព្រុស ដោយលើកឡើងថា ឆ្កែព្រុសតែពួកចោរ និងអ្នកដើរយប់ប៉ុណ្ណោះ" ។

នៅក្នុងសហគមន៍ជាច្រើន មន្ត្រីមូលដ្ឋានបានបង្កឧបសគ្គដល់ការរៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត និងបង្កបញ្ហាជាច្រើននៅក្នុងអំឡុងពេលកិច្ចពិភាក្សាផ្ទាល់។ ក្នុងករណីខ្លះ ពួកគេ បានទាមទារសំណូកពីអង្គការដៃគូក្នុងស្រុករបស់វិទ្យាស្ថានជាតិ NDI ដើម្បីរៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ឬព្យាយាមរារាំងប្រជាពលរដ្ឋមិនឲ្យចូលរួមព្រឹត្តិការណ៍នេះ។ ទោះជាយ៉ាងណាក្តី ប្រជាពលរដ្ឋសហគមន៍ បានបង្ហាញនូវភាពអង់អាចរបស់ពួកគេ ដោយបានចូលរួមនៅក្នុងកិច្ចពិភាក្សានេះ។ នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតលើកទីមួយនៅក្នុងខេត្តកំពត កងរាជអាវុធហត្ថ បានឡោមព័ទ្ធវេទិកាពិភាក្សា។ អ្នកភូមិ បានរាយការណ៍ថា អាជ្ញាធរមូលដ្ឋានបានអះអាងថា មានតែប្រជាពលរដ្ឋដែលត្រូវបានអញ្ជើញដោយអាជ្ញាធរមូលដ្ឋានផ្ទាល់ ទើបអាចចូលរួមនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនេះបាន ទោះបីជា កិច្ចពិភាក្សាទាំងនេះបើកចំហចំពោះប្រជាពលរដ្ឋគ្រប់រូបក៏ដោយ។ បន្ទាប់កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតលើកទីពីរនៅក្នុងខេត្តកំពត អ្នកចូលរួម៣នាក់ដែលបានលើកឡើងអំពីបញ្ហាដីធ្លីត្រូវបានកោះហៅដោយឡែកៗពីគ្នាទៅកាន់ការិយាល័យស្រុក ដើម្បីពន្យល់ពីសកម្មភាពរបស់ពួកគេជូនអភិបាលស្រុក។ ពួកគេត្រូវបានសាកសួរថា តើហេតុអ្វីបានជាពួកគេរិះគន់រដ្ឋាភិបាលនៅក្នុងវេទិកាកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ហើយពួកគេទាំង៣នាក់បានរាយការណ៍ថា ពួកគេមានអារម្មណ៍ថាត្រូវបានគេគំរាមគំហែង។ ស្ត្រីម្នាក់ទៀតដែលបានលើកឡើងអំពីកង្វល់នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ត្រូវបានគេតាមដល់ផ្ទះរបស់នាង បន្ទាប់ពីកិច្ចពិភាក្សានោះហើយបានទទួលការគំរាមគំហែងពីបុរសមិនស្គាល់អត្តសញ្ញាណម្នាក់ដែលបានសួរគាត់ថា ហេតុអ្វីបានជាគាត់និយាយនៅក្នុងកិច្ចពិភាក្សា។

តាមសំណូមពររបស់គណបក្សនយោបាយ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១០ វិទ្យាស្ថានជាតិ NDI បានកែសម្រួលកម្មវិធីទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដើម្បីទុកពេលឲ្យមន្ត្រីមូលដ្ឋានមានមតិ។ មន្ត្រីដែលបានមានមតិជារឿយៗ មិនបានផ្តល់ចម្លើយច្បាស់លាស់ចំពោះកង្វល់ដែលបានលើកឡើងនោះទេ តែបែរជារក្សាជំហរការពារខ្លួនទៅវិញ។ ក្នុងករណីជាច្រើន មន្ត្រីមូលដ្ឋានប្រើប្រាស់ពេលវេលារបស់ខ្លួន ដើម្បីវាយប្រហារអ្នកដទៃដោយពាក្យសម្តីដោយរំលោភលើក្រមសីលធម៌របស់វិទ្យាស្ថានជាតិ NDI។ មន្ត្រីមូលដ្ឋានម្នាក់ក្នុងខេត្តកំពត បានគំរាមគំហែងអ្នកតំណាងរាស្ត្ររបស់គណបក្ស សម រង្ស៊ី ដោយនិយាយថា ប្រសិនបើវេទិកានេះ មិនមែនជាវេទិកាសាធារណៈទេនោះ "អាច នឹងកើតមានបញ្ហា" ។

## III. លទ្ធផលនៃការពិភាក្សាក្រុមគោលដៅ

វិទ្យាស្ថានជាតិ NDI បានរៀបចំការពិភាក្សាក្រុមគោលដៅជាមួយអ្នកចូលរួមដែលត្រូវបានជ្រើសរើសសម្រាប់កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដើម្បីប្រមូលព័ត៌មានបែបគុណភាព ដែលត្រូវបានប្រើប្រាស់ ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អំពីចំណេះដឹង និងអាកប្បកិរិយារបស់អ្នកចូលរួម ចំពោះរដ្ឋសភា និងអ្នកតំណាងរាស្ត្រ និងការយល់ឃើញរបស់ពួកគេអំពីជម្រើសនយោបាយ និងប្រជាធិបតេយ្យពហុបក្ស។ តាមរយៈការពិភាក្សាក្រុមគោលដៅទាំងនេះ វិទ្យាស្ថានជាតិ NDI បានប្រមូលព័ត៌មានអំពីទម្លាប់ទូទៅសម្រាប់ការដោះស្រាយបញ្ហានៅក្នុងសហគមន៍ និងកម្រិតនៃទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងអ្នកតំណាងរាស្ត្រ ។

ការពិភាក្សាក្រុមគោលដៅ ត្រូវបានរៀបចំនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតចំនួន១៨ ក្នុងចំណោមកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតសរុប២៥[9] ដែលបានធ្វើឡើងចន្លោះពីខែវិច្ឆិកា ឆ្នាំ២០១០ ដល់ខែកញ្ញា ឆ្នាំ២០១១។ អ្នកចូលរួមភាគច្រើនគឺជាកសិករដែលមានអាយុចាប់ពី២៥ឆ្នាំឡើងទៅ។ ការពិភាក្សាក្រុមគោលដៅមានរយៈពេលប្រហែល១ម៉ោង ហើយមានមនុស្ស១២នាក់ជាមធ្យម ដែលមានប្រជាពលរដ្ឋជិត២៥០នាក់ (ជាង៥០%ជាស្ត្រី) ចូលរួមនៅក្នុងរយៈពេលនៃការពិភាក្សាក្រុមគោលដៅទាំងមូល។ អ្នកសម្របសម្រួលរបស់វិទ្យាស្ថានជាតិ NDI បានសួរសំណួរស្រដៀងគ្នា និងបានរៀបចំលំហាត់ពាក្យផ្សំជាមួយអ្នកចូលរួមភ្លាមៗមុន និងក្រោយពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដើម្បីកត់ត្រានូវការផ្លាស់ប្តូរណាមួយ។ វិទ្យាស្ថានជាតិ NDI បានរៀបចំការពិភាក្សាក្រុមគោលដៅជាភាសាខ្មែរ និងថតសម្លេងនៃដំណើរការនៃការពិភាក្សា ក្រោយមកវិទ្យាស្ថានជាតិ NDI បានចម្លងកំណត់ត្រាជាអក្សរ និងបកប្រែជាភាសាអង់គ្លេស។

ការយល់ដឹងរបស់អ្នកចូលរួមក្នុងការពិភាក្សាក្រុមគោលដៅអំពីរដ្ឋសភា មុនពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មានភាពខុសគ្នា ប៉ុន្តែជាទូទៅមានខុសគ្នាតិចតួច។ មានតែពាក់កណ្តាលនៃអ្នកចូលរួមនៅក្នុងក្រុមពិភាក្សាគោលដៅចំនួន៩ ក្នុងចំណោមក្រុមពិភាក្សាទាំង១៨ប៉ុណ្ណោះ ដែលអាចបង្ហាញកំណត់ផ្នែកណាមួយនៃការងាររបស់រដ្ឋសភា។ អ្នកឆ្លើយភាគច្រើនបានបញ្ជាក់ថា ពួកគេមិនបានដឹងថារដ្ឋសភាជាអ្វីទេ ឬបានផ្តល់ចម្លើយមិនច្បាស់លាស់។ ឧទាហរណ៍ មុនពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតលើកទីពីរនៅខេត្តកំពង់ស្ពឺ អ្នកចូលរួមម្នាក់បាននិយាយថា "នៅពេលដែលខ្ញុំបានឮពាក្យរដ្ឋសភា ខ្ញុំគិតថា វាគឺជាអ្នកគ្រប់គ្រង" ។ ទោះបីជាយ៉ាងនេះក្តី ក្នុងករណីខ្លះ អ្នកចូលរួម

[9] ការពិភាក្សាជាក្រុម ត្រូវបានធ្វើឡើងសម្រាប់កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតចំនួន៦ ដែលបានសាកល្បង ឬអនុវត្តវិធីសាស្ត្រការពិភាក្សាជាក្រុមជំនួសសម្រាប់ការសិក្សាវាយតម្លៃលើផលប៉ះពាល់របស់វិទ្យាស្ថាន NDI ។

អាចនិយាយយ៉ាងច្បាស់អំពីមុខងាររបស់រដ្ឋសភា។ អ្នកចូលរួមម្នាក់នៅខេត្តកំពតបាននិយាយថា "រដ្ឋសភា ត្រូវបានបង្កើតឡើងដើម្បីតំណាងប្រជាពលរដ្ឋ...រដ្ឋសភា ប្រមូលសំណូមពរពីប្រជាពលរដ្ឋ ហើយបញ្ជូនទៅរដ្ឋាភិបាល" ។ ការយល់ដឹងរបស់អ្នកចូលរួមអំពីមុខងាររបស់រដ្ឋសភា គឺច្បាស់លាស់បំផុតនៅក្នុងការពិភាក្សាក្រុមគោលដៅមុនពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតដែលបានរៀបចំនៅក្នុងខេត្តព្រៃវែង កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតលើកទីមួយដែលបានរៀបចំនៅក្នុងខេត្តកំពង់ស្ពឺ និងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតលើកទីពីរដែលបានរៀបចំនៅក្នុងខេត្តសៀមរាប។ អ្នកឆ្លើយនៅក្នុងការពិភាក្សាក្រុមគោលដៅទាំងនេះ ភាគច្រើនបានអធិប្បាយអំពីមុខងារតាក់តែងច្បាប់របស់រដ្ឋសភា។ នៅក្នុងការពិភាក្សាក្រុមគោលដៅតែមួយប៉ុណ្ណោះមុនកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតលើកទីមួយដែលរៀបចំនៅក្នុងខេត្តកណ្ដាលដែលអ្នកចូលរួមម្នាក់ បាននិយាយបញ្ជិតបញ្ជៀងអំពីតួនាទីត្រួតពិនិត្យរបស់រដ្ឋសភា៖ "រដ្ឋសភាត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងអ្នកមានអំណាច។ ដូច្នេះ រដ្ឋាភិបាល មិនអាចធ្វើអ្វីតាមតែអំពើចិត្តរបស់ខ្លួនឡើយ " ។

ភ្លាមៗបន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រនិងម្ចាស់ឆ្នោត ការពិភាក្សាក្រុមគោលដៅ បានបង្ហាញអំពីការផ្លាស់ប្ដូរលើចំណេះដឹងរបស់អ្នកចូលរួម ដោយសារតែពួកគាត់បានចូលរួមនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ ជារួមមានការយល់ដឹងច្បាស់លាស់ជាងមុនអំពីតួនាទី និងមុខងាររបស់រដ្ឋសភា យ៉ាងហោចណាស់ពាក់កណ្ដាលនៃអ្នកចូលរួមក្នុងការពិភាក្សាក្រុមគោលដៅនីមួយៗ អាចកំណត់បង្ហាញនូវទិដ្ឋភាពនៃការងាររបស់រដ្ឋសភា។ ការផ្លាស់ប្ដូរនេះ គួរឲ្យកត់សំគាល់ជាពិសេសនៅតាមបណ្ដាខេត្ត ដែលការយល់ដឹងមានកម្រិតមុនពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ ផ្ទុយទៅវិញ នៅក្នុងការពិភាក្សាក្រុមគោលដៅនៅក្នុងខេត្តកំពង់ចាម កំពត បន្ទាយមានជ័យ និងក្នុងការពិភាក្សាក្រុមគោលដៅលើកទីពីរនៅខេត្តកណ្ដាល អ្នកចូលរួមចំនួនពាក់កណ្ដាល នៅតែមិនអាចកំណត់ថា តើរដ្ឋសភាមានតួនាទីអ្វី។ ឧទាហរណ៍ នៅក្នុងការពិភាក្សាក្រុមគោលដៅលើកទីពីរ អ្នកចូលរួម៨នាក់ បានថ្លែងថា ពួកគេមិនដែលបានឮពាក្យ "រដ្ឋសភាទេ" ទោះបីជាទើបតែបានស្ដាប់អ្នកតំណាងរាស្ត្រក្នុងអំឡុងពេលកិច្ចពិភាក្សាក៏ដោយ។ សូម្បីតែ អ្នកចូលរួមដែលអាចកំណត់ពីមុខងាររបស់រដ្ឋសភា ជាធម្មតាគ្រាន់តែបានលើកឡើងអំពីផ្នែកតាក់តែងច្បាប់នៃការងាររបស់រដ្ឋសភា និងគ្រាន់តែលើកឡើងពីតួនាទីតំណាងម្ដងម្កាលប៉ុណ្ណោះ។ ប្រជាពលរដ្ឋតែ២នាក់ប៉ុណ្ណោះ នៅក្នុងការពិភាក្សាក្រុមគោលដៅ បានលើកឡើងអំពីតួនាទីត្រួតពិនិត្យរបស់រដ្ឋសភា។ អ្នកឆ្លើយម្នាក់ នៅក្នុងការពិភាក្សាក្រុមគោលដៅលើកទីមួយនៅក្នុងខេត្តកណ្ដាលបានមានប្រសាសន៍ថា "រដ្ឋសភា គឺជាស្ថាប័នដែលប្រជាពលរដ្ឋបោះឆ្នោតឲ្យដើម្បីតាក់តែងអនុម័ត និងអនុវត្តច្បាប់ ហើយរដ្ឋសភាក៏ត្រួតពិនិត្យការអនុវត្តន៍របស់រដ្ឋាភិបាលផងដែរ"។

មុនពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អ្នកចូលរួមការពិភាក្សាក្រុមគោលដៅ បានបង្ហាញអំពីការយល់ដឹងទូលំទូលាយ មិនច្បាស់លាស់អំពីតួនាទីរបស់សមាជិកសភា។ អ្នកចូលរួមភាគច្រើនបានឆ្លើយថា អ្នកតំណាងរាស្ត្រត្រូវ "ជួយប្រជាពលរដ្ឋ" ឬ"ដោះស្រាយបញ្ហា" ហើយអ្នកចូលរួមភាគច្រើនមានជំនឿថា ការងាររបស់អ្នកតំណាងរាស្ត្រ គឺត្រូវផ្តល់អំណោយ និងសេវាជាក់ស្តែង ជាញឹកញាប់សំដៅទៅលើហេដ្ឋារចនាសម្ព័ន្ធ ដោយផ្ទាល់ដល់ម្ចាស់ឆ្នោតរបស់ពួកគេ។ អ្នកចូលរួមម្នាក់នៅក្នុងខេត្តកំពង់ធំ បានថ្លែងថា "អ្នកតំណាងរាស្ត្ររបស់ខ្ញុំ ត្រូវអភិវឌ្ឍន៍សហគមន៍ ផ្តល់បង្គន់អនាម័យ អណ្តូង និងផ្លូវថ្នល់"។ នៅក្នុងការពិភាក្សាក្រុមគោលដៅលើកទីពីរនៅខេត្តកណ្តាល អ្នកឆ្លើយម្នាក់បាននិយាយថា "អ្នកតំណាងរាស្ត្ររបស់យើង ត្រូវតែកសាងទំនប់ទឹក ប្រឡាយ ផ្លូវថ្នល់ និងស្ពានសម្រាប់ប្រជាពលរដ្ឋ"។ ផ្ទុយទៅវិញ នៅក្នុងការពិភាក្សាក្រុមគោលដៅនៅខេត្តបន្ទាយមានជ័យ ការពិភាក្សាក្រុមគោលដៅលើកទីមួយនៅខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ នៅពេលដែលបានសួរអំពីតួនាទីរបស់អ្នកតំណាងរាស្ត្រ អ្នកចូលរួមពាក់កណ្តាល បានរៀបរាប់អំពីមុខងារតំណាងរបស់អ្នកតំណាងរាស្ត្របានត្រឹមត្រូវ។ នៅក្នុងខេត្តកណ្តាល អ្នកឆ្លើយម្នាក់បានពន្យល់ថា "អ្នកតំណាងរាស្ត្រ គឺជាអ្នកដែលអាចជួយពាំនាំពាក្យរបស់ប្រជាពលរដ្ឋទៅថ្នាក់ជាតិ"។ មុនពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត គ្មានអ្នកចូលរួមការពិភាក្សាក្រុមគោលដៅណាម្នាក់ បានរៀបរាប់ពីតួនាទីរបស់អ្នកតំណាងរាស្ត្រ ដូចជាការតាក់តែងច្បាប់ ឬត្រួតពិនិត្យតាមដានសកម្មភាពរបស់រដ្ឋាភិបាលឡើយ។ ដោយសារតែសមត្ថភាពរបស់អ្នកចូលរួមខ្លះក្នុងការកំណត់បង្ហាញនូវមុខងារតាក់តែងច្បាប់របស់សភាជាតិ នេះប្រហែលជាបានបង្ហាញពីការមិនយល់ដឹងពិតៗអំពីការធ្វើច្បាប់ និងផលប៉ះពាល់របស់វាទៅលើសហគមន៍។

ជំនឿរបស់អ្នកចូលរួមលើការទទួលខុសត្រូវរបស់អ្នកតំណាងរាស្ត្រ មានលក្ខណៈជាក់ច្បាស់ច្រើននៅពេលពិភាក្សាអំពីការរំពឹងទុករបស់ពួកគេពីអ្នកតំណាងរបស់ខ្លួន។ នៅក្នុងការពិភាក្សាក្រុមគោលដៅស្ទើរតែទាំងអស់ អ្នកចូលរួមរំពឹងថា អ្នកតំណាងរាស្ត្រ នឹងផ្តល់អំណោយ និងសម្ភារៈសម្រាប់ការអភិវឌ្ឍន៍។ ផ្លូវថ្នល់ ប្រឡាយ ស្ពាន អគ្គិសនី សាលារៀន មណ្ឌលសុខភាព និងបង្គន់អនាម័យ ត្រូវបានលើកឡើងច្រើនបំផុតដោយអ្នកចូលរួម។ អ្នកឆ្លើយម្នាក់នៅខេត្តកំពង់ធំបានរាយការណ៍ថា អ្នកតំណាងរាស្ត្ររបស់គាត់ គួរតែផ្តល់ "អគ្គិសនី និងកសាងសាលារៀន ផ្លូវថ្នល់ អណ្តូង មន្ទីរពេទ្យ និងបង្គន់អនាម័យឲ្យបានច្រើន ហើយផ្តល់ឡាន និងម៉ូតូដល់ប្រជាពលរដ្ឋ"។ ប៉ុន្តែក៏មានករណីលើកលែងខ្លះៗដែលនៅក្នុងការកិច្ចពិភាក្សាក្រុមគោលដៅ។ មុនពេលកិច្ចពិភាក្សារវាងតំណាងរាស្ត្រ និងម្ចាស់ឆ្នោតលើកទីមួយដែលបានរៀបចំនៅក្នុងខេត្តកំពង់ស្ពឺ អ្នកចូលរួមការពិភាក្សាក្រុមគោលដៅម្នាក់បានថ្លែងថា "នៅពេលអនាគត ខ្ញុំចង់ឲ្យអ្នកតំណាងរាស្ត្ររបស់ខ្ញុំផ្តល់លទ្ធិប្រជាធិបតេយ្យសេរីពិតប្រាកដ ប្រព័ន្ធនយោបាយពហុបក្ស និងការពារបូរណភាពដែនដី"។ នៅក្នុងការពិភាក្សាក្រុមគោលដៅនៅខេត្តក្រចេះ ការពិភាក្សាក្រុមគោលដៅលើកទីមួយនៅខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ អ្នកចូលរួមបានរៀបរាប់អំពីការរំពឹងទុករបស់ពួកគេថា អ្នកតំណាងរាស្ត្រ នឹង

ដោះស្រាយបញ្ហាដីធ្លីរបស់ពួកគេ។ អ្នកឆ្លើយម្នាក់នៅខេត្តកណ្តាលបានថ្លែងថា "យើងចង់ឲ្យអ្នកតំណាងរាស្ត្រដោះស្រាយបញ្ហានៅក្នុងសហគមន៍របស់យើងដែលទាក់ទងនឹងជម្លោះដីធ្លី"។

ការយល់ដឹងរបស់អ្នកចូលរួមអំពីតួនាទីជាក់លាក់នៃអ្នកតំណាងរាស្ត្រ បានបង្ហាញនូវការផ្លាស់ប្តូរបន្តិចបន្តួច បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ទោះបីជាអ្នកចូលរួមការពិភាក្សាក្រុមគោលដៅមួយចំនួនតូច បាននិយាយអំពីមុខងារតំណាង បន្ថែមទៅលើការផ្តល់សម្ភារៈក៏ដោយ។ នៅក្នុងខេត្តមួយចំនួន ចំណេះដឹងរបស់អ្នកចូលរួមមានការរីកចម្រើនខ្លាំង។ អ្នកចូលរួមក្នុងការពិភាក្សាក្រុមគោលដៅទាំងពីរលើកនៅខេត្តកំពង់ស្ពឺ ខេត្តកណ្តាល និងខេត្តក្រចេះ បានបង្ហាញនូវការយល់ដឹងល្អប្រសើរអំពីការទទួលខុសត្រូវរបស់អ្នកតំណាងរាស្ត្រ បន្ទាប់ពីបានចូលរួមកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ ដូចស្ត្រីម្នាក់នៅខេត្តកំពង់ស្ពឺបានថ្លែងថា "អ្នកតំណាងរាស្ត្ររបស់ខ្ញុំ ត្រូវតែចុះទៅសួរសុខទុក្ខប្រជាពលរដ្ឋ បង្កើតច្បាប់ផ្អែកលើតម្រូវការរបស់ប្រជាពលរដ្ឋ និងពាំនាំតម្រូវការរបស់ប្រជាពលរដ្ឋទៅកាន់រដ្ឋសភា"។ អ្នកចូលរួមម្នាក់នៅខេត្តក្រចេះបាននិយាយថា "អ្នកតំណាង-រាស្ត្ររបស់ខ្ញុំ ត្រូវតែបម្រើប្រជាពលរដ្ឋ និងពាំនាំកង្វល់របស់ប្រជាពលរដ្ឋទៅជូនរដ្ឋសភា និងរដ្ឋមន្ត្រីពាក់ព័ន្ធ "អ្នកឆ្លើយម្នាក់នៅខេត្តកណ្តាលបានថ្លែងថា" អ្នកតំណាងរាស្ត្ររបស់ខ្ញុំត្រូវតែស្រាវជ្រាវឯកសារពីតំបន់មូលដ្ឋាន និងពិនិត្យតាមដាននូវការអនុវត្តន៍ច្បាប់របស់រដ្ឋសភា និងព្រឹទ្ធសភា"។ បន្ទាប់ពី កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតលើកទីពីរនៅខេត្តកំពង់ស្ពឺ អ្នកចូលរួមការពិភាក្សាក្រុមគោលដៅ បានឈប់លើកឡើងថា អ្នកតំណាងរាស្ត្រគួរតែផ្តល់ការអភិវឌ្ឍន៍ ហើយបែរជាផ្តោតលើបញ្ហាយុត្តិធម៌ និងបញ្ហាដីធ្លីវិញ។ ដូចអ្នកឆ្លើយម្នាក់បានលើកឡើងថា "ក្នុងពេលអនាគត យើងចង់ឲ្យអ្នកតំណាងរាស្ត្ររបស់យើង ដោះស្រាយជម្លោះដីធ្លី និងប្រគល់ដីឲ្យប្រជាពលរដ្ឋវិញ"។ ទោះបីជាយ៉ាងនេះក្តី ភាគច្រើននៃអ្នកចូលរួមការពិភាក្សាក្រុមគោលដៅនៅតែរំពឹងថា នឹងមានការផ្តល់នូវរបស់ ឬសម្ភារៈជាក់លាក់ ដូចជាផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ និងសាលារៀនពីអ្នកតំណាងរាស្ត្រ ក្រោយពីកិច្ចពិភាក្សាទាំងនេះ។

អ្នកចូលរួមនៅក្នុងការពិភាក្សាក្រុមគោលដៅមុនកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មានមតិយោបល់ច្បាស់លាស់អំពីលក្ខណៈសម្បត្តិរបស់អ្នកតំណាងរាស្ត្រ ដែលពួកគេចង់បាន – ពោលគឺភាពត្រឹមត្រូវ ភាពស្មោះត្រង់ ការអាណិតអាសូរ មានចំណេះដឹងបទពិសោធន៍ និងភក្តីភាព – ហើយគំនិតយោបល់ទាំងនេះ មិនបានផ្លាស់ប្តូរទេ ក្រោយពីកិច្ចពិភាក្សា។ ពាក្យ "ស្លូតបូត" គឺជាគុណនាមមួយ ដែលត្រូវបានលើកឡើងដដែលៗជាញឹកញាប់ ហើយប្រជាពលរដ្ឋជាច្រើនបានលើកឡើងថា អ្នកតំណាងរាស្ត្រគួរតែ "ចុះសួរសុខទុក្ខប្រជាពលរដ្ឋឲ្យបានញឹកញាប់"។ ពាក្យ "យុត្តិធម៌" ក៏ត្រូវបានលើកឡើងជាញឹកញាប់ផងដែរ ដោយអ្នកចូលរួមម្នាក់នៅខេត្តក្រចេះបានថ្លែងថា "អ្នកតំណាងរាស្ត្ររបស់ខ្ញុំ គួរតែជាបុគ្គលម្នាក់ដែលជួយរកយុត្តិធម៌ឲ្យប្រជាពលរដ្ឋ"។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ គឺនិន្នាការនយោបាយរបស់អ្នកតំណាងរាស្ត្រ មិនត្រូវបានលើកឡើងក្នុងអំឡុងការពិភាក្សាទាំងនេះឡើយ។

មុនកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ការពិភាក្សាក្រុមគោលដៅបានបង្ហាញថា កិច្ចខិតខំប្រឹងប្រែងចុះទស្សនកិច្ចតាមមណ្ឌលបោះឆ្នោតរបស់អ្នកតំណាងរាស្ត្រមិនទាន់បានគ្រប់គ្រាន់ ហើយអ្នកចូលរួមភាគច្រើន មិនធ្លាប់មានទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្ររបស់ពួកគេទេ។ ទោះបីជាយ៉ាងណាក្តី បើប្រៀបធៀបជាមួយឆ្នាំមុនៗ អ្នកចូលរួមភាគច្រើន អាចស្គាល់ឈ្មោះរបស់អ្នកតំណាងរាស្ត្រ។ នៅក្នុងការពិភាក្សាក្រុមគោលដៅចំនួន៩លើក មុនពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មានអ្នកចូលរួម៥នាក់ ឬច្រើនជាងនេះ បានប្រាប់ឈ្មោះអ្នកតំណាងរាស្ត្ររបស់ពួកគេ។ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អ្នកចូលរួមការពិភាក្សាក្រុមគោលដៅទាំងអស់ អាចស្គាល់ឈ្មោះអ្នកតំណាងរាស្ត្រម្នាក់យ៉ាងតិច ដែលពួកគេបានជួបនៅក្នុងវេទិកាកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ។

ទោះបីជាយ៉ាងនេះក្តី នៅក្នុងការពិភាក្សាក្រុមគោលដៅតែ៥ ប៉ុណ្ណោះ ដែលអ្នកចូលរួមបានរាយការណ៍ថា អ្នកតំណាងរាស្ត្របានទំនាក់ទំនងជាមួយគេ ជាធម្មតានៅក្នុងការប្រជុំសាធារណៈ។ ក្នុងករណីមួយចំនួន អ្នកចូលរួមបាននឹកឃើញអំពីការប្រជុំទាំងនេះ បន្ទាប់ពីបានចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ ក្រោយពីកិច្ចពិភាក្សានៅខេត្តកំពង់ស្ពឺ អ្នកចូលរួមម្នាក់បាននឹកឃើញថា "មែនហើយ! ឯកឧត្តម **នុត រ៉ុមដួល** បានទំនាក់ទំនងជាមួយយើងអំពីអ្វីដែលពួកគេមានផែនការត្រូវធ្វើ នៅពេលដែលពួកគេបានចុះមកជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ ហើយយើងបានដាក់ពាក្យបណ្តឹងជូនគាត់"។ នេះបង្ហាញឲ្យឃើញពីការរីកចម្រើន បើប្រៀបធៀបជាមួយកម្មវិធីទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតឆ្នាំមុនៗរបស់វិទ្យាស្ថានជាតិ NDI នៅពេលដែលអ្នកចូលរួមការពិភាក្សាជាក្រុមមិនដែលបានរាយការណ៍ថា អ្នកតំណាងរាស្ត្រម្នាក់បានទំនាក់ទំនងជាមួយពួកគេឡើយ។






ដើម្បីដោះស្រាយបញ្ហានៅក្នុងសហគមន៍របស់ពួកគេ អ្នកចូលរួមការពិភាក្សាក្រុមគោលដៅ បានស្វែងរកអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋាន – មេភូមិ អភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ឬអង្គការមិនមែនរដ្ឋាភិបាល។ អ្នកចូលរួមភាគច្រើនមិនដែលបានទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្ររបស់ពួកគេអំពីបញ្ហាណាមួយឡើយ។ នៅក្នុងការពិភាក្សាក្រុមគោលដៅតែ៣ប៉ុណ្ណោះ ដែលប្រជាពលរដ្ឋមួយចំនួនតូចបានរាយការណ៍ថា ពួកគេបានទាក់ទងជាមួយអ្នកតំណាងរាស្ត្ររបស់ខ្លួន។ ការពិភាក្សាក្រុមគោលដៅលើកទីពីរនៅខេត្តសៀមរាប គឺលេចធ្លោជាងគេ ដោយអ្នកចូលរួមភាគច្រើនបានរាយការណ៍ថា ពួកគេបានទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្ររបស់ពួកគេតាមរយៈវេទិកាផ្សេងៗ ដូចជាកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតដែរ។ ទោះបីជាមានកង្វះទំនាក់ទំនងជារូមក៏ដោយ អ្នកចូលរួមការពិភាក្សាក្រុមគោលដៅ បានទទួលស្គាល់ថា ពួកគេមានសិទ្ធិក្នុងការនាំយកកង្វល់របស់ខ្លួន ទៅជូនអ្នកតំណាងរាស្ត្រ។ នៅពេលដែលសួរថា តើពួកគេនឹងទៅទាក់ទងជាមួយអ្នកតំណាងរាស្ត្រក្នុងពេលអនាគត ដែរឬទេ អ្នកចូលរួមភាគច្រើនបានលើកឡើងថា ពួកគេនឹងទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្រ។ មានតែការពិភាក្សាក្រុមគោលដៅនៅខេត្តកំពត បាត់ដំបង និងការពិភាក្សាទាំងពីរលើកនៅកំពង់ធំប៉ុណ្ណោះទេ ដែលអ្នកចូលរួមពីរបីនាក់បានសម្តែងការភ័យខ្លាចក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកតំណាងរាស្ត្រ។ អ្នកចូលរួមម្នាក់នៅខេត្តបាត់ដំបងបានពន្យល់ថា "ប្រសិនបើ យើងមានបញ្ហានៅពេលអនាគត យើងនឹងមិននិយាយប្រាប់អ្នកតំណាងរាស្ត្ររបស់យើងទេ ខ្លាចក្រែងយើងប្រើពាក្យសម្តីមិនសមរម្យចំពោះពួកគេ"។ ប៉ុន្តែបន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនៅក្នុងខេត្តបាត់ដំបង អ្នកចូលរួមការពិភាក្សាក្រុមគោលដៅទាំងអស់បាននិយាយថា ពួកគេនឹងទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្ររបស់ពួកគេនៅពេលអនាគត។




ក្រៅពីទំនាក់ទំនងមានកម្រិតជាមួយអ្នកតំណាងរាស្ត្ររបស់ពួកគេ អ្នកចូលរួមការពិភាក្សាក្រុមគោលដៅ មិនអាចកំណត់បង្ហាញពីសកម្មភាព ឬគំនិតផ្តួចផ្តើម ដែលអ្នកតំណាងរាស្ត្រ ធ្វើឡើងក្នុងនាមប្រជាពលរដ្ឋ ឬសហគមន៍របស់ពួកគេ ឬកិច្ចខិតខំប្រឹងប្រែងដែលអ្នកតំណាងរាស្ត្របានធ្វើឡើងដើម្បីដោះស្រាយបញ្ហាឡើយ។ នៅក្នុងការពិភាក្សាក្រុមគោលដៅចំនួន១២ក្នុងចំណោមកិច្ចពិភាក្សាក្រុមគោលដៅសរុប១៨ អ្នកចូលរួមមិនអាចប្រាប់ពីសកម្មភាពដែលអ្នកតំណាងរាស្ត្រ ឬសភាជាតិបានធ្វើរួចកន្លងមកទេ មុនពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ នៅក្នុងការពិភាក្សាក្រុមគោលដៅចំនួន៣ អ្នកចូលរួមពីរបីនាក់បានរាយការណ៍ជាទូទៅថា អ្នកតំណាងរាស្ត្រ "បានធ្វើកិច្ចការជាច្រើនដូចជាកសាងផ្លូវថ្នល់ ស្ពាន សាលារៀន និងវត្តអារាម" ដោយមិនបានប្រាប់ឈ្មោះបុគ្គលជាក់លាក់ទេ។ នៅក្នុងការពិភាក្សាក្រុមគោលដៅមួយនៅខេត្តបាត់ដំបង ប្រជាពលរដ្ឋចំនួន៣នាក់ បានលើកឡើងអំពីប្រាក់វិភាគទានរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាង-រាស្ត្រ និងម្ចាស់ឆ្នោត អ្នកចូលរួមជាច្រើន បាននឹកឃើញអំពីសកម្មភាពមុនៗរបស់អ្នកតំណាងរាស្ត្រ ទោះបីជាការនឹកឃើញនេះ ប្រហែលកើតឡើងដោយសារតែសុន្ទរកថារបស់អ្នកតំណាងរាស្ត្រនៅក្នុងកិច្ចពិភាក្សាទាំងនេះក៏ដោយ។ ឧទាហរណ៍ នៅក្នុង ខេត្តកំពង់ឆ្នាំង ប្រជាពលរដ្ឋចំនួន៤នាក់ បានរំលឹកថាក្នុងពេលកន្លងមក លោកជំទាវ **កែ ច័ន្ទមុនី** អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា បានចែកអំណោយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតលើកទីពីរនៅខេត្តកំពង់ស្ពឺ អ្នកចូលរួមចំនួន២នាក់បានរាយការណ៍ថា "មែនហើយ យើងធ្លាប់បានឃើញអ្នកតំណាងរាស្ត្រមកពីគណបក្សប្រឆាំងមកជួយដោះស្រាយជម្លោះដីធ្លី"។ បន្ទាប់ពីកិច្ចពិភាក្សាលើកទីមួយនៅខេត្តកណ្តាល អ្នកចូលរួមការពិភាក្សាក្រុមគោលដៅបានឯកភាពគ្នា នៅពេលដែលអ្នកចូលរួមម្នាក់បានលើកឡើងថា "ឯកឧត្តម **ចាន់ ចេង** មកពីគណបក្ស សម រង្ស៊ី បានជួយ

នាំយកសំណូមពររបស់យើងអំពីជម្លោះដីធ្លី ទៅជូនរដ្ឋសភា និងរដ្ឋាភិបាល"។ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនៅខេត្តកំពត អ្នកចូលរួមភាគច្រើនបានយល់ស្របគ្នាថា គណបក្សប្រជាជនកម្ពុជា បានផ្តល់អំណោយដល់ប្រជាពលរដ្ឋក្នុងពេលកន្លងមក។







អ្នកចូលរួមជាច្រើន ក៏បានរៀបរាប់ផងដែរអំពីការចូលរួមរបស់ពួកគេផ្ទាល់ក្នុងការកសាងសហគមន៍ជារឿយៗ ការចូលរួមនោះទម្រង់ជាការគាំទ្រផ្នែកហិរញ្ញវត្ថុ សម្រាប់គម្រោងអភិវឌ្ឍន៍ខ្នាតតូចនៅថ្នាក់មូលដ្ឋាន ឬការចូលរួមនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ អ្នកចូលរួមភាគច្រើននៅក្នុងការពិភាក្សាក្រុមគោលដៅទាំងអស់ បានរាយការណ៍អំពីអារម្មណ៍របស់ពួកគេដែលថា ពួកគេ ជាផ្នែកមួយនៃដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងសហគមន៍។

តាមរយៈការពិភាក្សាក្រុមគោលដៅ វិទ្យាស្ថានជាតិ NDI ក៏បានស្ទង់លើការយល់ឃើញរបស់ប្រជាពលរដ្ឋចំពោះការប្រកួតប្រជែង និងជម្រើសផ្នែកនយោបាយផងដែរ។ ជារួមមាននិន្នាការចម្រុះគ្នាចំពោះគណបក្សប្រឆាំង និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស មុនពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ហើយពាក់កណ្តាលនៃការពិភាក្សាក្រុមគោលដៅ (ការពិភាក្សាក្រុមគោលដៅលើកទីមួយនៅខេត្តកំពង់ធំ កំពត បន្ទាយមានជ័យ សៀមរាបលើកទីមួយ ការពិភាក្សាក្រុមគោលដៅទាំងពីរលើកនៅខេត្តកំពង់ស្ពឺ កិច្ចពិភាក្សាក្រុមគោលដៅទាំងពីរនៅខេត្តតាកែវ និងខេត្តក្រចេះ) អ្នកចូលរួមភាគច្រើនមានចំណាប់អារម្មណ៍គាំទ្រគណបក្សប្រឆាំង។ ជាធម្មតាប្រជាពលរដ្ឋ បានរៀបរាប់អំពីតួនាទីកែលំអបែបស្ថាបនារបស់គណបក្សប្រឆាំង។ ដូចអ្នកចូលរួមម្នាក់នៅខេត្តកំពង់ធំ បានលើកឡើងថា "នៅពេលដែលខ្ញុំបានឮពាក្យ "គណបក្សប្រឆាំង" ខ្ញុំគិតថា អ្នកខ្លះបានធ្វើអ្វីមួយខុស ដូច្នេះទើបពួកគេរិះគន់ ឬប្រឆាំង"។ នៅក្នុងការពិភាក្សាក្រុមគោលដៅចំនួន៤ និន្នាការរបស់អ្នកចូលរួមមានលក្ខណៈអព្យាក្រឹតចម្រុះគ្នា ឬប្រជាពលរដ្ឋមិនដឹង។ អ្នកឆ្លើយម្នាក់នៅខេត្តព្រៃវែងបានថ្លែងថា "នៅពេលដែលយើងឮពាក្យ "គណបក្សប្រឆាំង" យើងគិតថា គឺជាគណបក្សមួយដែលមានទស្សនៈនយោបាយខុសពីរដ្ឋាភិបាល"។ នៅខេត្តកំពង់ធំ ប្រជាពលរដ្ឋម្នាក់ដែលបានចូលរួមក្នុងកិច្ចពិភាក្សាលើកទីពីរ បាននិយាយថា "នៅពេលដែលយើងឮពាក្យ "គណបក្សប្រឆាំង" យើងគិតថា វាគឺជាគណបក្សល្អមួយ ប៉ុន្តែជួនកាលមានវិធីត្រឹមត្រូវ និងមិនត្រឹមត្រូវក្នុងការនិយាយប្រឆាំងរដ្ឋាភិបាល" ។

នៅក្នុងការពិភាក្សាក្រុមគោលដៅចំនួន៦ អ្នកចូលរួមភាគច្រើនមានទស្សនៈអវិជ្ជមានចំពោះគណបក្សប្រឆាំង នៅមុនកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត (ការពិភាក្សាក្រុមគោលដៅលើកទីពីរនៅខេត្តសៀមរាប និងខេត្តកំពត ការពិភាក្សាក្រុមគោលដៅទាំងពីរលើកនៅខេត្តកណ្តាល ការពិភាក្សាក្រុមគោលដៅនៅខេត្តកំពង់ចាម និងការពិភាក្សាក្រុមគោលដៅនៅខេត្តបាត់ដំបង)។ ជាទូទៅ ពួកគេត្អូញត្អែរថា គណបក្សប្រឆាំងបានត្រឹមតែរិះគន់ និងមិនបានបំពេញតួនាទីដែលមានប្រយោជន៍។ ដូចអ្នកចូលរួមម្នាក់នៅខេត្តសៀមរាបបានពន្យល់ថា "នៅពេលដែលយើងបានឮពាក្យ "គណបក្សប្រឆាំង" យើងគិតថា ពួកគេតែងតែប្រឆាំងគណបក្សកាន់អំណាចគ្រប់ពេល"។ អ្នកចូលរួមម្នាក់នៅខេត្តបាត់ដំបង បានថ្លែងថា "នៅពេលដែលខ្ញុំឮពាក្យ "គណបក្សប្រឆាំង " ខ្ញុំគិតថា មានគណបក្សដែលល្អ និងអាក្រក់។ គណបក្សប្រឆាំងជម្រុញឲ្យគណបក្សដទៃទៀតធ្វើអាក្រក់ដូចពួកគេដែរ" ។

នៅបណ្តាខេត្តដែលអ្នកចូលរួមការពិភាក្សាក្រុមគោលដៅ បានបង្ហាញទស្សនៈជាអវិជ្ជមាន ឬអព្យាក្រឹត្យចំពោះទស្សនៈនៃការប្រឆាំង *មុន*កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ជាធម្មតា គោលគំនិតទាំងនេះ បានផ្លាស់ប្តូរវិញ បន្ទាប់ពីពួកគេបានចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ ឧទាហរណ៍ ក្រោយពីកិច្ចពិភាក្សា

នៅខេត្តកណ្តាល អ្នកចូលរួមម្នាក់ បានមានប្រសាសន៍ថា "នៅពេលដែលខ្ញុំឮពាក្យ "គណបក្សប្រឆាំង" ខ្ញុំគិតអំពីអ្នកដែលជួយផ្សះផ្សាបញ្ហា និងរិះគន់ដើម្បីជាប្រយោជន៍ និងការអភិវឌ្ឍន៍"។ នៅក្នុងការពិភាក្សាក្រុមគោលដៅលើកទីពីរនៅខេត្តសៀមរាប អ្នកចូលរួមទាំងអស់មានទស្សនៈអវិជ្ជមានចំពោះគណបក្សប្រឆាំង មុនពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត តែបន្ទាប់ពីមក អ្នកចូលរួមភាគច្រើនបានសម្តែងនូវចំណាប់អារម្មណ៍ជាវិជ្ជមានចំពោះគណបក្សប្រឆាំងវិញ។ អ្នកចូលរួមម្នាក់ បាននិយាយថា "នៅពេលដែលយើងលឺពាក្យ "គណបក្សប្រឆាំង" យើងគិតថា ពួកគេជួយកែតម្រូវ និងទប់ស្កាត់អំពើពុករលួយ"។ មានការយល់ដឹង និងការឲ្យតម្លៃកាន់តែច្រើនលើភាពខុសគ្នានៃមតិយោបល់ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតផងដែរ។ អ្នកចូលរួមម្នាក់នៅក្នុងការពិភាក្សាក្រុមគោលដៅលើកទីពីរនៅខេត្តកំពង់ធំ បានមានប្រសាសន៍ថា "នៅពេលដែលខ្ញុំលឺពាក្យ "គណបក្សប្រឆាំង" ខ្ញុំគិតថា តែងតែមានគំនិតពីរនៅពេលដែលយើងធ្វើអ្វីមួយ"។

ការយល់ដឹងជាសាធារណៈអំពីការប្រកួតប្រជែងខាងនយោបាយ និងជម្រើសរបស់បុគ្គលម្នាក់ៗ ក៏ត្រូវបានលើកឡើងក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតផងដែរ។ បន្ទាប់ពីកិច្ចពិភាក្សាលើកទីពីរនៅខេត្តកំពង់ស្ពឺ សមាជិកម្នាក់នៃការពិភាក្សាក្រុមគោលដៅបានសន្យាថា "ប្រសិនបើ អ្នកតំណាងរាស្ត្រមកពីគណបក្សណាមួយ អាចជួយដោះស្រាយជម្លោះដីធ្លីឲ្យខ្ញុំបាន ខ្ញុំនឹងបោះឆ្នោតឲ្យគណបក្សនោះ"។ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតរួច អ្នកចូលរួមក៏បានសង្កត់ធ្ងន់លើតម្លៃនៃកិច្ចពិភាក្សាពហុបក្ស និងការឲ្យតម្លៃរបស់ពួកគេក្នុងការស្តាប់លឺនូវទស្សនៈជាច្រើនផ្សេងៗគ្នា។ នៅពេលធ្វើការឆ្លុះបញ្ចាំងអំពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតជាទូទៅ អ្នកចូលរួមម្នាក់នៅខេត្តបន្ទាយមានជ័យ បានថ្លែងថា "ខ្ញុំគិតថាកិច្ចពិភាក្សានេះល្អ ពីព្រោះវាជាកិច្ចពិភាក្សាពហុបក្ស"។ អ្នកចូលរួមម្នាក់នៅខេត្តកណ្តាលបាននិយាយថា "ខ្ញុំគិតថា កិច្ចពិភាក្សានេះល្អ ពីព្រោះថា គណបក្សប្រឆាំងទាំងពីរ បានពិភាក្សាអំពីបញ្ហាព្រំដែន" ។

ទោះបីជាយ៉ាងនេះក្តី ការចាប់អារម្មណ៍របស់អ្នកចូលរួមលើគណបក្សប្រឆាំង មិនមែនសុទ្ធតែបានល្អប្រសើរឡើយ។ ទោះបីជានិន្នាការចំពោះគណបក្សប្រឆាំង មុនពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតលើកទីមួយនៅខេត្តកំពត មានលក្ខណៈវិជ្ជមានភាគច្រើនក៏ដោយ ប៉ុន្តែបន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អ្នកចូលរួមការពិភាក្សាក្រុមគោលដៅភាគច្រើន បានរាយការណ៍អំពីអារម្មណ៍អវិជ្ជមាន ដែលប្រហែលជាការចង្អុលប្រាប់អំពីការប្រតិបត្តិទាក់ទាញរបស់គណបក្សកាន់អំណាច ក្នុងអំឡុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ អ្នកចូលរួមម្នាក់ បានរាយការណ៍ថា "នៅពេលដែលយើងឮពាក្យ "គណបក្សប្រឆាំង" យើងគិតថា វាគឺជាគណបក្សមួយដែលចាំតែរិះគន់រដ្ឋាភិបាល"។

បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតលើកទីពីរនៅខេត្តកំពត អ្នកចូលរួមការពិភាក្សាក្រុមគោលដៅម្នាក់ប៉ុណ្ណោះ បានមានមតិវិជ្ជមានអំពីគណបក្សប្រឆាំង។







បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អ្នកសម្របសម្រួលនៃវិទ្យាស្ថានជាតិ NDI បានសួរសំណួរមួយចំនួនដល់អ្នកចូលរួមការពិភាក្សាក្រុមគោលដៅ ដើម្បីវាស់ស្ទង់មតិយោបល់នៃកិច្ចពិភាក្សាជាទូទៅ ការយល់ឃើញរបស់ពួកគាត់ចំពោះការបំពេញការងាររបស់អ្នកតំណាងរាស្ត្រ និងជំនឿទុកចិត្តរបស់ពួកគេលើសមត្ថភាពអ្នកតំណាងរាស្ត្រក្នុងការគោរពពាក្យសន្យា។ ជាទូទៅអ្នកចូលរួមការពិភាក្សាក្រុមគោលដៅក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ពេញចិត្តចំពោះការបំពេញការងាររបស់អ្នកតំណាងរាស្ត្រ ហើយគិតថា បញ្ហារបស់ពួកគេត្រូវយកមកពិភាក្សា។ អ្នកចូលរួមភាគច្រើន បានបញ្ជាក់ថា ការយល់ឃើញរបស់ពួកគេចំពោះអ្នកតំណាងរាស្ត្ររបស់ខ្លួន គឺល្អប្រសើរជាងមុនដោយសារតែ

កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ អ្នកចូលរួមម្នាក់នៅខេត្តព្រៃវែង បានឆ្លើយតបថា "មែនហើយ វាធ្វើឲ្យខ្ញុំយល់ដឹងកាន់តែច្បាស់អំពីតួនាទីរបស់អ្នកតំណាងរាស្ត្រ។ មានអ្នកតំណាងរាស្ត្រជាច្រើនមកពីគណបក្សនយោបាយផ្សេងៗគ្នា បានពិភាក្សាអំពីកង្វល់របស់ប្រជាពលរដ្ឋ"។ ប្រជាពលរដ្ឋបានរាយការណ៍ថា អ្នកតំណាងរាស្ត្រ ទំនងជាងាយស្រួលទាក់ទងជាងមុន។ នៅក្នុងការពិភាក្សាក្រុមគោលដៅលើកទីពីរនៅខេត្តកំពង់ស្ពឺ អ្នកចូលរួមម្នាក់បាននិយាយថា "មែនហើយ វាជួយឲ្យខ្ញុំបានយល់ច្បាស់អំពីតួនាទីរបស់អ្នកតំណាងរាស្ត្រ។ ឥឡូវនេះ ខ្ញុំមិនខ្លាចពួកគេទៀតទេ ហើយពួកគេនឹងចុះមកជួយប្រជាពលរដ្ឋ នៅពេលដែលពួកយើងមានបញ្ហា"។ ការសួរពីចង្កោមពាក្យ ក៏បានបង្ហាញនូវអារម្មណ៍វិជ្ជមាន បន្ទាប់ពីកម្មវិធីកិច្ចពិភាក្សាទាំងនេះផងដែរ។ នៅក្នុងការពិភាក្សាក្រុមគោលដៅក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនៅក្នុងខេត្តកំពង់ចាម អ្នកចូលរួមម្នាក់ បាននិយាយថា "នៅពេលដែលខ្ញុំឮពាក្យ "អ្នកតំណាងរាស្ត្រ" ខ្ញុំគិតដល់មនុស្សម្នាក់ដែលប្រជាពលរដ្ឋស្រឡាញ់ និងចូលចិត្ត"។ មានតែប្រជាពលរដ្ឋ៣នាក់នៅក្នុងខេត្តក្រចេះប៉ុណ្ណោះ ដែលបានបង្ហាញអំពីទស្សនៈកាន់តែអាក្រក់ចំពោះអ្នកតំណាងរាស្ត្រ បន្ទាប់ពីបានស្តាប់ពួកគេក្នុងអំឡុងពេលកិច្ចពិភាក្សា។ អ្នកចូលរួមម្នាក់បានថ្លែងថា "យើងគិតថា អ្នកតំណាងរាស្ត្រមិនបានឆ្លើយតបទៅនឹងសំណួរដែលបានលើកឡើងដោយប្រជាពលរដ្ឋដោយផ្ទាល់ទេ"។

អ្នកចូលរួមការពិភាក្សាក្រុមគោលដៅ បានរាយការណ៍អំពីកម្រិតនៃទំនុកចិត្តខ្លាំងលើអ្នកតំណាងរាស្ត្រ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ហើយបាននិយាយថា ពួកគេជឿថា អ្នកតំណាងរាស្ត្រ នឹងចាត់វិធានការដោះស្រាយបញ្ហាកង្វល់ដែលលើកឡើង។ អ្នកចូលរួមម្នាក់នៅខេត្តតាកែវ បានថ្លែងថា "យើងមានទំនុកចិត្តច្រើនលើចំណាប់អារម្មណ៍នៃអ្នកតំណាងរាស្ត្ររបស់យើងក្នុងការធ្វើជាតំណាងឲ្យយើងទាំងអស់គ្នា ពីព្រោះ ពួកគេ បានសន្យាថានឹងដោះស្រាយបញ្ហា"។ អ្នកចូលរួមមួយចំនួនបានបង្ហាញថា ពួកគេសប្បាយចិត្តដែលកង្វល់របស់ពួកគាត់ត្រូវបានស្តាប់ដោយអ្នកតំណាងរាស្ត្រ។ អ្នកចូលរួមម្នាក់នៅខេត្តកំពង់ឆ្នាំង បាននិយាយថា "ខ្ញុំមានជំនឿចិត្តច្រើនជាងមុនលើអ្នកតំណាងរាស្ត្ររបស់ខ្ញុំក្នុងការធ្វើជាតំណាងខ្ញុំ ពីព្រោះ ពួកគេបានចុះជួបជាមួយប្រជាពលរដ្ឋ និងបានស្តាប់ពីកង្វល់របស់ប្រជាពលរដ្ឋ"។ ខណៈដែលអ្នកចូលរួមភាគច្រើននៃការពិភាក្សាក្រុមគោលដៅនៅខេត្តក្រចេះ បានរៀបរាប់អំពីទំនុកចិត្តខ្លាំងលើអ្នកតំណាងរាស្ត្រ ក៏មានអ្នកចូលរួមមួយចំនួនតូចបានជំទាស់ថា "យើងមានទំនុកចិត្តតិចជាងមុនលើអ្នកតំណាងរាស្ត្ររបស់យើង ក្នុងការធ្វើជាតំណាងរបស់យើង ពីព្រោះពួកគេឆ្លើយតបទៅនឹងបញ្ហាដែលផ្អែកទៅលើច្បាប់តែប៉ុណ្ណោះ មិនផ្អែកលើអង្គហេតុជាក់ស្តែង" ដោយសំដៅដល់អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាចដែលបានឆ្លើយតបថា ប្រទេសអនុវត្តន៍ច្បាប់ ទោះបីជាត្រូវបានមើលឃើញថា មានការរំលោភច្បាប់ក៏ដោយ។ អ្នកឆ្លើយទាំងអស់នៅក្នុងការពិភាក្សាក្រុមគោលដៅលើកទីមួយនៅខេត្តសៀមរាប បានរាយការណ៍អំពីទំនុកចិត្តតិចជាងមុនលើអ្នកតំណាងរាស្ត្រ៖ "ខ្ញុំមានជំនឿតិចជាងមុនលើអ្នកតំណាងរាស្ត្រ

ពីព្រោះ ពួកគេបានសន្យាដោយគ្មានដំណោះស្រាយជាក់ស្តែង"។ ប្រជាពលរដ្ឋចំនួន២នាក់ដែលបានចូលរួមការពិភាក្សាក្រុមគោលដៅលើកទីពីរនៅខេត្តកំពង់ធំ និងការពិភាក្សាក្រុមគោលដៅនៅខេត្តបាត់ដំបង បានរាយការណ៍អំពីជំនឿតិចជាងមុនលើអ្នកតំណាងរាស្ត្ររបស់ពួកគេ បន្ទាប់ពី កិច្ចពិភាក្សាដោយបានរៀបរាប់អំពីកង្វះជំនឿចិត្តលើការតាមដានបន្ត។ អ្នកចូលរួមម្នាក់នៅខេត្តបាត់ដំបង បាននិយាយថា "ខ្ញុំមានជំនឿតិចជាងមុនលើចំណាប់អារម្មណ៍នៃអ្នកតំណាងរាស្ត្ររបស់ខ្ញុំក្នុងការធ្វើជាតំណាងខ្ញុំ ពីព្រោះពួកគេមិនដែលបានគោរពពាក្យសន្យារបស់ខ្លួនជាមួយប្រជាពលរដ្ឋឡើយ"។

ក្នុងការពិភាក្សាក្រុមគោលដៅភាគច្រើន ក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ការបង្កើនទំនុកចិត្តលើអ្នកតំណាងរាស្ត្របានកើតមានឡើងជាមួយនឹងសេចក្តីរំពឹងទុកច្រើន ហើយអ្នកចូលរួមបានសម្តែងនូវក្តីសង្ឃឹមយ៉ាងខ្លាំងថា អ្នកតំណាងរាស្ត្រ នឹងគោរពពាក្យសន្យារបស់ខ្លួនដែលបានសន្យាក្នុងអំឡុងពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត និងចុះជួបសំណេះសំណាលជាមួយម្ចាស់ឆ្នោតម្តងទៀត។ ការផ្តោតលើការបំពេញពាក្យសន្យានេះចង្អុលបង្ហាញអំពីការយល់ដឹងកាន់តែកើនឡើងអំពីការទទួលខុសត្រូវ។ អ្នកចូលរួមម្នាក់នៅខេត្តតាកែវបានថ្លែងថា "ខ្ញុំគិតថា អ្នកតំណាងរាស្ត្របានសន្យាថា នឹងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋនៅក្នុងកិច្ចពិភាក្សា ប៉ុន្តែយើងត្រូវរង់ចាំមើលសកម្មភាពរបស់ពួកគេសិន"។ អ្នកចូលរួមម្នាក់មកពីខេត្តកំពង់ស្ពឺ ក៏បានសន្យាថានឹងបោះឆ្នោតជូនអ្នកតំណាងរាស្ត្រណាដែលបានបំពេញតម្រូវការដែលបានលើកឡើងនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនេះ"។

នៅពេលដែលត្រូវបានសួរថា តើពួកគេបានទទួលព័ត៌មានដែលមានប្រយោជន៍ពីអ្នកតំណាងរាស្ត្រដែរឬទេ ក្នុងអំឡុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អ្នកចូលរួមការពិភាក្សាក្រុមគោលដៅភាគច្រើន បានឆ្លើយតបជាវិជ្ជមាន។ ដូចអ្នកចូលរួមម្នាក់នៅក្នុងការពិភាក្សាក្រុមគោលដៅលើកទីមួយនៅខេត្តសៀមរាប បានថ្លែងថា "ខ្ញុំបានយល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកតំណាងរាស្ត្រច្រើនជាងមុន និងបានទទួលព័ត៌មានស្តីពីច្បាប់តាមរយៈការពន្យល់របស់អ្នកតំណាងរាស្ត្រនៅក្នុងវេទិកា"។ អ្នកចូលរួមទាំងអស់បានបញ្ជាក់អំពីតម្លៃដែលពួកគេបានផ្តល់លើទស្សនៈនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ នៅពេលដែលត្រូវបានសួរសំណួរថា តើពួកគេយល់ថា កិច្ចពិភាក្សានេះមានប្រយោជន៍ដែរឬទេ អ្នកចូលរួមនៅក្នុងការពិភាក្សាក្រុមគោលដៅលើកទីពីរនៅខេត្តសៀមរាបបានឆ្លើយតបថា "បាទ ខ្ញុំយល់ថាវាមានប្រយោជន៍ ពីព្រោះមានការផ្លាស់ប្តូរមតិយោបល់គ្នា ហើយខ្ញុំអាចសួរពួកគេអំពីគម្រោងអភិវឌ្ឍន៍"។ អ្នកចូលរួមជាច្រើនបានរាយការណ៍ថា ពួកគេឲ្យតម្លៃលើកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដោយសារតែកិច្ចពិភាក្សានេះជាកិច្ចពិភាក្សាពហុបក្ស។ អ្នកចូលរួមម្នាក់នៅក្នុងការពិភាក្សាក្រុមគោលដៅលើកទីពីរនៅខេត្តកំពតបានថ្លែងថា "ខ្ញុំគិតថា ល្អដែលមានកិច្ចពិភាក្សាបែបនេះ ពីព្រោះមានគណបក្ស

នយោបាយពីរដែលបានស្តាប់កង្វល់របស់ប្រជាពលរដ្ឋ"។ ការពិភាក្សាក្រុមគោលដៅបានបង្ហាញថា អ្នកចូលរួមចង់បានការយកចិត្តទុកដាក់ថែមទៀតពីអ្នកតំណាងរាស្ត្រ ហើយអ្នកចូលរួមទាំងអស់ បាននិយាយថា ត្រូវតែមានកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតច្រើនថែមទៀតក្នុងពេលអនាគត។

## IV. សកម្មភាព និងលទ្ធផលក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត[10]

បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនីមួយៗ វិទ្យាស្ថានជាតិ NDI បានបំពេញទម្រង់ពិនិត្យតាមដាន ដើម្បីកត់ត្រាបញ្ហាចម្បងៗដែលអ្នកចូលរួមបានលើកឡើង ការសន្យារបស់អ្នកតំណាងរាស្ត្រ ដើម្បីដោះស្រាយនូវកង្វល់នីមួយៗ លទ្ធផលផ្អែកលើការរាយការណ៍ផ្ទាល់ខ្លួនពីអ្នកតំណាងរាស្ត្រ និងលទ្ធផលផ្អែកលើការរាយការណ៍ដោយសហគមន៍។ បុគ្គលិកនៃវិទ្យាស្ថានជាតិ NDI បានបន្តតាមដានជាមួយអ្នកតំណាងរាស្ត្រម្នាក់ៗ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដើម្បីពិភាក្សាលើសកម្មភាពរបស់ពួកគេ ដោយកត់ត្រាព័ត៌មានក្នុងទម្រង់ពិនិត្យតាមដាន[11]។ លើសពីនេះទៀត អង្គការដៃគូក្នុងស្រុករបស់វិទ្យាស្ថានជាតិ NDI បានចុះជួបតាមភូមិដែលបានរៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត និងតាមសហគមន៍នៅក្បែរ បន្ទាប់ពីកិច្ចពិភាក្សាដោយជួបសំណេះសំណាលជាមួយអ្នកចូលរួម និងអាជ្ញាធរមូលដ្ឋាន ដើម្បីសាកសួរអំពីការផ្លាស់ប្តូរ ឬភាពរីកចម្រើនណាមួយ ចំពោះបញ្ហានានាដែលបានលើកឡើងនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត និងពិនិត្យផ្ទៀងផ្ទាត់លើភាពត្រឹមត្រូវនៃរបាយការណ៍របស់អ្នកតំណាងរាស្ត្រ។ ភាគច្រើនសកម្មភាព និងលទ្ធផល ដែលបានរាយការណ៍ដោយអ្នកតំណាងរាស្ត្រ ត្រូវបានបញ្ជាក់ និងស្របតាមការសង្កេតនៅថ្នាក់សហគមន៍ដោយមន្ត្រីមូលដ្ឋាន និងប្រជាពលរដ្ឋ។ បន្ទាប់មក លទ្ធផលទាំងនេះ ត្រូវបានប្រមូលចងក្រង និងរាយការណ៍ត្រឡប់ទៅសហគមន៍នីមួយៗ ដោយអង្គការដៃគូក្នុងស្រុក និងអ្នកស្ម័គ្រចិត្តរបស់វិទ្យាស្ថានជាតិ NDI នៅខែសីហា និងខែកញ្ញា ឆ្នាំ២០១១។

អ្នកតំណាងរាស្ត្រជាច្រើន បានចាត់វិធានការដោះស្រាយកង្វល់ដែលបានលើកឡើងដោយអ្នកចូលរួមនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ហើយការអន្តរាគមន៍របស់ពួកគេកើតឡើងគ្រប់រូបភាព។ ជាញឹកញាប់ អ្នកតំណាងរាស្ត្រ បានសរសេររបាយការណ៍ ឬលិខិតជូនស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ។ ក្នុងករណីខ្លះ អ្នកតំណាងរាស្ត្របានជួបប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន និងធ្វើអន្តរាគមន៍យ៉ាងសកម្មលើបញ្ហាដែលកើតឡើង ដោយជារឿយៗ បានដើរតួនាទីជាអ្នកសម្រុះសម្រួលដ៏សំខាន់ក្នុងការដោះស្រាយជម្លោះផ្សេងៗ។ ជាញឹកញាប់ កិច្ចពិភាក្សារវាង

---

[10] នៅពេលសរសេររបាយការណ៍នេះ កិច្ចប្រជុំពិនិត្យតាមដានភាគច្រើន តែមិនទាំងអស់ទេ ត្រូវបានរៀបចំជាមួយអ្នកតំណាងរាស្ត្រ។ នៅក្នុងសហគមន៍មួយចំនួន ពុំមានពេលវេលាគ្រប់គ្រាន់ ចាប់តាំងពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ត្រូវបានរៀបចំធ្វើឡើងក្នុងការពិនិត្យតាមដានបន្ថែមនៅថ្នាក់មូលដ្ឋាន។ លទ្ធផលដែលបានរាយការណ៍នៅក្នុងរបាយការណ៍នេះគ្រាន់តែជាចំណែកខ្លះៗប៉ុណ្ណោះ។

[11] ជាធម្មតា បុគ្គលិកនៃវិទ្យាស្ថានជាតិ NDI បានជួបជាមួយអ្នកតំណាងរាស្ត្រនៅការិយាល័យអ្នកតំណាងរាស្ត្រ។ ជួនកាលអ្នកតំណាងរាស្ត្រទាំងអស់មិនមានពេលវេលាសម្រាប់ការសម្ភាសន៍ដោយផ្ទាល់ទេ ហើយតាមសំណូមពររបស់ពួកគេ ពួកគេបានបំពេញទម្រង់ពិនិត្យតាមដានរបស់វិទ្យាស្ថានជាតិ NDI ដោយខ្លួនឯង។

អ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត និងការយកចិត្តទុកដាក់របស់អ្នកតំណាងរាស្ត្រជាបន្តបន្ទាប់ បានជួយពន្លឿនផែនការអភិវឌ្ឍន៍ដែលមានស្រាប់សម្រាប់តំបន់មូលដ្ឋាន ជាពិសេសសំណើសុំហេដ្ឋារចនាសម្ព័ន្ធ។ បើទោះបីជា បញ្ហាភាគច្រើនមិនមែនត្រូវបានដោះស្រាយដោយសារកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដោយផ្ទាល់ក៏ដោយ ប៉ុន្តែ កិច្ចពិភាក្សាទាំងនេះមានផលប៉ះពាល់ដ៏គួរឲ្យកត់សម្គាល់ – ជារឿយៗ មានលក្ខណៈប្រយោល និងមិនឃើញដោយជាក់លាក់–ហើយជួនកាល ពិតជាបាននាំឲ្យមានដំណោះស្រាយបញ្ហាដ៏ពេញលេញ។ បើទោះបីជាពុំមានការពាក់ព័ន្ធជាក់លាក់ពីអ្នកតំណាងរាស្ត្រក៏ដោយ ក៏កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានបង្ហាញឲ្យឃើញពីសកម្មភាពល្អ និងខុសច្បាប់ ហើយដែលជាញឹកញាប់ញ៉ាំងឲ្យមានវិធានការផ្លូវការនៅថ្នាក់មូលដ្ឋាន ឬការបញ្ចប់សកម្មភាពដោយអ្នកប្រព្រឹត្តដោយខ្លួនឯង។

ដូចបានលើកឡើងខាងលើ ជារឿយៗ អ្នកតំណាងរាស្ត្របានសរសេរលិខិត ឬជួបជាមួយមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធនានាដើម្បីទាញការចាប់អារម្មណ៍លើបញ្ហាដែលបានលើកឡើងនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ វិទ្យាស្ថានជាតិ NDI បានកត់ត្រានូវរាល់អន្តរាគមន៍ទាំងនេះ ទោះបីជាបញ្ហាទាំងនោះ មិនត្រូវបានដោះស្រាយឲ្យចប់សព្វគ្រប់ក៏ដោយ ព្រោះវាជាការបង្ហាញពីឆន្ទៈ និងការប្តេជ្ញារបស់អ្នកតំណាងរាស្ត្រ។ ឧទាហរណ៍រួមមាន៖

- ***ខេត្តសៀមរាប៖*** ឯកឧត្តម **ឈឹម ម៉ា** អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា បានជួបប្រជុំជាមួយអភិបាលស្រុក និងមេឃុំ ដើម្បីពិភាក្សាលើពាក្យបណ្តឹងរបស់អ្នកចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អំពីអាជ្ញាធរការពារនិងគ្រប់គ្រងប្រាសាទអង្គរវត្ត និងតំបន់សៀមរាប (អាជ្ញាធរអប្សរា) និងការទាមទារសុំការបំភ្លឺអំពីដែនសមត្ថកិច្ច និងបទបញ្ញត្តិរបស់អាជ្ញាធរនេះ។
- ***ខេត្តបន្ទាយមានជ័យ ៖*** ឯកឧត្តម **អន ស៊ុំ** អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា បានជួបប្រជុំជាមួយមន្ត្រីនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត មន្ទីរធនធានទឹក មន្ទីរបរិស្ថាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ មន្ទីរអប់រំយុវជន និងកីឡា មន្ទីរសុខាភិបាល និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីពិភាក្សាលើបញ្ហាដែលបានលើកឡើងនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ។ ឯកឧត្តម បានជំរុញឲ្យមន្ត្រីខេត្តរកដំណោះស្រាយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។
- ***ខេត្តបន្ទាយមានជ័យ ៖*** ឯកឧត្តម **យន្ត ថារូ** អ្នកតំណាងរាស្ត្ររបស់គណបក្ស សម រង្ស៊ី បានរាយការណ៍ថា កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកឧត្តមបានសរសេរលិខិតចំនួន៩ ផ្ញើជូនស្ថាប័នពាក់ព័ន្ធតាមរយៈរដ្ឋសភា ស្នើសុំព័ត៌មានអំពីគម្រោងអភិវឌ្ឍន៍នៅក្នុងខេត្ត។

- ***ខេត្តកំពង់ចាម ៖*** ឯកឧត្តម **យូ ហុកគ្រី** អ្នកតំណាងរាស្ត្ររបស់គណបក្សនរោត្តមរណឫទ្ធិ បានសរសេរលិខិតផ្ញើជូនឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ដើម្បីស្នើសុំអន្តរាគមន៍លើជម្លោះដីធ្លីដែលពាក់ព័ន្ធជាមួយក្រុមហ៊ុន ឡុង ស្រេង ដែលបានដណ្តើមយកដីពីកសិករ នៅភូមិអូប្រាំពីរ ឃុំព្រៃកកក់ ស្រុកស្ទឹងត្រង់។
- ***ខេត្តកំពង់ចាម៖*** ឯកឧត្តម **យូ ហុកគ្រី** អ្នកតំណាងរាស្ត្ររបស់គណបក្សនរោត្តមរណឫទ្ធិ បានសរសេរលិខិតផ្ញើជូនរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីស្នើសុំផ្លូវនៅក្នុងភូមិមាយ២ ឃុំព្រៃកកក់ ស្រុកស្ទឹងត្រង់ និងរដ្ឋមន្ត្រីក្រសួងធនធានទឹក ដើម្បីស្តារឡើងវិញនូវទំនប់តាពន និងទ្វារទឹក នៅឃុំព្រៃកកក់ ស្រុកស្ទឹងត្រង់ ហើយនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដើម្បីស្នើសុំមណ្ឌលសុខភាពនៅឃុំព្រៃកកក់ ស្រុកស្ទឹងត្រង់។
- ***ខេត្តបាត់ដំបង៖*** លោកជំទាវ **មូរ សុខហួរ** អ្នកតំណាងរាស្ត្ររបស់គណបក្ស សម រង្ស៊ី បានស្នើឲ្យអភិបាលខេត្តរងធ្វើអន្តរាគមន៍លើជម្លោះដីធ្លី នៅស្រុកគាស់ក្រឡ និងស្រុកបាណន់។ លោកជំទាវ ក៏បានជួបប្រជុំជាមួយជំទប់ឃុំរបស់គណបក្សប្រជាជនកម្ពុជា និងគណបក្ស សម រង្ស៊ី រួមជាមួយនគរបាលប៉ុស្តិ៍ឃុំដូនបា ផងដែរ ដើម្បីស្នើពួកគេអនុញ្ញាតឲ្យអ្នកភូមិធ្វើស្រែនៅលើដីដែលមានជម្លោះនៅក្នុងឃុំដូនបា។
- ***ខេត្តកំពង់ធំ៖*** បន្ទាប់ពីមានការត្អូញត្អែរ នៅកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ទាក់ទងនឹងប្រាក់បៀវត្សរ៍ទាប សម្រាប់មន្ត្រីរាជការ ជាកត្តាដែលនាំឲ្យមានការប្រព្រឹត្តអំពើពុករលួយ ឯកឧត្តម **ម៉ែន សុថាវរិន្ទ្រ** អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី បានសរសេរលិខិតផ្ញើជូននាយករដ្ឋមន្ត្រី និងអាជ្ញាធរពាក់ព័ន្ធអំពីការតម្លើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ។

បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតជាញឹកញាប់អ្នកតំណាងរាស្ត្របានដើរតួនាទីដ៏មានប្រយោជន៍ និងចាំបាច់បំផុតជាអ្នកចរចារនៅក្នុងជម្លោះផ្សេងៗដោយបង្កើតនូវឱកាសសម្រាប់ការសម្រុះសម្រួល និងបញ្ចុះបញ្ចូល ក្នុងនាមជាងតំណាងនៃផលប្រយោជន៍របស់អ្នកចូលរួម។ ឧទាហរណ៍រួមមាន ៖

- ***ខេត្តព្រៃវែង៖*** ឯកឧត្តម **សុខ ឥសាន** អ្នកតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា បានធ្វើអន្តរាគមន៍លើជម្លោះដីធ្លីជាមួយមន្ត្រីមូលដ្ឋានហើយដីនោះត្រូវបានប្រគល់ឲ្យម្ចាស់ដីពិតប្រាកដវិញ។ ការអន្តរាគមន៍នេះ ត្រូវបានបញ្ជាក់ដោយមន្ត្រីមូលដ្ឋាន។
- ***ខេត្តកណ្តាល៖*** ឯកឧត្តម **ចាន់ ចេង** អ្នកតំណាងរាស្ត្រនៃគណបក្ស សម រង្ស៊ី បានជួបប្រជុំជាមួយសមាជិកក្រុមប្រឹក្សាខេត្តមកពីគណបក្ស សម រង្ស៊ី ដើម្បីពិភាក្សាអំពីតម្លៃខ្ពស់សម្រាប់ធ្វើប័ណ្ណបើកបរ ដែលជាបញ្ហាមួយដែលត្រូវបានលើកឡើងនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ សមាជិកក្រុមប្រឹក្សាខេត្ត បានលើក

យកបញ្ហានេះទៅពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបន្ទាប់ ហើយក្រោយមកតម្លៃប័ណ្ណបើកបរ ត្រូវបានកាត់បន្ថយពី៨០,០០០រៀល មកនៅ៥៧,០០០រៀល។

- ***ខេត្តកំពង់ធំ៖*** អ្នកចូលរួមនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានរាយការណ៍អំពីការខ្វះអត្តសញ្ញាណប័ណ្ណជាតិខ្មែរ។ អ្នកតំណាងរាស្ត្រ បានធ្វើអន្តរាគមន៍លើបញ្ហានេះ ហើយពីរសប្តាហ៍ក្រោយមក អាជ្ញាធរស្រុក បានចែកចាយអត្តសញ្ញាណប័ណ្ណជាតិខ្មែរចំនួន៥,០០០ ដល់អ្នកភូមិនៅក្នុងស្រុកទាំងមូល។
- ***ខេត្តកំពង់ធំ៖*** បន្ទាប់ពីមានការត្អូញត្អែរ ដោយអ្នកចូលរួម មកពីឃុំសាគ្រាមថា ពួកគេមិនទាន់បានទទួលនូវសំណងពីក្រុមហ៊ុនមួយ ដែលបានឈូសឆាយដីរបស់ពួកគេ មួយខែក្រោយវេទិកាកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អភិបាលស្រុក បានរៀបចំកិច្ចប្រជុំជាមួយអ្នកភូមិចំនួន៨៣៨នាក់ នៅវត្តអូរខ្សុង ហើយជាលទ្ធផល គ្រួសារចំនួន៨ បានទទួលសំណង។
- ***ខេត្តកំពង់ធំ៖*** ឯកឧត្តម **ម៉ែន សុថាវរិន្ទ្រ** អ្នកតំណាងរាស្ត្រនៃគណបក្ស សម រង្ស៊ី និង ឯកឧត្តម **ស៊ិក ប៊ុនហុក** អ្នកតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា បានធ្វើអន្តរាគមន៍លើជម្លោះដីធ្លីដែលពាក់ព័ន្ធជាមួយក្រុមហ៊ុន Gold Fusion។ អ្នកដឹកនាំសហគមន៍ភូមិថ្មី នៅក្នុងឃុំស្រើង បានរាយការណ៍ថា ក្រុមហ៊ុននេះ មិនបានធ្វើការឈូសឆាយដីទេរហូតដល់បច្ចុប្បន្ននេះ។
- ***ខេត្តក្រចេះ*** ៖ លោកជំទាវ **ត្រឹង ថាវី** អ្នកតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា បានសរសេរលិខិតផ្ញើជូនប្រធានរដ្ឋសភាស្តីពីជម្លោះដីធ្លី ដែលបានលើកឡើងដោយអ្នកចូលរួមនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ រដ្ឋសភា បានផ្ញើលិខិតមួយច្បាប់ជូនអភិបាលខេត្ត ដោយស្នើសុំឲ្យអភិបាលខេត្តរកដំណោះស្រាយចំពោះករណីនេះ។ ជាលទ្ធផល គ្រួសារចំនួន១៦ បានទទួលសំណងសម្រាប់ដីធ្លីដែលត្រូវបានគេរឹបអូសយកដោយក្រុមហ៊ុនផ្សេងៗ ដូចបានបញ្ជាក់ដោយអាជ្ញាធរស្រុក។

នៅក្នុងករណីមួយចំនួនតូច កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានលើកទឹកចិត្តប្រជាពលរដ្ឋឲ្យចេះរៀបចំបញ្ហានានា ដែលពួកគេជួបប្រទះជារួម។ ឧទាហរណ៍រួមមាន៖

- ***ខេត្តក្រចេះ*** ៖ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ប្រជាពលរដ្ឋចំនួន២០០នាក់ មកពីឃុំចំនួន៣ – ឃុំស្វាយជ្រះ ឃុំពីរធ្នូ និងឃុំខ្សឹម បានរៀបចំពិធីបួងសួងលើជម្លោះដីធ្លីនៅក្នុងវត្តតាពុំ។
- ***ខេត្តកំពង់ធំ៖*** សមាជិកសហគមន៍ព្រៃឈើមកពីឃុំសាមគ្គី ឃុំក្រយា និងឃុំសាគ្រាម បានរាយការណ៍ថា ពួកគេបានជួបប្រជុំជាមួយក្រុមប្រឹក្សាឃុំក្រយា និងឃុំសាមគ្គី ហើយបានព្រមព្រៀងគ្នាលើព្រំប្រទល់ព្រៃឈើ ដែលជាបញ្ហាមួយដែលបានលើកឡើង

នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ រដ្ឋបាលព្រៃឈើ បានប្រាស់ឧបករណ៍ GPS និងបាញ់ថ្នាំពណ៌លើដើមឈើ ដើម្បីកំណត់ព្រំប្រទល់ដីព្រៃចំនួន៧,៧៨២ ហិកតា។

- ***ខេត្តក្រចេះ*** ៖ នៅក្នុងស្រុកស្នួល បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ប្រជាពលរដ្ឋចំនួន៣០០នាក់ បានប្រមូលផ្តុំគ្នា និងបិទផ្លូវទៅកាន់ខេត្តក្រចេះ ដោយទាមទារឲ្យក្រុមហ៊ុនប្រគល់ដីដែលរឹបអូសយកពីពួកគេចំនួន៥,៦០០ហិកតា ឲ្យពួកគេវិញ និងដកពាក្យបណ្តឹងប្រឆាំងនឹងអ្នកតំណាងសហគមន៍ចំនួន៨នាក់ ដែលត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនក្នុងអំឡុងពេលតវ៉ាពីបញ្ហាដីធ្លី។

*ជម្លោះដីធ្លី ដែលត្រូវបានដោះស្រាយដោយអ្នកតំណាងរាស្ត្រ មណ្ឌលក្រចេះ*
*មកពីគណបក្សប្រជាជនកម្ពុជា និងគណបក្ស សម រង្ស៊ី*

សហគមន៍មូលដ្ឋាន នៅឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ និងអ្នកតំណាងរាស្ត្រ បានសហការគ្នាដោះស្រាយជម្លោះដីធ្លី ដែលពាក់ព័ន្ធជាមួយក្រុមហ៊ុនដូវទៀងក្រចេះ (Dau Tieng Kratie) និងក្រុមហ៊ុនដូវទៀងរ៉ាប់ប៊័រ (Dau Tieng Rubber)។ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត សហគមន៍នេះបានប្រមូលផ្តុំគ្នា និងសុំជំនួយពីឯកឧត្តម **ឡុង រី** អ្នកតំណាងរាស្ត្ររបស់គណបក្ស សម រង្ស៊ី និងលោកជំទាវ **ត្រឹង ថារី** អ្នកតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា ដែលបានសរសេរលិខិតស្តីពីបញ្ហាដីធ្លីផ្ញើជូនរដ្ឋសភា។ អ្នកតំណាងរាស្ត្ររបស់គណបក្ស សម រង្ស៊ី បានចែកចាយឯកសារថតចំលងនៃលិខិតអន្តរាគមន៍របស់លោក ដែលបានចុះហត្ថលេខាដោយប្រធានរដ្ឋសភាដល់សហគមន៍។ អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា បានស្នើសុំឲ្យអភិបាលខេត្ត និងអភិបាលស្រុកសរសេររបាយការណ៍លំអិតស្តីពីជម្លោះដីធ្លីជូនរដ្ឋសភា។ សហគមន៍ ក៏បានរៀបចំបាតុកម្មនៅមុខសាលាឃុំស្វាយជ្រះផងដែរ។ កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ ប្រជាពលរដ្ឋចំនួន១០០នាក់ មកពីឃុំស្វាយជ្រះ បានធ្វើដំណើរទៅរាជធានីភ្នំពេញ ដើម្បីតវ៉ានៅមុខផ្ទះរបស់នាយករដ្ឋមន្ត្រី ដើម្បីស្វែងរកអន្តរាគមន៍ពីលោក។

កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ អភិបាលខេត្ត និងអនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ បានឆ្លើយតបទៅនឹងការទាមទារចំនួនបី ក្នុងចំណោមការទាមទារសរុប៥របស់បាតុករ។ ពួកគេ បានកោះហៅតំណាងសហគមន៍បីនាក់ឡើងតុលាការ និងស្នើសុំឲ្យក្រុមហ៊ុនបញ្ឈប់ការឈូសឆាយដីធ្លីរហូតដល់មានដំណោះស្រាយសមស្របមួយ។ ពួកគេ បានទុកពេល១៥ថ្ងៃ ឲ្យសហគមន៍ដើម្បីជូនដំណឹងទៅគណៈកម្មាធិការដោះស្រាយវិវាទដីធ្លីអំពីទីតាំងដីពិតប្រាកដរបស់ពួកគេ។ ក្នុងអំឡុងពេលសរសេររបាយការណ៍នេះ ដី៦០% ត្រូវបានវាស់វែង។

ជាការឆ្លើយតបចំពោះសំណើអភិវឌ្ឍន៍ អ្នកតំណាងរាស្ត្របានដាក់សម្ពាធលើអាជ្ញាធរមូលដ្ឋានឲ្យពន្លឿនគម្រោង ឬគំនិតផ្តួចផ្តើមដែលបានរៀបចំផែនការរួចហើយ ដែលជាញឹកញាប់ការគាបសង្កត់ ឬជម្រុញឲ្យមានលទ្ធផលសម្រាប់សហគមន៍។ ថ្វីត្បិតតែលទ្ធផលទាំងនេះមិនមែនកើតឡើងពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតតែឯង តែកិច្ចពិភាក្សានេះ ក៏បានជួយលើកកម្ពស់ការយល់ដឹងចាំបាច់ និងទាញចំណាប់អារម្មណ៍ចាំបាច់លើបញ្ហាទាំងនេះ ហើយថែមទាំងបានផ្តល់ការលើកទឹកចិត្ត ដើម្បីឲ្យចាត់វិធានការឲ្យលឿន ដែលជួនកាលមិនមានការចូលរួមពីអ្នកតំណាងរាស្ត្រផង។ នៅក្នុងករណីមួយចំនួន អ្នកតំណាងរាស្ត្រ អាចបញ្ចុះបញ្ចូលឲ្យមានកម្មវិធី ឬសកម្មភាពថ្មីដែលបានស្នើដោយម្ចាស់ឆ្នោតប្រកបដោយប្រសិទ្ធភាព។ ឧទាហរណ៍ រួមមាន៖

- ***ខេត្តកំពត៖*** ក្រោយពីមានសំណូមពរពីអ្នកចូលរួមនៅកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដែលបានស្នើសុំការជួសជុលប្រឡាយមួយខ្សែ ៧៧០ម៉ែត្រនៃប្រឡាយនេះ ត្រូវបានជួសជុលពីចំណុចភូមិត្រពាំងសង្កែដល់ឃុំត្រពាំងព្រីង។
- ***ខេត្តព្រៃវែង៖*** ជាការឆ្លើយតបទៅនឹងសំណូមពរដែលបានធ្វើឡើងក្នុងអំឡុងពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ឯកឧត្តម **សុខ ឥសាន** អ្នកតំណាង–រាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា បានរាយការណ៍ថា ផ្លូវថ្នល់ចំនួន២ខ្សែ – មួយខ្សែប្រវែង១៥គីឡូម៉ែត្រ ពីចំណុចភូមិពានាដល់ស្រុកស៊ីធរកណ្តាល និងមួយខ្សែទៀតប្រវែង២០គីឡូម៉ែត្រ ពីចំណុចផ្សារព្រៃញៅតាមបណ្តោយផ្លូវជាតិលេខ៨ដល់ផ្សារព្រែកសណ្តែក--កំពុងត្រូវបានសាងសង់ដោយអង្គភាពវិស្វកម្មនៃកងយុទ្ធពលខេមរភូមិន្ទ។
- ***ខេត្តបន្ទាយមានជ័យ៖*** ឯកឧត្តម **យន្ត ថារូ** អ្នកតំណាងរាស្ត្ររបស់គណបក្ស សម រង្ស៊ី បានរាយការណ៍ថា ផ្លូវថ្នល់ប្រវែង២គីឡូម៉ែត្រពីសាលាក្របាមទៅឃុំចង្ហា ត្រូវបានជួសជុលដោយប្រើប្រាស់ថវិកាអភិវឌ្ឍន៍ឃុំ និងអំណោយសប្បុរសជន។
- ***ខេត្តសៀមរាប៖*** ឯកឧត្តម **ឈឹម ម៉ា** អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា បានណែនាំអាជ្ញាធរមូលដ្ឋាន ឲ្យស្តារឡើងវិញនូវប្រឡាយដែលខូចខាត នៅក្នុងសហគមន៍ដែលបញ្ហាមួយនេះ ត្រូវបានលើកឡើងនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ ជាលទ្ធផល ប្រឡាយប្រវែង៥គីឡូម៉ែត្រ នៅក្នុងសហគមន៍កែវព័រ ស្រុកពួកត្រូវបានជួសជុល។
- ***ខេត្តកំពង់ចាម៖*** មេឃុំព្រែកកក់ និងប្រជាពលរដ្ឋ បានរាយការណ៍ថា បន្ទាប់ពីកិច្ច–ពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរធនធានទឹក បានសិក្សាផ្លូវចំនួន៣ខ្សែ និងទំនប់ទឹកមួយដែលបានខូចខាត ដែលបានលើកឡើងដោយអ្នកចូលរួមនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដើម្បីរៀបចំព្រាងសំណើមួយសម្រាប់ការជួសជុល។

- ***ខេត្តកំពង់ធំ៖*** ឯកឧត្តម **ស៊ិក ប៊ុនហុក** អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា បានរាយការណ៍ថា អាជ្ញាធរមូលដ្ឋាន បានដោះស្រាយបញ្ហាទ្វារទឹក ដែលត្រូវបានលើកឡើងនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត នៅក្នុងឃុំតាំងក្រសៅ។ ទំនប់ទឹកថ្មីមួយកន្លែង ដែលត្រូវបានស្នើសុំដោយអ្នកចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការវិនិយោគឃុំ។ .
- ***ខេត្តបាត់ដំបង៖*** បន្ទាប់ពីមានសំណូមពរដែលបានលើកឡើងនៅកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ផ្លូវ៣ខ្សែត្រូវបានកសាង៖ ផ្លូវមួយខ្សែប្រវែង ៨គីឡូម៉ែត្រមួយខ្សែពីព្រំប្រទល់ភូមិអូរដូនពៅទៅភូមិបូរសង្ឃរាជ ផ្លូវមួយខ្សែប្រវែង ៧គីឡូម៉ែត្រមួយខ្សែពីភូមិអូរដូនពៅទៅភូមិប្រាបហើប និងផ្លូវមួយខ្សែទៀតប្រវែង ៣គីឡូម៉ែត្រមួយខ្សែពីភូមិអូរដូនពៅទៅភូមិត្រពាំងក្បាលស្វា។
- ***ខេត្តកំពង់ឆ្នាំង៖*** បន្ទាប់ពីមានសំណូមពរនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានជួសជុលផ្លូវពីភ្នំជ័យទៅស្រះតាមេធ និងបានសាងសង់កំពែងរក្សាទឹកសម្រាប់ស្រះតាមេធ។

អ្នកចូលរួមនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ក៏បានបង្ហាញឲ្យឃើញពីសកម្មភាពមិនប្រក្រតី ឬសកម្មភាពខុសច្បាប់ដែលត្រូវបានកើតឡើងនៅក្នុងសហគមន៍របស់ពួកគេផងដែរ។ ការលាតត្រដាងដល់សាធារណជន និងអន្តរាគមន៍ជាបន្តបន្ទាប់របស់អ្នកតំណាងរាស្ត្រ ជារឿយៗ បាននាំទៅដល់ការបង្ក្រាបលើសកម្មភាពដែលកំពុងកើតមាន ហើយវាក៏ជារនាំងរាំងអ្នកផ្សេងៗទៀត មិនឲ្យប្រព្រឹត្តខុស។ ឧទាហរណ៍រួមមាន៖

- ***ខេត្តបន្ទាយមានជ័យ៖*** ក្នុងអំឡុងពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អ្នកចូលរួម បានត្អូញត្អែរអំពីអ្នកគួកជេ (ឈ្មួញកណ្តាល) ដែលប្រើជញ្ជីងស៊ីភ្នែកគីឡូ ដើម្បីលួចបន្លំប្រជាពលរដ្ឋលើតម្លៃអង្ករ។ ក្រោយពីមានអន្តរាគមន៍ពីឯកឧត្តម **យន្ត ថារូ** អ្នកតំណាងរាស្ត្ររបស់គណបក្ស សម រង្ស៊ី អាជ្ញាធរខេត្ត បានកម្រិតភ្នែកជញ្ជីងឡើងវិញ នៅតាមរោងម៉ាស៊ីនកិនស្រូវ និងផ្តល់ជញ្ជីងថ្មីដល់មេឃុំ ដើម្បីប្រៀបធៀបទម្ងន់ថ្លឹងជាមួយជញ្ជីងរបស់អ្នកគួកជេ។
- ***ខេត្តសៀមរាប៖*** នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អ្នកចូលរួម បានត្អូញត្អែរអំពីការទារថ្លៃសេវា២,០០០រៀល សម្រាប់សេវាសុខភាព ដែលពួកគេជឿថាសេវាសុខភាព ត្រូវតែផ្តល់ឲ្យដោយមិនគិតថ្លៃ។ ឯកឧត្តម **ឈឹម ម៉ា** អ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា បានជួបប្រជុំជាមួយប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិនៅស្រុកអង្គរជុំ និងត្រូវបានគេប្រាប់ថា ការបង់ថ្លៃសេវា គឺជាការស្ម័គ្រចិត្ត ហើយមិនគួរត្រូវបានទាមទារឡើយ។ បច្ចុប្បន្ន ព័ត៌មាននេះ ត្រូវបានប្រាប់ទៅសហគមន៍រួចហើយ។

- ***ខេត្តកំពត៖*** នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អ្នកនេសាទ បានត្អូញត្អែរអំពីរមណីយដ្ឋានមួយកន្លែងដែលបានបិទផ្លូវមិនឲ្យពួកគេចូលទៅនេសាទ។ បន្ទាប់ពីកិច្ចពិភាក្សាចប់ភ្លាម អ្នកភូមិ និងមេភូមិព្រែកអំពិល ឃុំកោះតូច ស្រុកទឹកឈូ បានរាយការណ៍ថា ម្ចាស់រមណីយដ្ឋាននេះរុះរើរនាំងចេញពីផ្លូវហើយ។
- ***ខេត្តបាត់ដំបង៖*** ការនេសាទខុសច្បាប់ និងភាពអសកម្មរបស់អាជ្ញាធរមូលដ្ឋាន ត្រូវបានលើកឡើងនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ បន្ទាប់ពីកិច្ចពិភាក្សានេះ ប្រជាពលរដ្ឋមកពីស្រុកម៉ោងឫស្សី បានរាយការណ៍ថា សកម្មភាពនេសាទខុសច្បាប់ត្រូវបានកាត់បន្ថយ៦០% ដោយសារតែការចាត់វិធានការរបស់អាជ្ញាធរ។
- ***ខេត្តកំពង់ឆ្នាំង៖*** អ្នកចូលរួម បានត្អូញត្អែរអំពីការជ្រៀតជ្រែករបស់អាជ្ញាធរមូលដ្ឋានក្នុងការបង្កើតបណ្តាញស្ត្រីសហគមន៍។ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បណ្តាញស្ត្រី បានរៀបចំកិច្ចប្រជុំដោយគ្មានការជ្រៀតជ្រែក ឬការបំភិតបំភ័យ។

## V. សេចក្តីសន្និដ្ឋាន

កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតរបស់វិទ្យាស្ថានជាតិ NDI ត្រូវបានរៀបចំឡើងពីខែវិច្ឆិកា ឆ្នាំ២០១០ រហូតដល់ខែកញ្ញាឆ្នាំ២០១១ បានបង្ហាញអំពីបញ្ហាដូចៗគ្នា ដ៏គួរឲ្យកត់សម្គាល់របស់ប្រជាពលរដ្ឋខ្មែរនៅក្នុងខេត្តទាំង១២ ដែលកម្មវិធីទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតត្រូវបានរៀបចំ។ បញ្ហា ដែលត្រូវបានលើកឡើងរួមមានៈ ជម្លោះដីធ្លី បញ្ហាប្រឈមផ្នែកកសិកម្ម ជាពិសេសតម្រូវការផ្នែកធារាសាស្ត្រ និងទីផ្សារ អំពើពុករលួយដ៏រាលដាលជាពិសេសក្នុងចំណោមអាជ្ញាធរមូលដ្ឋាន ការអនុវត្តន៍ច្បាប់មិនស្មើគ្នា និងការមិនបានផ្តល់យុត្តិធម៌ដល់ប្រជាពលរដ្ឋក្រីក្រ ហើយនឹងតម្រូវការហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍ ដូចជា ផ្លូវ មណ្ឌលសុខភាព សាលារៀន និងអគ្គិសនី។ ទោះបីជាមានភាពខុសគ្នាបន្តិចបន្តួច ដែលគួរឲ្យកត់សំគាល់លើបញ្ហាដែលបានលើកឡើងនៅក្នុងកម្មវិធីទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតរបស់វិទ្យាស្ថានជាតិ NDI ក្នុងឆ្នាំមុនៗក៏ដោយ ក៏នៅឆ្នាំនេះបញ្ហាជុំវិញការដណ្តើមដីធ្លី និងសម្បទានសេដ្ឋកិច្ច បានលេចធ្លោកាន់ខ្លាំងឡើង។ ប្រជាពលរដ្ឋខ្មែរហាក់ដូចជាមានការយល់ដឹងថា ទោះបីជាសេដ្ឋកិច្ចនៃប្រទេសរបស់ពួកគេ បាននឹងកំពុងតែរីកចម្រើនក្នុងមួយទសវត្សរ៍កន្លងទៅក៏ដោយ ក៏ការអភិវឌ្ឍន៍បានផ្តល់អត្ថប្រយោជន៍ដល់អ្នកមានលុយ អ្នកមានខ្សែស្រឡាយ និងជនបរទេសជាជាងប្រជាពលរដ្ឋខ្មែរ។ អារម្មណ៍ខឹងសម្បារ និងការមិនពេញចិត្ត បានបញ្ជាក់នៅក្នុងពាក្យសម្តីរបស់ប្រជាពលរដ្ឋ ហើយអ្នកចូលរួមជាច្រើន និយាយឥតលាក់លៀម និងរិះគន់ចំៗនៅក្នុងវេទិកាទាំងនោះ។

នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតភាគច្រើន អ្នកតំណាងរាស្ត្របានសម្តែងអាកប្បកិរិយាប្រកបដោយវិជ្ជាជីវៈ អនុវត្តតាមពិធីការនៃកិច្ចពិភាក្សា និងចៀសវាងមិនធ្វើការវាយប្រហារជាលក្ខណៈបុគ្គល និងរិះគន់បែបបន្ទុះបង្អាប់។ ពួកគេ ក៏បានបង្ហាញពីវិន័យបក្សដ៏ល្អប្រសើរ ដោយរក្សាសារនយោបាយ និងគោលជំហរគណបក្សរបស់ពួកគេ នាំឲ្យមានការឆ្លើយតបស៊ីសង្វាក់គ្នាទៅនឹងបញ្ហាសំខាន់ៗ។ ការអនុវត្តន៍ជារួម និងសិល្បៈនៃការនិយាយរបស់អ្នកតំណាងរាស្ត្រ មានការរីកចម្រើនជាងឆ្នាំមុនៗ ហើយអ្នកតំណាងរាស្ត្របានបង្ហាញពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការស្តាប់ម្ចាស់ឆ្នោត ហើយឆ្លើយតបច្បាស់ៗទៅនឹងកង្វល់របស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។ កម្រិតជំនាញ មានលក្ខណៈផ្សេងៗគ្នាក្នុងចំណោមអ្នកតំណាងរាស្ត្រម្នាក់ៗ ប៉ុន្តែគុណភាពនៃការអនុវត្តន៍របស់ពួកគេ មិនជាប់ទាក់ទិនទៅនឹងនិន្នាការគណបក្សទេ។ អ្នកចូលរួម ហាក់ដូចជាឆ្លើយតបជាវិជ្ជមានច្រើនទៅនឹងអ្នកតំណាងរាស្ត្រ ដែលបានឆ្លើយតបនឹងការដោះស្រាយជាក់លាក់ និងមានលក្ខណៈជាប្រព័ន្ធចំពោះបញ្ហានីមួយៗដែលកើតឡើងជាជាងអ្នកដែលនិយាយទូទៅ ឬឲ្យមន្ត្រីមូលដ្ឋានឆ្លើយតបនឹងបញ្ហាជំនួសពួកគេ។

នៅក្នុងករណីខ្លះ គណបក្សនយោបាយ បានបញ្ជូនអ្នកតំណាងរាស្ត្រមកពីមណ្ឌលផ្សេង មកចូលរួមកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ អ្នកតំណាងរាស្ត្រ ត្រូវបានគេបោះឆ្នោតឲ្យតាមខេត្តដែលមានឈ្មោះក្នុងបញ្ជីឈ្មោះគណបក្សខេត្ត ហើយពួកគេទទួលខុសត្រូវចំពោះម្ចាស់ឆ្នោតនៅក្នុងខេត្តនោះ។ នៅពេលដែលអ្នកតំណាងរាស្ត្រមកពីមណ្ឌលផ្សេង បានចូលរួមកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ជារឿយៗ ពួកគេអនុវត្តមិនសូវបានល្អដូចអ្នកតំណាងរាស្ត្រមកពីមណ្ឌលនោះផ្ទាល់ទេ ពីព្រោះពួកគេមិនដឹងច្បាស់អំពីបញ្ហានៅមូលដ្ឋាននិងមិនស្គាល់អ្នកដឹកនាំមូលដ្ឋាន និងមិនអាចបន្តតាមដានបាន។ អ្នកចូលរួមស្តាប់នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ហាក់ដូចជាមានអារម្មណ៍ច្របូកច្របល់ ជាពិសេស នៅពេលដែលអ្នកតំណាងរាស្ត្រមកពីមណ្ឌលផ្សេង ថ្លែងអំណរគុណពួកគេដែលបានបោះឆ្នោតឲ្យ។ ថ្វីត្បិតតែភារកិច្ចរបស់រដ្ឋសភា គឺត្រូវធ្វើជាតំណាងប្រជាពលរដ្ឋទាំងអស់ក៏ដោយ ក៏គណបក្ស និងអ្នកតំណាងរាស្ត្រ គួរតែយកចិត្តទុកដាក់ដោយផ្ទាល់ដល់អ្នកបោះឆ្នោតក្នុងមណ្ឌលរបស់ខ្លួនដែលជាយុទ្ធសាស្ត្រមួយអាចជួយឲ្យពួកគេជាប់ឆ្នោតម្តងទៀតនាពេលអនាគតនៅក្នុងមណ្ឌលនោះ ជាជាងការបញ្ជូនអ្នកតំណាងរាស្ត្រចុះផ្សព្វផ្សាយទូទាំងប្រទេស។

ជារួម កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានបង្កើតលទ្ធផលជាក់ច្បាស់ ដែលលទ្ធផលជាច្រើនអាចកើតចេញដោយផ្ទាល់ពីសកម្មភាពរបស់អ្នកតំណាងរាស្ត្រ ដែលបានចូលរួមក្នុងកិច្ចពិភាក្សាទាំងនោះ។ អ្នកតំណាងរាស្ត្រ បានបង្ហាញពីការប្តេជ្ញាចិត្តដ៏មុតមាំចំពោះម្ចាស់ឆ្នោត និងបង្ហាញនូវភារកិច្ចជាអ្នកតំណាងចំពោះប្រជាពលរដ្ឋហើយអ្នកតំណាងរាស្ត្រជាច្រើន បានគោរពការសន្យារបស់ខ្លួនយ៉ាងតិចក៏មួយដែរ។ អន្តរាគមន៍ផ្សេងៗ ត្រូវបានដឹកនាំដោយសហគមន៍ ឬអាជ្ញាធរមូលដ្ឋាន។ ជារឿយៗ កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត គឺជាការរារាំងមិនឲ្យមានការអនុវត្តន៍ខុសច្បាប់បន្ថែមទៀត ដោយបានឆ្លុះបញ្ចាំងនូវបញ្ហា និងវែកមុខជនល្មើសជាសាធារណៈ។ ដូច្នេះ ទោះបីជា គ្មានអ្នកណាម្នាក់ចាត់វិធានការជាក់លាក់លើបញ្ហាក៏ដោយ ក៏បញ្ហានោះត្រូវបានបញ្ឈប់ដែរ។ នៅក្នុងករណីជាច្រើន អ្នកតំណាងរាស្ត្រ បានចាត់វិធានការដោះស្រាយបញ្ហា ប៉ុន្តែ រហូតដល់ពេលនេះ ពុំទាន់មានលទ្ធផលណាមួយ ដែលត្រូវបានរាយការណ៍ទេ។ ទោះជាយ៉ាងនេះក្តី វិទ្យាស្ថានជាតិ NDI ទទួលស្គាល់ថា អ្នកតំណាងរាស្ត្រទាំងអស់ដែលបានព្យាយាមឆ្លើយតបទៅនឹងកង្វល់នានា ដែលបានលើកឡើងដោយម្ចាស់ឆ្នោត។

មុខងារជាតំណាងរបស់អ្នកតំណាងរាស្ត្រ ត្រូវបានពង្រឹងតាមរយៈកម្មវិធីទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដោយអ្នកតំណាងរាស្ត្របានចាត់វិធានការចាំបាច់ក្នុងការលើកឡើងពីកង្វល់របស់ម្ចាស់ឆ្នោតជូនស្ថាប័នពាក់ព័ន្ធ។ ដូចអ្នកតំណាងរាស្ត្រម្នាក់របស់គណបក្ស សម រង្ស៊ី នៅមណ្ឌលក្រចេះ បានថ្លែងថា "ខ្ញុំគឺជាអ្នកបំរើរបស់អ្នក ខ្ញុំធ្វើការឲ្យអ្នក"។ អ្នកតំណាងរាស្ត្រ បាននឹងកំពុងតែត្រួតពិនិត្យតាមដាន ជាពិសេសទាក់ទងនឹងការអនុវត្តន៍

ខុសច្បាប់នៅថ្នាក់មូលដ្ឋាន។ ប៉ុន្តែក៏គួរឲ្យកត់សម្គាល់ផងដែរថាគ្មានការអន្តរាគមន៍ណាមួយពាក់ព័ន្ធដល់ស្ថាប័ននីតិប្បញ្ញត្តិទេ។ ផ្ទុយទៅវិញ បញ្ហាទៅវិញបញ្ហាទាំងនោះ ត្រូវបានលើកឡើងដល់ក្រសួងរបស់រាជរដ្ឋាភិបាល និងមន្ត្រី។ បញ្ហាជាច្រើនដែលត្រូវបានលើកឡើងក្នុងកំឡុងពេលកិច្ចពិភាក្សាស្ថិតក្នុងរង្វង់សមត្ថកិច្ចរបស់ស្ថាប័ននីតិប្រតិបត្តិក៏ដោយ ក៏សភាជាតិអាចបំពេញតួនាទីដ៏សំខាន់ដោះស្រាយបញ្ហានានា តាមរយៈមុខងារតាក់តែងច្បាប់របស់ខ្លួនដែរ។ ប្រជាពលរដ្ឋ បានកំណត់បង្ហាញយ៉ាងត្រឹមត្រូវនូវការធ្វើច្បាប់របស់សភាជាតិ មិនមែនគ្រាន់តែចាំអនុម័តសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាលឡើយ និងបានសម្តែងនូវសេចក្តីរំពឹងទុករបស់គេថា សភាជាតិ នឹងអនុវត្តអំណាចនេះជាមិនខាន។

ដូចគ្នានេះដែរ កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ហាញជូនប្រជាពលរដ្ឋទូទាំងប្រទេស នូវជម្រើសនយោបាយផ្សេងៗរបស់ពួកគេ។ នៅកម្ពុជា មានឱកាសតិចតួច – បើសិនមាន – សម្រាប់អ្នកតំណាងរាស្ត្ររបស់គណបក្សកាន់អំណាច និងគណបក្សប្រឆាំងក្នុងការចូលរួមកៀកស្មាគ្នា នៅក្នុងវេទិកាសាធារណៈ និងឆ្លើយសំណួររបស់ប្រជាពលរដ្ឋ។ បន្ទាប់ពីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អ្នកចូលរួមការពិភាក្សាក្រុមគោលដៅ បានបង្ហាញនូវការយល់ដឹងដ៏ទូលំទូលាយអំពីគណបក្សប្រឆាំង និងតម្លៃនៃលទ្ធិប្រជាធិបតេយ្យពហុបក្ស។

ទោះបីជាសម្រេចបានលទ្ធផលទាំងនេះក៏ដោយ ក៏ការពិភាក្សាក្រុមគោលដៅបានបង្ហាញថា ប្រជាពលរដ្ឋនៅមានការយល់ដឹងមានកម្រិតអំពីរដ្ឋសភា និងគោលបំណងរបស់រដ្ឋសភានៅឡើយ។ ជាញឹកញាប់ អ្នកចូលរួម អាចកំណត់បានត្រឹមតែការតាក់តែងច្បាប់ថាជាតួនាទីដ៏សំខាន់របស់រដ្ឋសភាប៉ុណ្ណោះ ផ្ទុយទៅវិញបានបង្ហាញនូវការយល់ដឹងតិចតួចអំពីផលប៉ះពាល់របស់ច្បាប់។ ប្រជាពលរដ្ឋ មិនយល់ច្បាស់អំពីតួនាទីរបស់អ្នកតំណាងរាស្ត្រម្នាក់ៗ និងបានយល់ច្រឡំពីមុខងាររបស់អ្នកតំណាងរាស្ត្រថា ចែកអំណោយ និងសេវានានាដល់ប្រជាពលរដ្ឋដូចគ្នានឹងមុខងាររបស់រាជរដ្ឋាភិបាលដែរ។ ទោះបីជាការចូលរួមនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានពង្រឹងការយល់ដឹងរបស់ពួកគេមួយចំនួនយ៉ាងណាក៏ដោយ ក៏អ្នកចូលរួម នៅតែមិនសូវយល់ដឹងឲ្យបានទូលំទូលាយអំពីតួនាទីរបស់រដ្ឋសភា និងអ្នកតំណាងរាស្ត្រ ឬទំនាក់ទំនងរបស់ស្ថាប័ននីតិប្បញ្ញត្តិជាមួយជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ នេះ គឺហាក់ដូចជាដោយសាររដ្ឋសភា និងអ្នកតំណាងរាស្ត្រ មានផលប៉ះពាល់តិចតួចលើពួកគេរហូតដល់ពេលបច្ចុប្បន្ននេះ។ ប្រជាពលរដ្ឋមួយចំនួន មិនមានទំនាក់ទំនងជាមួយ ឬទទួលព័ត៌មានពីរដ្ឋសភា និងអ្នកតំណាងរាស្ត្រ មុនកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតឡើយ។ អ្នកចូលរួមការពិភាក្សាក្រុមគោលដៅភាគច្រើន មិនអាចប្រាប់អំពីគំនិតផ្តួចផ្តើម ឬកម្មវិធីណាមួយដែលត្រូវបានអនុវត្តដោយស្ថាប័ននីតិប្បញ្ញត្តិក្នុងនាមប្រជាពលរដ្ឋឡើយ ។

លទ្ធផលទាំងនេះ បង្ហាញថា រដ្ឋសភា និងអ្នកតំណាងរាស្ត្រ មិនបានបំពេញភារកិច្ចរបស់ខ្លួនបានល្អ ពីព្រោះប្រជាពលរដ្ឋនៅតែមិនយល់ដឹង និងមិនបានទទួលនូវផលប៉ះពាល់ពីការងាររបស់ពួកគេឡើយ។ ក្រៅពីការមិនបានផ្តួចផ្តើមគំនិតលើការតាក់តែងច្បាប់រដ្ឋសភាពុំមាននីតិវិធីសម្រាប់សវនាការជាសាធារណៈ ឬការសិក្សាស្រាវជ្រាវ និងការស៊ើបអង្កេតស៊ីជម្រៅ។ រដ្ឋសភា មិនបានបំពេញកិច្ចខិតខំប្រឹងប្រែងឲ្យបានគ្រប់គ្រាន់ក្នុងការចុះទស្សនកិច្ចតាមមណ្ឌលបោះឆ្នោត ឬបង្កើតវិធីសាស្ត្រផ្សេងៗទៀត ដើម្បីផ្សព្វផ្សាយព័ត៌មានតាមមណ្ឌលបោះឆ្នោត ឧទាហរណ៍ តាមរយៈព្រឹត្តិប័ត្រ ប្រព័ន្ធរក្សាបញ្ជីអ៊ីម៉ែល ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងទៀត។ ស្ថាប័ននីតិប្រតិបត្តិកំណត់របៀបវារៈរដ្ឋសភា និងដឹកនាំចាត់ចែងរដ្ឋសភាលើគ្រប់កិច្ចការរបស់រដ្ឋសភា។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋខ្មែរនៅតែចាប់អារម្មណ៍ស្តាប់តំណាងរបស់ពួកគេព្រមទាំងជឿទុកចិត្តថា អ្នកតំណាងរាស្ត្រ នឹងបំពេញនូវការសន្យារបស់ខ្លួន។ ម្ចាស់ឆ្នោត ចង់ឲ្យបង្កើននូវទំនាក់ទំនងជាមួយនឹងអ្នកតំណាងរាស្ត្រហើយនឹងទទួលនូវព័ត៌មានពីអ្នកដែលពួកគាត់បានបោះឆ្នោតជ្រើសរើសដើម្បីបំរើផលប្រយោជន៍ពួកគាត់នៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ។

កម្មវិធីទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតរបស់វិទ្យាស្ថានជាតិ NDI បានផ្តល់ឱកាសដ៏សំខាន់ដល់អ្នកតំណាងរាស្ត្រ ដើម្បីកសាងទំនាក់ទំនងជាមួយសហគមន៍ និងបំពេញភារកិច្ចរបស់ខ្លួន ប៉ុន្តែឱកាសដែរនេះមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ រដ្ឋសភា និងសមាជិកសភា គួរតែបានបំពេញភារកិច្ចរបស់ខ្លួនបានល្អ ដើម្បីផ្តល់ព័ត៌មានឲ្យបានកាន់តែច្រើនទៅដល់ប្រជាពលរដ្ឋនៅមូលដ្ឋានអំពីការងារ របៀបវារៈ និងកម្មវិធីរបស់រដ្ឋសភា ហើយនឹងផ្តល់ព័ត៌មានទាំងនេះទៅសមាជិកសភាគ្រប់រូប ដើម្បីបង្កើនកិច្ចប្រឹងប្រែងចុះជួបសំណេះសំណាលជាមួយម្ចាស់ឆ្នោតរបស់ខ្លួនឲ្យកាន់តែញឹកញាប់។

# ឧបសម្ព័ន្ធ

តារាងសង្ខេបកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតរបស់វិទ្យាស្ថានជាតិ NDI ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១០ ដល់ខែកញ្ញា ឆ្នាំ២០១១

| កាលបរិច្ឆេទ | ទីកន្លែងនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត | | | | អ្នកចូលរួម | អ្នកតំណាងរាស្ត្រ | |
|---|---|---|---|---|---|---|---|
| | ខេត្ត | ស្រុក | ឃុំ | ភូមិ | | ឈ្មោះ | គណបក្ស |
| ២៧/១១/២០១០ | សៀមរាប | ពួក | កែវព័ណ៌ | កំភេម | ៤០៣ | ឯកឧត្តម ឈឹម ម៉ា | CPP |
| | | | | | | លោកជំទាវ កែ សុវណ្ណរតន៍ | SRP |
| ០៤/១២/២០១០ | កណ្ដាល | កណ្ដាលស្ទឹង | អំពៅព្រៃ | តាដោល២ | ៧៩៣ | លោកជំទាវ ហូ ណូន | CPP |
| | | | | | | ឯកឧត្តម ចាន់ ចេង | SRP |
| | | | | | | ឯកឧត្តម អ៊ូ ច័ន្ទឬទ្ធិ | HRP |
| ១៨/១២/២០១០ | បាត់ដំបង | បវេល | ក្ដុលតាហែន | អូរដូនពៅ | ៤២៧ | លោកជំទាវ ជួញ សុផៃ | CPP |
| | | | | | | លោកជំទាវ មូរ សុខហួរ | SRP |
| ១៥/០១/២០១១ | កំពង់ធំ | ប្រាសាទបល្ល័ង្ក | ក្រយា | ក្រយា | ៦០៤ | ឯកឧត្តម ស៊ិក ប៊ុនហុក | CPP |
| | | | | | | ឯកឧត្តម ម៉ែន សុថាវរិន្ទ្រ | SRP |
| ២៩/០១/២០១១ | កំពត | ទឹកឈូ | ត្រពាំងសង្កែ | ត្រពាំងសង្កែ | ១៩២ | ឯកឧត្តម សោម ចិន | CPP |
| | | | | | | ឯកឧត្តម ហូរ វ៉ាន់ | SRP |
| ១២/០២/២០១១ | បន្ទាយមានជ័យ | អូរជ្រៅ | ចង្ហា | តាជោក | ៩៦៣ | ឯកឧត្តម អន ស៊ុំ | CPP |
| | | | | | | ឯកឧត្តម យន្ត ថារូ | SRP |
| | | | | | | ឯកឧត្តម ជា គីម | FCP |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៩/០២/២០១១ | ព្រៃវែង | ស៊ីធរកណ្ដាល | អំពិលក្រៅ | ស្វាយទៀប | ៣៦៧ | ឯកឧត្តម សុខ ឥសាន | CPP |
| | | | | | | ឯកឧត្តម ជា ប៉ូច | SRP |
| | | | | | | ឯកឧត្តម សៅ រ៉ានី | NRP |
| ២៦/០២/២០១១ | កំពង់ស្ពឺ | ឱរ៉ាល់ | សង្កែសាទប | គោក | ៤០១ | លោកជំទាវ ឡាក់ អួន | CPP |
| | | | | | | ឯកឧត្តម នុត រុំដួល | SRP |
| ១២/០៣/២០១១ | តាកែវ | សំរោង | បឹងត្រាញ់ខាងត្បូង | ស្រីជ័យ | ៣៤៧ | ឯកឧត្តម  អ៊ុំ សុខន | CPP |
| | | | | | | ឯកឧត្តម ម៉ៅ មុនីវណ្ណ | SRP |
| ២៣/០៤/២០១១ | ក្រចេះ | ស្នួល | ស្វាយជ្រះ | វត្ត | ៨៤៨ | លោកជំទាវ ត្រឹង ថាវី | CPP |
| | | | | | | ឯកឧត្តម ឡុង រី | SRP |
| ៣០/០៤/២០១១ | កំពង់ឆ្នាំង | ជលគីរី | ព្រៃគ្រី | ព្រៃគ្រីជើង | ៦១៥ | លោកជំទាវ កែ ច័ន្ទមុនី | CPP |
| | | | | | | ឯកឧត្តម ឃី វណ្ណដេត | SRP |
| ០៧/០៥/២០១១ | កំពង់ចាម | ស្ទឹងត្រង់ | ព្រែកកក់ | មាយ២ | ៤១៣ | ឯកឧត្តម ជិន គឹមស្រេង | CPP |
| | | | | | | ឯកឧត្តម គួយ ប៊ុនរឿន | SRP |
| | | | | | | ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ | HRP |
| | | | | | | ឯកឧត្តម យូ ហុកគ្រី | NRP |
| ២៦/០៣/២០១១ | សៀមរាប | ប្រាសាទបាគង | កន្ទ្រាំង | ស្រិត | ៥១២ | ឯកឧត្តម សំ ហ៊ាង | CPP |
| | | | | | | លោកជំទាវ  កែ សុវណ្ណរតន៍ | SRP |
| ២១/០៥/២០១១ | កណ្ដាល | កោះធំ | ឈើខ្មៅ | ចុងខ្សាច់ | ៥២៣ | លោកជំទាវ ហូ ណូន | CPP |
| | | | | | | ឯកឧត្តម ចាន់ ចេង | SRP |
| | | | | | | ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ | HRP |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៨/០៥/២០១១ | បាត់ដំបង | ម៉ោងឫស្សី | គារ | គារ៣ | ៩០៨ | លោកជំទាវ លី គឹមលៀង | CPP |
| | | | | | | លោកជំទាវ មូរ សុខហួរ | SRP |
| ០៤/៦/២០១១ | កំពត | ជុំគីរី | ត្រពាំងរាំង | តារាជ | ២០៩ | ឯកឧត្តម សោម ចិន | CPP |
| | | | | | | ឯកឧត្តម ជា ប៉ូច | SRP |
| ១១/៦/២០១១ | កំពង់ធំ | ប្រាសាទសម្បូរណ៍ | តាំងក្រសៅ | តាំងក្រសៅ | ៦០៥ | ឯកឧត្តម ស៊ិក ប៊ុនហុក | CPP |
| | | | | | | ឯកឧត្តម ម៉ែន សុថាវរិន្ទ្រ | SRP |
| ២៥/៦/២០១១ | បន្ទាយមានជ័យ | ស្វាយចេក | ស្លក្រាម | ខ្លែងពណ៌ខាងជើង | ៣៦៨ | ឯកឧត្តម ប៉ាល់ សំអឿន | CPP |
| | | | | | | ឯកឧត្តម យន្ត ថារូ | SRP |
| | | | | | | ឯកឧត្តម ញឹក ប៊ុនឆៃ | FCP |
| ០២/៧/២០១១ | ព្រៃវែង | កញ្ជ្រៀច | គោកគង់លិច | អ្នកតាជ័យ | ៣០៧ | ឯកឧត្តម សុខ ឥសាន | CPP |
| | | | | | | ឯកឧត្តម គង់ បូរ៉ា | SRP |
| | | | | | | ឯកឧត្តម សៅ រ៉ានី | NRP |
| | | | | | | ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ | HRP |
| ៩/៧/២០១១ | កំពង់ស្ពឺ | ឧត្តុង្គ | ដំណាក់រាំង | ពោធិ៍ | ៤៣០ | ឯកឧត្តម លី សុន | CPP |
| | | | | | | ឯកឧត្តម នុត រុំដួល | SRP |
| ២៣/៧/២០១១ | តាកែវ | បាទី | ពត់សរ | ព្រៃស្វា | ៥៥៨ | ឯកឧត្តម ប្រាក់ ធុច | CPP |
| | | | | | | ឯកឧត្តម តុ វ៉ាន់ចាន់ | SRP |
| ៣០/៧/២០១១ | កំពង់ចាម | មេមត់ | ជាំតាម៉ៅ | បុស្សតាអឹម | ៩៥៨ | ឯកឧត្តម វ៉ាន់ សេងលី | CPP |
| | | | | | | ឯកឧត្តម គួយ ប៊ុនរឿន | SRP |
| | | | | | | ឯកឧត្តម យូ ហុកគ្រី | NRP |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦/៨/២០១១ | ក្រចេះ | សម្បូរ | កោះខ្ញែរ | ស្វាយចេក | ៩០១ | លោកជំទាវ ត្រឹង ថារី | CPP |
| | | | | | | ឯកឧត្តម ឡុង រី | SRP |
| ១៣/៨/២០១១ | កំពង់ឆ្នាំង | បរិបូណ៌ | ពេជ្រចង្វារ | តាំងត្រពាំង | ៥២៨ | ឯកឧត្តម កែវ សូសាក់ | CPP |
| | | | | | | ឯកឧត្តម គីមសួរ ភិរិទ្ធ | SRP |
| ចំនួនសរុបនៃប្រជាពលរដ្ឋដែលបានចូលរួមនៅកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតរបស់វិទ្យាស្ថានជាតិ NDI ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១១ | | | | | ១១,១៨០ | អ្នកតំណាងរាស្ត្រសរុប ៣៥នាក់ | |